ពុទ្ធិកសមាគមខ្មែរនៅកម្ពុជា

កម្មវិធីសិទ្ធិមនុស្ស

# កម្មវិធីហ្វឹកហ្វឺន

អំពី

# សិទ្ធិមនុស្ស និង ព្រះពុទ្ធសាសនា

សំរាប់

## សមណសិស្ស និង មន្ត្រីរាជការ

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

២១៥.
១

www.budhist.gov.kh www.elibraryofcambodia.org

## **ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage.  This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

www.budinst.gov.kh        www.elibraryofcambodia.org

២១៥.១
២៦៤

# គណៈកម្មការរៀបរៀងកម្មវិធីសិក្សា

***********

**ព្រាងដោយ :**

- លោក អ៊ុ ប៊ុនឡុង — ចាងហ្វាងអនុវត្តនៃពុទ្ធិកសមាគមខ្មែរនៅកម្ពុជា
- លោក អានឌ្រិច ម៉ាកស៊ីលីណូ — ក្រុមពិសេសនៃផ្នែកសិទ្ធិមនុស្សនៅកម្ពុជា
- លោក ខាល ស្ទៀលឡេសឌ៍ — មន្ត្រីសិទ្ធិមនុស្សនៃមជ្ឈមណ្ឌលអង្គការសហប្រជាជាតិខាងផ្នែកសិទ្ធិមនុស្ស
- លោក អ៊ុង ជីវ័ន្ត — គ្រូហ្វឹកហ្វឺននៃពុទ្ធិកសមាគមខ្មែរនៃកម្ពុជា
- លោក ស្រ៊ុន លីមហេង — គ្រូហ្វឹកហ្វឺននៃពុទ្ធិកសមាគមខ្មែរនៃកម្ពុជា
- អ្នកស្រី ពៅ ម៉ូរ៉េម — គ្រូហ្វឹកហ្វឺននៃពុទ្ធិកសមាគមខ្មែរនៃកម្ពុជា

**ពិនិត្យ និង កែសំរួលដោយ :**

- បណ្ឌិត គុណ ផេង — អ្នកពិនិត្យ និង កែសម្រួលសៀវភៅព្រះសមណគោតម
- អនុបណ្ឌិត សំ យ៉ាង — ផ្នែកប្រវត្តិព្រះពុទ្ធសាសនា និង ជាសាស្ត្រាចារ្យនៅសកលវិទ្យាល័យភ្នំពេញ
- លោក ខាល ស្ទៀលឡេសឌ៍ — មន្ត្រីសិទ្ធិមនុស្សនៃមជ្ឈមណ្ឌលអង្គការសហប្រជាជាតិខាងផ្នែកសិទ្ធិមនុស្ស

BUDDHIST INSTITUTE LIBRARY
៣៦៥/៩៤

**អនុម័តដោយ :**

- សម្តេចព្រះសង្ឃរាជ ទេព វង្ស
- ឯកឧត្តម ហៀង ចន្ទារ័ត្ន រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា ។

www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធិកសមាគមខ្មែរនៅកម្ពុជា

# កម្មវិធីហ្វឹកហ្វឺន

## I. គោលដៅនៃវគ្គហ្វឹកហ្វឺន

នៅចុងបញ្ចប់នៃវគ្គហ្វឹកហ្វឺនដែលមានរយៈពេល ៣០ម៉ោងនេះ សមណសិស្ស និង សិក្ខាកាមអាចយល់ដឹង:

១_ អំពីសិទ្ធិមនុស្ស ច្បាប់ជាតិ និង ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយនិង អំពីចំណេះដឹងទូទៅដែលទាក់ទងនឹងការជួយការពារ និង លើកស្ទួយសិទ្ធិមនុស្ស ។

២_ ការទំនាក់ទំនងរវាងព្រះធម៌នៃព្រះពុទ្ធសាសនា និង សិទ្ធិមនុស្ស ។

៣_ អំពីការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌ ។

៤_ អំពីតួនាទីព្រះសង្ឃព្រះពុទ្ធសាសនា និង មន្ត្រីរាជការក្នុងរដ្ឋប្រជាធិបតេយ្យ ។

៥_ អំពីគោលនៃវិជ្ជាសង្គមកិច្ច ។

## II. រយៈពេលហ្វឹកហ្វឺន

_ រយៈពេលនៃការសិក្សា : ៣០ម៉ោង

## III. មាតិកាមេរៀន


១_ មេរៀនទី ១ : តម្លៃ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស

២_ មេរៀនទី ២ : ការវិវត្តន៍បទដ្ឋានសិទ្ធិមនុស្សជាសកល

៣_ មេរៀនទី ៣ : តើសិទ្ធិមនុស្សជាអ្វី ?

៤_ មេរៀនទី ៤ : សិទ្ធិមនុស្ស និង ព្រះពុទ្ធសាសនា

៥_ មេរៀនទី ៥ : ច្បាប់ទូទៅ ធម្មាធិបតេយ្យ ហើយនិង សិទ្ធិមនុស្ស និង ច្បាប់

៦_ មេរៀនទី ៦ : ការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌ "ភាគ១"

៧_ មេរៀនទី ៧ : ការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌ "ភាគ២"

៨_ មេរៀនទី ៨ : តួនាទីរបស់ព្រះសង្ឃនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៩_ មេរៀនទី ៩ : តួនាទីរបស់មន្ត្រីរាជការនៅក្នុងរដ្ឋប្រជាធិបតេយ្យ

១០_ មេរៀនទី ១០ : គោលនៃវិជ្ជាសង្គមកិច្ច


www.budinst.gov.kh www.elibraryofcambodia.org

## IV. សេចក្តីណែនាំសំរាប់គ្រូបង្ហាត់

- គ្រូបង្ហាត់ត្រូវពន្យល់វិធីសាស្ត្រនៃមេរៀនដល់សិស្សឱ្យយល់ដឹងជាមុន ដើម្បីសិស្សអនុវត្តវិធីសាស្ត្រទាំងនេះក្នុងការហ្វឹកហ្វឺនបន្តទៅទៀត ។
- គ្រូបង្ហាត់ត្រូវស្រង់យោបល់ល្អៗរបស់សិស្សសំរាប់កែលំអកម្មវិធីហ្វឹកហ្វឺននេះថែមទៀត ។
- គ្រូបង្ហាត់អាចជ្រើសរើសរបៀបរៀបកៅអីអង្គុយ ឬ ផ្លាស់ប្តូរទីកន្លែងសិស្សអង្គុយទៅតាមបំណងរបស់គ្រូ និង តាមលទ្ធភាពនៃថ្នាក់រៀន ។

## V. វិធីសាស្ត្របង្រៀនក្នុងកម្មវិធីហ្វឹកហ្វឺន

១_ ពិភាក្សាបំផុសគំនិត ( Brainstorming )
២_ ពិភាក្សាជាក្រុម ( Group discussion )
៣_ ធ្វើការពិចារណាលើរឿងមួយជាឧទាហរណ៍ ( Case study )
៤_ អត្ថាធិប្បាយរីកញែកមេរៀន ( Lecture discussion )
៥_ សិស្សសួរបញ្ជាក់ ( Open question )
៦_ ពិភាក្សារកខុសរកត្រូវ ( Debate )
៧_ អញ្ជើញអ្នកឯកទេសមកពន្យល់ ( Guest speaker )
៨_ ការរំឭកឱ្យមើលឯកសារជាមុន ( Pre-requisite reading assignment )
៩_ រៀបកន្លែងអង្គុយនៅក្នុងថ្នាក់សំរាប់មេរៀននីមួយៗ ( ផ្លាស់ប្តូរកន្លែង ឬ រៀបកៅអីអង្គុយ )
( Disposition of seats or Change of students seats )
១០_ អានមេរៀនដោយសិស្ស និង ចោទសំណួរ ( Reading by student and Open questions )

## VI. ការផ្តើមនៃវគ្គហ្វឹកហ្វឺន

- បទឧទ្ទេសនាមរបស់គ្រូបង្ហាត់ម្នាក់ៗ
- បទឧទ្ទេសនាមរបស់សិក្ខាកាម និង សមណសិស្សទៅវិញទៅមក
- ការណែនាំឱ្យដឹងពីគោលដៅនៃវគ្គហ្វឹកហ្វឺន និង គោលដៅនៃមេរៀននីមួយៗ ។

www.budinst.gov.kh www.elibraryofcambodia.org

# កម្មវិធីមុខវិជ្ជាសំរាប់គ្រូបង្ហាត់នៃមេរៀនទី ១

*******

## តម្លៃ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស

### ១. គោលដៅ :

នៅចុងបញ្ចប់នៃមេរៀនដែលមានរយៈពេល៣ម៉ោងនេះ សមណសិស្ស និង សិក្ខាកាមនឹងបានទទួលការចេះដឹង :

- អំពីតម្លៃ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស តាមទស្សនៈវិជ្ជាខាងផ្នែកមនុស្សធម៌ និង ព្រះធម៌នៃពុទ្ធសាសនា ។

### ២. ឯកសារយោង :

- គម្ពីរអភិធម្មនៃព្រះត្រៃបិតក
- សិទ្ធិមនុស្សជាមូលដ្ឋានសំរាប់ធ្វើការហ្វឹកហ្វឺនព្រះសង្ឃ និពន្ធដោយ
  " ក្រុមកិច្ចការពិសេសផ្នែកសិទ្ធិមនុស្សនៅកម្ពុជា "

### ៣. សម្ភារៈសិក្សា

- ក្រដាសជ័រភ្លឺសម្រាប់បញ្ចាំង ( Transparency of overhead-projector )
- ក្រដាសផ្ទាំងសធំ និង ឧបករណ៍សរសេរ ( ហ្វឺត )
- ក្តារខៀន និង ដីស
- មេរៀនលាយលក្ខណ៍អក្សរ

### ៤. លំហាត់

- តើតម្លៃ និង សេចក្តីថ្លៃថ្នូររបស់មនុស្សសំដៅទៅលើអ្វី ?
- តើមនុស្សរាល់រូបមានធាតុអ្វីខ្លះ ?
- តើទស្សនៈមនុស្សធម៌ និង ទស្សនៈព្រះធម៌នៃព្រះពុទ្ធសាសនាមានចំណុចស្របគ្នាដែរឬទេ ? តើមានអ្វីខ្លះ?
- តើយសស័ក្តិ និង អំណាច អាចធ្វើឱ្យមនុស្សមានតម្លៃបានដែរឬទេ ?
- តើយើងត្រូវគោរពតម្លៃមនុស្សឱ្យបានស្មើៗគ្នាដែរឬទេ ? ព្រោះហេតុអ្វី ?

www.budinst.gov.kh www.elibraryofcambodia.org

## ៥. <u>មេរៀនទី ១:</u> តម្លៃ និង សេចក្ដីថ្លៃថ្នូររបស់មនុស្ស

---

### ក. <u>តាមទស្សនៈមនុស្សធម៌ (៥០នាទី)</u>

<u>មនុស្សក្នុងនាមជាបុគ្គលម្នាក់ៗ និង ក្នុងនាមជាសមាជិកសង្គម</u> :

- គ្រូបង្ហាត់ត្រូវធ្វើការពិចារណាដោយលើករឿងមួយ ឬ ពីរ :

ឧទាហរណ៍ : វាស់តម្លៃបុគ្គល ៣នាក់ ដែលមានទ្រព្យសម្បត្តិ ឬ បុណ្យសក្តិខុសគ្នា រួចហើយពិភាក្សាបំផុសគំនិត ។

- គ្រូបង្ហាត់ត្រូវធ្វើអត្ថាធិប្បាយបកស្រាយមេរៀនហើយពន្យល់ពាក្យសំខាន់ៗទាំងឡាយ ដែលសិក្ខាកាម និង សមណសិស្សពុំទាន់យល់ ។

---

សម្រាក ២០នាទី

---

### ខ. <u>តាមទស្សនៈព្រះពុទ្ធសាសនា (៨០នាទី)</u>

<u>មនុស្សក្នុងនាមជាបុគ្គលម្នាក់ៗ និង មនុស្សក្នុងនាមជាសមាជិកសង្គម</u>

- គ្រូបង្ហាត់ត្រូវឱ្យសមណសិស្ស ឬ សិក្ខាកាមម្នាក់អានមេរៀន ហើយចោទជាសំណួរដែលទាក់ទងទៅនឹងអត្ថបទ ។

- គ្រូបង្ហាត់ត្រូវឱ្យសមណសិស្ស និង សិក្ខាកាមប្រៀបធៀបទស្សនៈខាងមនុស្សធម៌ និង ព្រះធម៌នៃព្រះពុទ្ធសាសនាថា តើមានចំណុចណាខ្លះដែលស្របគ្នា និង ផ្ទុយគ្នាដោយគ្រូបង្ហាត់ត្រូវចែកសមណសិស្ស និងសិក្ខាកាមជាក្រុម រួចហើយឱ្យក្រុមនីមួយៗសរសេរចម្លើយលើផ្ទាំងក្រដាសសរួចឱ្យតំណាងក្រុមឡើងមករាយការណ៍ជូនក្រុមធំទាំងមូល ។ គ្រូបង្ហាត់ត្រូវបិទក្រដាសផ្ទាំងសទុកនៅក្នុងថ្នាក់រៀន ។

- សួរអ្នកឯកទេសមកពន្យល់បន្ថែម ។

---

www.budinst.gov.kh www.elibraryofcambodia.org

# <u>មេរៀនទី ១</u>

# តម្លៃ និង សេចក្ដីថ្លៃថ្នូររបស់មនុស្ស

## ក_ <u>តាមទស្សនៈមនុស្សធម៌</u> :

### *ក១_ <u>មនុស្សក្នុងនាមជាបុគ្គលម្នាក់ៗ</u>*

តម្លៃ និង សេចក្ដីថ្លៃថ្នូររបស់មនុស្សម្នាក់ៗពុំមែនសំដៅទៅលើទ្រព្យសម្បត្តិ អំណាច យសសក្ដិនោះទេ គឺមនុស្សម្នាក់ៗមានតម្លៃ និង សេចក្ដីថ្លៃថ្នូរដូចៗគ្នាទាំងអស់ ពីព្រោះមនុស្សរាល់រូបមានធាតុដូចគ្នា៣យ៉ាង ដូចជា :

ទី ១ : មាន<u>ជីវិត</u> និង តំរូវខ្លួនឯងដែលមនុស្សម្នាក់ៗត្រូវការមានមុនគេទាំងអស់ ដើម្បីរស់នៅក្នុងឋានៈជា<u>បុគ្គលម្នាក់ៗ</u> និង <u>ជាសហគមន៍មួយ</u> ។

ទី ២ : មាន<u>វិចារណញ្ញាណ</u>ដែលធ្វើឱ្យមនុស្សចេះគិតពិចារណាដឹងល្អ អាក្រក់ ដើម្បីកំណត់ជោគវាសនាអនាគតរបស់ខ្លួន ។

ទី ៣ : ការដែលរីកចំរើននៃមនុស្សម្នាក់ៗមិនមែនតែផ្លូវ<u>កាយ</u>ទេ គឺទាំងផ្លូវ<u>ចិត្តមនោសញ្ចេតនា</u> និង <u>បញ្ញា</u>ផងដែរ ។ ការរីកចំរើននៃវិស័យទាំងបីខាងលើ នឹងធ្វើឱ្យបុគ្គលនោះៗមានគំនិតធ្វើអ្វីមួយច្បាស់លាស់ ដើម្បីអោយខ្លួនឯងរីកចំរើនព្រមទាំងអ្នកដទៃផង ។

*<u>សេចក្ដីសន្និដ្ឋាន</u>* :

ដោយសារមនុស្សរាល់រូបមានធាតុដូចគ្នា៣យ៉ាងជាចាំបាច់ ដូច្នេះមនុស្សម្នាក់ៗគប្បីត្រូវបានទទួលនូវការគោរពស្មើៗគ្នា ដោយមិនគិតពីស្ថានភាពសង្គម សេដ្ឋកិច្ច ឬ នយោបាយឡើយ ។

### *ក២_ <u>មនុស្សក្នុងនាមជាសមាជិកសង្គម</u>*

មនុស្សរាល់រូបកើតមកក្នុងសង្គមតែងតែពឹងផ្អែកគ្នាទៅវិញទៅមកក្នុងការចិញ្ចឹមជីវិត និងអភិវឌ្ឍន៍ផ្សេងៗ ដូចជា បង្កបង្កើតជាគ្រួសារ ជាសហគមន៍ និង ជាតិសាសន៍មួយ ។ ដើម្បីកសាងជីវភាពត្រឹមត្រូវតាមសន្តិវិធី មនុស្សយើងម្នាក់ៗត្រូវចេះគោរពរាប់អានគ្នាជាបងប្អូន ហើយមានការទទួលខុសត្រូវទាំងអស់គ្នាក្នុងជីវិតរួម ។

*<u>ការសន្និដ្ឋាន</u>* :

ដោយមនុស្សម្នាក់ៗត្រូវការពឹងគ្នាទៅវិញទៅមកដើម្បីរស់នៅ ដូចនេះមនុស្សម្នាក់ៗត្រូវរួមកម្លាំងគ្នាទទួលខុសត្រូវទាំងអស់គ្នា ក្នុងឋានៈជាបុគ្គលម្នាក់ៗផង និង សមាជិកសហគមន៍ផង ដើម្បីអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច និង នយោបាយរបស់ខ្លួនអោយរីកចំរើន ។

www.budinst.gov.kh www.elibraryofcambodia.org

## ខ_ តាមទស្សនៈព្រះពុទ្ធសាសនា

### ខ១_ មនុស្សក្នុងនាមជាបុគ្គលម្នាក់ៗ

ព្រះពុទ្ធសាសនាឱ្យតម្លៃ និង សេចក្តីថ្លៃថ្នូរ ឬ តំលៃខ្លួនឯងរបស់មនុស្សស្មើៗគ្នា ។ ព្រះពុទ្ធតែងមានព្រះពុទ្ធដីកាថាមនុស្សយើងរាល់រូបកើតមកគ្មានយកអ្វីមកជាមួយ ហើយស្លាប់ទៅវិញក៏គ្មានយកអ្វីទៅជាមួយបានដែរ ។ ឧទាហរណ៍: នគបាល ឬ មន្ត្រីពន្ធនាគារត្រូវប្រតិបត្តិចំពោះអ្នកជាប់ឃុំ ឬ ទណ្ឌិតដោយសេចក្តីគោរព និង សេចក្តីថ្លៃថ្នូររបស់មនុស្ស ។ ទ្រព្យសម្បត្តិ អំណាច និង យសសក្តិជាវត្ថុមិនស្ថិតស្ថេរ " អនិច្ចំ " ហើយមិនមែនជារបស់ខ្លួន " អនត្តា " រួមទាំងរូបកាយរបស់យើងផង ។ ព្រះអង្គទ្រង់ចាត់ទុកវត្ថុដែលមានជីវិតជាបីផ្នែកគឺ:

- វត្ថុដែលមានជីវិតហៅថា រុក្ខជាតិ
- សត្វមានជីវិត ដែលគ្មានវិចារណញ្ញាណហៅថា សត្វតិរច្ឆាន ។
- សត្វមានជីវិត ដែលមានវិចារណញ្ញាណហៅថា សត្វលោក គឺមនុស្សនេះឯង ។

### ខ២_ មនុស្សក្នុងនាមជាសមាជិកសង្គម :

មនុស្សរាល់រូបកើតមកក្នុងសង្គមត្រូវការពឹងពាក់គ្នាទៅវិញទៅមក ដើម្បីបង្កបង្កើតជាសង្គមគ្រួសារ ឬ ជាតិមួយ ។ ពីព្រោះការកសាងសង្គមត្រូវពឹងផ្អែកទៅលើអំពើត្រឹមត្រូវនៃបុគ្គលម្នាក់ៗផងដែរ ដូចជាព្រះពុទ្ធបានចែងក្នុងទស្សនវិជ្ជា " កម្ម " " ផល " " ទុក្ខ ", " សុខ " និង អរិយសច្ចៈទាំង ៤ ដូចមានពណ៌នានៅមេរៀនខាងក្រោយ ។ បើសិនមានបុគ្គលណាមួយប្រព្រឹត្តអំពើអាក្រក់គុណសម្បត្តិខាងសីលធម៌នៃបុគ្គលនោះត្រូវរងនូវការអាប់ឱន ហើយ អាចបណ្តាលឱ្យអាប់ឱនដល់សមាជិកនៃសង្គមឯទៀតៗផងដែរ ។ ព្រះអង្គបានបញ្ញត្តិថាទោះជាមនុស្សម្នាក់ៗមានវណ្ណៈជាព្រាហ្មណ៍, ក្សត្រ, វេស្ស, សុទ្រៈ យ៉ាងណាក៏ដោយ កាលណាចូលរួមក្នុងសង្គមសង្ឃហើយ ត្រូវតែបដិបត្តិធម៌ដូចៗគ្នា ។

<u>ឧទាហរណ៍</u> : ព្រះពុទ្ធបានប្រៀបធៀបបុគ្គលម្នាក់ៗទៅនឹងស្ទឹង ឬ ទន្លេ ហើយសង្គមទៅជាសមុទ្ទ ។ កាលណាស្ទឹង ឬ ទន្លេទាំងនោះហូរធ្លាក់ទៅក្នុងសមុទ្ទ ទឹកទាំងឡាយត្រូវប្រែក្លាយមានជាតិប្រៃទាំងអស់ បានសេចក្តីថា កាលណាមនុស្សយើងម្នាក់ៗរស់នៅក្នុងសង្គម ឬ ក្នុងសាសនារបស់ព្រះអង្គ មនុស្សទាំងនោះត្រូវមានភាពស្មើៗគ្នាទទួលការខុសត្រូវចំពោះមុខច្បាប់ ឬ បដិបត្តិធម៌ និង រួមកម្លាំងគ្នាដើម្បីកសាងសង្គមទាំងនោះ។

❖ <u>ការត្រិះរិះ</u> :

តាមទស្សនមនុស្សធម៌ និង ទស្សនៈព្រះធម៌នៃព្រះពុទ្ធសាសនា តម្លៃ និង សេចក្តីថ្លៃថ្នូរ ឬ តំលៃខ្លួនឯងរបស់មនុស្សពុំមែនសំដៅទៅលើទ្រព្យសម្បត្តិ អំណាច និង យសសក្តិនោះទេ ក៏ប៉ុន្តែសំដៅទៅលើមនុស្សរាល់រូបដែលកើតមកមានភាពស្មើគ្នាជាប់មកជាមួយស្រាប់។

www.budinst.gov.kh www.elibraryofcambodia.org

# កម្មវិធីមុខវិជ្ជាសំរាប់គ្រូបង្ហាត់នៃមេរៀនទី ២

*********

## ការវិវត្តន៍បទដ្ឋានសិទ្ធិមនុស្សជាសកល

### ១. គោលដៅ :

នៅចុងបញ្ចប់នៃមេរៀននេះ សមណសិស្ស និង សិក្ខាកាមអាចយល់ដឹង :

- ប្រវត្តិនៃសិទ្ធិមនុស្ស
- សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស

### ២. ឯកសារយោង :

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស

### ៣. សម្ភារៈសិក្សា

- ក្រដាសជ័រភ្លឺសម្រាប់បញ្ចាំង ( បើសិនមាន )
- ក្រដាសផ្ទាំងស និង ឧបករណ៍សរសេរ
- ក្តារខៀន និង ដីស ( បើចាំបាច់ )
- មេរៀនលាយលក្ខណ៍អក្សរ

### ៤. លំហាត់

១. តើគំនិតដែលទាក់ទងនឹងសិទ្ធិមនុស្សមានការលូតលាស់យ៉ាងដូចម្តេចដែរ ?

២. ហេតុដូចម្តេចបានជាការលូតលាស់នៃសិទ្ធិមនុស្សនាំទំរង់ទៅរកសេរីភាពពីការសង្កត់សង្កិន និង បញ្ជាក់នូវជីវិតប្រជាធិបតេយ្យ ?

៣. តើសេចក្តីប្រកាសជាសកលនៃសិទ្ធិមនុស្សមានសារៈសំខាន់យ៉ាងដូចម្តេច ?

www.budinst.gov.kh www.elibraryofcambodia.org

## ៥_ មេរៀនទី ២ : ការទទួលស្គាល់បទដ្ឋានសិទ្ធិមនុស្សជាសកល

---

### ក_ បទដ្ឋាននៃសិទ្ធិមនុស្ស ( ៤០នាទី )

#### ក១_ *សិទ្ធិមនុស្សពីបុរាណ*

- គ្រូបង្ហាត់ត្រូវអាន ហើយអធិប្បាយពីកំណែកមេរៀន ដោយមានពន្យល់ពាក្យខ្លះៗដែលសមណសិស្ស ឬ សិក្ខាកាមពុំយល់ ឬ ចោទជាសំណួរ រួចហើយគ្រូត្រូវពិភាក្សាបំផុសគំនិតលើចំណុចនៃទស្សនៈព្រះពុទ្ធសាសនាផ្សេងៗទៀត ដែលមានទំនាក់ទំនងនឹងសិទ្ធិមនុស្សដោយឱ្យសមណសិស្ស និង សិក្ខាកាមបញ្ចេញយោបល់ ហើយកត់ត្រាទុកលើក្ដារខៀន ឬ ក្រដាសផ្ទាំងសន្លឹកចម្លើយទាំងនោះសំរាប់បិទទុកក្នុងថ្នាក់ ។

#### ក២_ *ប្រវត្តិសាស្ត្រនៃសិទ្ធិមនុស្សចាប់ពីសតវត្សរ៍ទី ១៧ ( ៤០នាទី )*

គ្រូបង្ហាត់ត្រូវអាន ហើយអធិប្បាយពីកំណែកមេរៀន ។ គ្រូបង្រៀនត្រូវពន្យល់ ជាពិសេសនូវចំណុច « ទស្សនៈរបស់ទស្សនវិទូ ចុន ឡក់ ( John Lock ) » « បដិវត្តបារាំង » និង « បដិវត្តអាមេរិកាំង » ។

---

**សម្រាក ២០នាទី**

---

#### ក៣_ *សេចក្ដីប្រកាសជាសកលស្ដីអំពីសិទ្ធិមនុស្ស ( ៤០នាទី )*

- គ្រូបង្ហាត់ត្រូវអាន ហើយធ្វើអធិប្បាយពីកំណែកមេរៀន ។ នៅពេលធ្វើអធិប្បាយលើសេចក្ដីប្រកាសជាសកលស្ដីអំពីសិទ្ធិមនុស្ស គ្រូត្រូវប្រើក្រដាសធំភ្ជាប់បញ្ជាំងលើផ្ទាំងសំពត់ស នូវមាត្រា និង រូបភាពខ្លះៗ ( បើសិនជាមាន ) ។
- បើអាចធ្វើបាន គួរអញ្ជើញអ្នកឯកទេសមកពន្យល់បន្ថែម

---

www.budinst.gov.kh www.elibraryofcambodia.org

# មេរៀនទី ២

# ការវិវត្តន៍នៃបទដ្ឋានសិទ្ធិមនុស្សជាសកល

## ក_ បទដ្ឋាននៃសិទ្ធិមនុស្ស

### ក១_ សិទ្ធិមនុស្សពីបុរាណ

យោលតាមព្រះធម៌នៃព្រះពុទ្ធសាសនា និង សាសនានានា ក្នុងពិភពលោកមាន : គ្រិស្តសាសនា, អ៊ីស្លាម, ហិណ្ឌូ និង សាសនាចិន សិទ្ធិមនុស្សមានតាំងពីពេលកកើតនៃសាសនានោះមកម្លេះ គ្រាន់តែគេអធិប្បាយរបៀបផ្សេងៗគ្នា ក៏ប៉ុន្តែក្នុងគោលបំណងតែមួយ ដូចជា :

- សិទ្ធិមានជីវិតរស់នៅ_ព្រះពុទ្ធសាសនាថែងថា " បាណាតិបាតា = មិនឱ្យសម្លាប់សត្វ " ។
- គ្រិស្តសាសនា " ស្រលាញ់អ្នកជិតខាងដូចខ្លួនឯង " ។
- ទស្សនវិទូចិន " កុំធ្វើទៅអ្នកដទៃនូវអ្វីដែលអ្នកមិនចង់ឱ្យគេធ្វើចំពោះខ្លួនអ្នក " ។
- សាសនាអ៊ីស្លាមមហាម៉ាត់ប្រកាសថា " មនុស្សទាំងអស់ស្មើគ្នាដូចធ្មេញនៃក្រាស់សិតសក់ " ។
- សាសនាហិណ្ឌូ " ធម៌សំរាប់អោយមនុស្សម្នាក់ៗអនុវត្តហើយធ្វើតាម ពីព្រោះធម៌គឺជារបស់ដែលអ្នកទាំងនោះកំណត់ " ។

### ក២_ ប្រវត្តិសាស្ត្រនៃសិទ្ធិមនុស្សចាប់ពីសតវត្សរ៍ទី ១៧

នៅសតវត្សទី ១៧ និង ១៨ ទស្សនវិជ្ជាសេរីនៅក្នុងពិភពលោកបានចាប់ផ្តើមគិតផ្សេងអំពីពិភពលោក និង ការដោះស្រាយបញ្ហានៅក្នុងពិភពលោក ។ ទស្សនវិទូរអង់គ្លេសឈ្មោះ ជ្យន ឡុក ( John Locke ) បានបញ្ចេញទស្សនវិជ្ជាខាងផ្នែកសិទ្ធិមនុស្ស ៣ គឺ : សិទ្ធិមានជីវិតរស់នៅ ១, សេរីភាព ១ និងកម្មសិទ្ធិ ១។ ទស្សនៈនៃជ្យន ឡុក និង ទស្សនវិទូរផ្សេងៗទៀតបានជំរុញឱ្យប្រជាពលរដ្ឋអាមេរិកកាំង និង ការបដិវត្តន៍ប្រទេសបារាំងក្នុងសតវត្សទី ១៨ ក្រោកឡើងប្រឆាំងនឹងការរំលោភ និង ការប្រើអំណាចខុសច្បាប់របស់អ្នកដឹកនាំ ។ នៅថ្ងៃទី ២៦ ខែ សីហា ១៧៨៩ រដ្ឋសភានៃប្រទេសបារាំងបានប្រកាសចេញឯកសារមួយដ៏សំខាន់សំរាប់សិទ្ធិមនុស្សគឺ សេចក្តីប្រកាសនៃសិទ្ធិរបស់មនុស្ស និង ពលរដ្ឋ ។ នៅចុងសតវត្សទី ១៨ បដិវត្តន៍អាមេរិកកាំងបានទៀមទាសេរីភាពពីការសង្កត់សង្កិនដែលបណ្តាលឱ្យមានរដ្ឋធម្មនុញ្ញអាមេរិកកាំង និងច្បាប់នៃសិទ្ធិ "ការធ្វើវិសោធនកម្ម ១០៨ លើកទីមួយនៃរដ្ឋធម្មនុញ្ញ" ។ រដ្ឋធម្មនុញ្ញអាមេរិកកាំង និង ច្បាប់នៃសិទ្ធិក៏បានបង្កើតនូវមូលដ្ឋាននៃសិទ្ធិមនុស្សផងដែរ ។

### ក៣_ សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស

អង្គការសហប្រជាជាតិ ( គឺជាអង្គការអន្តរជាតិ និង អន្តររដ្ឋាភិបាលមួយដែលសព្វថ្ងៃមានរដ្ឋ ឬ ប្រទេសជាសមាជិកចំនួន ១៨៥ក្នុងនោះរួមទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ )បានកើតឡើងនៅក្រោយសង្គ្រាមលោកលើកទី ២ បន្ទាប់ពីឃើញវិនាសកម្មដ៏ធំធេងមក ។ ក្រុមណាហ្ស៊ីស(Nazis)ធ្វើការប្រល័យពូជសាសន៍

www.budinst.gov.kh www.elibraryofcambodia.org

ដល់ជនជាតិជ្វីស (Jews), ហ្ស៊ីពស៊ី ( Gypsies ) និង ជនជាតិភាគតិចទៀត ។ សង្គ្រាមលោកលើកទី២ខ្លួនឯងក៏បានធ្វើឱ្យមនុស្សរាប់លាននាក់បាត់បង់ជីវិត និង បាត់បង់សេរីភាព ។ ចំពោះវិនាសកម្មដ៏ធំធេងនេះ ប្រទេសទាំងឡាយនៅក្នុងពិភពលោករិះរកមធ្យោបាយដើម្បីរកមាគ៌ាទប់ស្កាត់កុំឱ្យវិនាសកម្មនេះកើតមានជាថ្មីម្តងទៀត ។

នៅថ្ងៃទី ៩ ខែ ធ្នូ ១៩៤៨ អង្គការសហប្រជាជាតិបានអនុម័តអនុសញ្ញាស្តីពីការការពារ និងការដាក់ទណ្ឌកម្មនៃការប្រល័យពូជសាសន៍ ដើម្បីចាត់ទុកជាអំពើខុសច្បាប់ចំពោះការប្រល័យពូជសាសន៍ ។

នៅថ្ងៃទី ១០ ធ្នូ១៩៤៨មហាសន្និបាតនៃអង្គការសហប្រជាជាតិបានអនុម័តនូវឯកសារដ៏សំខាន់មួយនៃសតវត្សទី២០ គឺសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ( សូមមើលឯកសារសេចក្តីប្រកាសជាសកល )ដែលទទួលស្គាល់ថាសេចក្តីថ្លៃថ្នូរ និង សិទ្ធិស្មើភាពនៃមនុស្សលោក ជាមូលដ្ឋានគ្រឹះនៃសេរីភាពយុត្តិធម៌ និងសន្តិភាពនៅលើពិភពលោក ។ សេចក្តីប្រកាសនេះក៏បញ្ជាក់ផងដែរនូវសិទ្ធិរស់រានមានជីវិត និង សមភាព ( សេចក្តីមិនស្មើគ្រប់រូបភាពត្រូវបានហាមឃាត់ ) សេរីភាពបញ្ចេញមតិ និង សេរីភាពនៃជំនឿ សិទ្ធិគ្មានមនុស្សណាម្នាក់អាចត្រូវគេទុកជាទាសករ ឬ ត្រូវគេធ្វើបាប ធ្វើទារុណកម្មឃោរឃៅ និង អមនុស្សធម៌. ដាក់ទណ្ឌកម្ម ឬទទួលអំពើបន្ថោកបន្ទាបទេ ។ សេចក្តីប្រកាសនេះក៏បានបញ្ជាក់ផងដែរនូវឧត្តមគតិនៃប្រជាធិបតេយ្យមួយដ៏ល្អឥតខ្ចោះដែលពលរដ្ឋម្នាក់ៗមានសិទ្ធិចូលរួមធ្វើនយោបាយក្នុង ប្រទេសរបស់ខ្លួន ។ សេចក្តីប្រកាសពុំមែនត្រូវគេទុកជាច្បាប់អន្តរជាតិនៃសិទ្ធិមនុស្សទេ ក៏ប៉ុន្តែសមាជិកនៃអង្គការសហប្រជាជាតិទាំងអស់ រួមមានទាំងព្រះរាជាណាចក្រកម្ពុជាផងត្រូវតែទទួលស្គាល់ និង គោរពតាម ។

## ❖ *សេចក្តីបញ្ជាក់*

ចំពោះច្បាប់សិទ្ធិមនុស្សអន្តរជាតិ យើងនឹងលើកទៅពណ៌នានៅក្នុងមេរៀនទី ៥ បន្ថែមទៀត ។

## ❖ *ការត្រិះរិះ*

ការវិវត្តន៍ខាងលើ គោលការណ៍នៃសិទ្ធិមនុស្សនេះកើតចេញពីគំនិតទស្សនវិទូ ទ្រឹស្តីសាសនា នានា និង ប្រទេសជាសមាជិកនៃអង្គការសហប្រជាជាតិជាច្រើន ដែលបានចងក្រងហើយអនុម័តជាសេចក្តីប្រកាសសកលស្តីអំពីសិទ្ធិមនុស្ស ។ ធ្វើដូចនេះ អង្គការសហប្រជាជាតិទទួលស្គាល់ថា សិទ្ធិមនុស្សឆ្លងដែននៃប្រទេសជាសមាជិក. ប្រព័ន្ធនយោបាយ. វប្បធម៌ និង សាសនា ។ រដ្ឋាភិបាលដែលតំណាងនៃប្រទេសជាសមាជិករបស់អង្គការសហ-ប្រជាជាតិ ត្រូវតែគោរពសិទ្ធិប្រជាពលរដ្ឋក្នុងអធិបតេយ្យភាពរបស់ខ្លួន ។

www.budinst.gov.kh www.elibraryofcambodia.org

# កម្មវិធីមុខវិជ្ជាសំរាប់គ្រូបង្ហាត់នៃមេរៀនទី ៣

********

## តើសិទ្ធិមនុស្សជាអ្វី ?

### ១. គោលដៅ :

នៅចុងបញ្ចប់នៃមេរៀននេះ សមណសិស្ស និង សិក្ខាកាមអាចយល់ដឹង :

- អំពីនិយមន័យនៃសិទ្ធិមនុស្ស
- ការបែងចែកសិទ្ធិមនុស្ស
- សិទ្ធិខាងជំនឿហើយនឹងច្បាប់ និង បទដ្ឋានធានាផែលបានធានា និង ការពារនៃសិទ្ធិទាំងនេះ ។

### ២. ឯកសារយោង :

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស
- កតិកាសញ្ញាស្តីអំពីសិទ្ធិពលរដ្ឋ និង នយោបាយ
- សេចក្តីថ្លែងការណ៍ស្តីអំពីការបំបាត់រាល់ទំរង់នៃការមិនអនុគ្រោះ និងការរើសអើងខាងវិស័យសាសនា ឬ ជំនឿ ។

### ៣. សម្ភារះសិក្សា

- ក្រដាសធំរភ្ជិសំរាប់បញ្ចាំងលើផ្ទាំងក្រណាត់ស
- ក្តារខៀន និង ដីស
- ក្រដាសសផ្ទាំងធំ និង ឧបករណ៍សរសេរ
- មេរៀនលោយលក្ខណ៍អក្សរ

### ៤. លំហាត់

- តើសិទ្ធិខាងផ្លូវច្បាប់ និង សិទ្ធិខាងសីលធម៌ខុសគ្នាយ៉ាងដូចម្តេច ?
- ដើម្បីឲ្យសិទ្ធិមនុស្សមានលើនឹង តើត្រូវមានអ្វីទៀត ?
- តើសិទ្ធិមនុស្សចែកជាប៉ុន្មានផ្នែកអ្វីខ្លះ ?
- តើព្រះសង្ឃមានសេរីភាពក្នុងការសរសេរ ការចេញផ្សាយ និង ការចែកចាយឯកសារផ្ទាល់ព្រះអង្គ ឬទេ ?

www.budinst.gov.kh www.elibraryofcambodia.org

## ៥_ មេរៀនទី ៣ : តើសិទ្ធិមនុស្សជាអ្វី ?

### ១_ និយមន័យអំពីសិទ្ធិ និង សិទ្ធិមនុស្សហើយនិងអត្ថន័យរបស់វា ( ៤០នាទី )

គ្រូត្រូវណែនាំឱ្យសិក្ខាកាម និង សមណសិស្សពិភាក្សាបំផុសគំនិតអំពីនិយមន័យនៃសិទ្ធិ និង អត្ថន័យនៃសិទ្ធិ_មនុស្ស ដោយឱ្យសិក្ខាកាម ឬ សមណសិស្សម្នាក់ៗបញ្ចេញយោបល់រៀងៗខ្លួន ហើយគ្រូបង្គោលត្រូវកត់ត្រាទុកលើក្ដារខៀន ឬ ក្រដាសសន្លឹកធំ ។ បន្ទាប់មកគ្រូបង្គោលត្រូវប្រមូលយោបល់ទាំងនោះមកសរុបជាអត្ថន័យរួមមួយដែលមានដូចក្នុងមេរៀន រួចហើយគ្រូបង្គោលត្រូវអាន និង ធ្វើអត្ថាធិប្បាយពីកញែកបន្ថែមទៀត ។ គ្រូបង្គោលត្រូវបិទក្រដាសសន្លឹកធំនៅក្នុងថ្នាក់រៀន។

### ២_ សិទ្ធិ និង ការទទួលខុសត្រូវ ( ៤០នាទី )

- គ្រូបង្គោលត្រូវចោទជាសំណួរថា តើសិទ្ធិ និង ការទទួលខុសត្រូវៗមានតុល្យភាពយ៉ាងដូចម្ដេច រួចហើយឱ្យសមណសិស្ស និងសិក្ខាកាមលើកជាឧទាហរណ៍ ២ឬ៣ ។ បន្ទាប់មកគ្រូបង្គោលអាចលើកយកឧទាហរណ៍បន្ថែមដូចជា : « ខ្ញុំមានសិទ្ធិបោះឆ្នោតបើសតំណាងរាស្ត្រ តែខ្ញុំក៏មានការទទួលខុសត្រូវ ជ្រើសរើសតំណាងរាស្ត្រដែលមានគុណសម្បត្តិ និងសមត្ថភាពដែរ » « ខ្ញុំមានសិទ្ធិធ្វើបេក្ខជនតំណាងរាស្ត្រ តែបើកាលណាជាប់ឆ្នោតតំណាងរាស្ត្រ ខ្ញុំត្រូវតែធ្វើច្បាប់ដើម្បីការពារផលប្រយោជន៍រាស្ត្រ » « ខ្ញុំជាអាជ្ញាធរមានសិទ្ធិចាប់ចង តែខ្ញុំក៏ត្រូវមានការទទួលខុសត្រូវចំពោះមុខច្បាប់នូវការចាប់ចងនោះឱ្យបានសមស្របត្រឹមត្រូវ » ។ ទីបញ្ចប់គ្រូត្រូវអោយសិស្សលើកជាឧទាហរណ៍ខ្លីៗបន្ថែមទៀត ដូចជាមនុស្សម្នាក់ជាចោរលួចទោចក្រយានយន្តដែលជាហេតុនាំអោយតុលាការឯករាជ្យរកឃើញកំហុស ហើយដាក់ទណ្ឌកម្ម និងឧទាហរណ៍ខ្លីមួយទៀត មន្ត្រីពន្ធនាគារម្នាក់បំពានអំណាចរបស់ខ្លួនលួចរួមគំនិត ឬ ប្រព្រឹត្តផ្ទាល់ក្នុងការធ្វើទារុណកម្មវាយដំចំពោះអ្នកជាប់ឃុំឃាំង ឬ ទណ្ឌិតដែលជាហេតុនាំអោយតុលាការឯករាជ្យរកឃើញកំហុស និងដាក់ទណ្ឌកម្ម ។

---

សម្រាក ២០នាទី

---

### ៣_ ការបែងចែកសិទ្ធិមនុស្ស ( ៣០នាទី )

- គ្រូបង្គោលត្រូវចែកសមណសិស្ស និង សិក្ខាកាមជាក្រុមពិភាក្សា រួចហើយឱ្យក្រុមនីមួយៗស្រង់សិទ្ធិទាំងឡាយដែលមាននៅក្នុងក្រដាសជំរុំភ្លឺ ឬ លើក្ដារខៀនដោយឱ្យដាក់តាមផ្នែកនីមួយៗរបស់វា ។ បន្ទាប់មកតំណាងក្រុមនីមួយៗឡើងមករាយការណ៍ជូនវត្តមានទាំងមូល ។

- គ្រូបង្គោលត្រូវសម្របសម្រួលឱ្យចេញជាលទ្ធផលត្រឹមត្រូវតាមមេរៀន ព្រមទាំងពន្យល់នូវការចំណាត់ថ្នាក់តាមផ្នែកនីមួយៗផង ។

- គ្រូត្រូវបញ្ជាក់ផងដែរថា សិទ្ធិនីមួយៗមានការទាក់ទងគ្នាទៅវិញទៅមក ។

## ៤_ ការរៀបចំសិទ្ធិ (១០នាទី)

គ្រូបង្គាត់ត្រូវអាន ហើយពិភាក្សាបំភ្លែកឃើសិទ្ធិខាងផ្លូវច្បាប់ និង សិទ្ធិខាងសីលធម៌ ។

## ៥_ សិទ្ធិខាងជំនឿ (៤០នាទី)

_ គ្រូបង្គាត់ត្រូវណែនាំពិភាក្សាបំផុសគំនិតថា តើសេរីភាពខាងសាសនាអាចជួយអ្វីខ្លះដល់សហគមន៍ ? តើសេរីភាពដែលស្របតាមលក្ខណៈច្បាប់មានអ្វីខ្លះ ? តើច្បាប់ក្នុងស្រុករបស់ព្រះរាជាណាចក្រកម្ពុជា និង ច្បាប់អន្តរជាតិណាខ្លះដែលជួយលើកតម្កើង និង ការពារសិទ្ធិខាងជំនឿនេះ ? ។

_ គួររកអ្នកឯកទេសមកពន្យល់បន្ថែម ។

www.budinst.gov.kh www.elibraryofcambodia.org

# មេរៀនទី ៣
# តើសិទ្ធិមនុស្សជាអ្វី ?

## ១_ តើសិទ្ធិជាអ្វី ?

សិទ្ធិគឺជាការទាមទារ ឬ ក៏ជាការប្រគល់អំណាចអ្វីមួយ ដែលបុគ្គលម្នាក់ៗជឿថាគេត្រូវតែមាន ឬ គេនឹងត្រូវតែមាន ។ តាមវចនានុក្រមខ្មែរ សិទ្ធិ គឺ អំណាច ( អ្វីដែលអាចមាន ) ។ ប្រសិនបើសិទ្ធិនោះបង្កើតឡើងដោយច្បាប់គេហៅថា សិទ្ធិតាមច្បាប់ ។ សិទ្ធិតាមផ្លូវច្បាប់សំដៅទៅលើផលប្រយោជន៍ដែលត្រូវបានការពារដោយសង្គមតាមរយៈច្បាប់ និង ស្ថាប័ននានាដូចជា តុលាការ និង នគរបាលជាដើម ។ មានសិទ្ធិមួយជំពូកទៀតផងដែរ ដែលគេទទួលស្គាល់ថាជាសិទ្ធិ ខាងផ្លូវសីលធម៌ ។ សិទ្ធិសីលធម៌នេះ គឺជាសិទ្ធិដែលប្រជាពលរដ្ឋរៀនចេះដឹងនៅក្នុងបរិបទនៃសង្គម និង វប្បធម៌របស់គេ ឧទាហរណ៍ដូចជាការគោរពអ្នកដទៃ ការគួរសម និង សេចក្ដីទៀងត្រង់ ។

## ២_ តើសិទ្ធិមនុស្សជាអ្វី ?

សិទ្ធិមនុស្សសំដៅលើវត្ថុទាំងឡាយដែលមានសារៈសំខាន់ចំពោះមនុស្សលោក ដូចជាមានជីវិតរស់នៅ ( សិទ្ធិមានជីវិត ) ចៀសវាងការឈឺចាប់ ( សិទ្ធិអោយគេប្រព្រឹត្តចំពោះខ្លួននូវអំពើមនុស្សធម៌ ) ការប្រព្រឹត្តចំពោះខ្លួនដោយស្មើភាពគ្នាដើម្បីរស់នៅក្នុងសហគមន៍ ( គ្មានជនណាម្នាក់ត្រូវគេបំបែកចេញដោយឡែក ឬ ប្រព្រឹត្តអំពើរើសអើង ) ។ គំនិតនៃសេចក្ដីថ្លៃថ្នូររបស់មនុស្សត្រូវលើកយកមកប្រើ កាលណាគេពន្យល់អំពីសិទ្ធិមនុស្សសេចក្ដីថ្លៃថ្នូរគឺ ជាតំលៃខ្លួនឯងនៃរូបបុគ្គលម្នាក់ៗ ឬ បុគ្គលគ្រប់រូបដែលកើតមកមានសេចក្ដីថ្លៃថ្នូរស្មើៗគ្នា ។ ហេតុដូច្នេះសេចក្ដីថ្លៃថ្នូររបស់រូបបុគ្គលម្នាក់ៗមិនអាចកាត់បន្ថយ ឬ ដកហូតបានឡើយ ។

គទៅនេះគឺជានិយមន័យទូទៅទាំងពីររបស់សិទ្ធិមនុស្ស :

១_ ការប្រព្រឹត្តចំពោះមនុស្សរាល់រូបដោយសេចក្ដីគោរព និង សេចក្ដីថ្លៃថ្នូរ និង

២_ ការផ្ដល់នូវតំលៃ និង សេចក្ដីថ្លៃថ្នូររបស់មនុស្សម្នាក់ៗ ។

នៅក្នុងនិយមន័យទីមួយ ពាក្យថា " មនុស្សរាល់រូប " គឺសំដៅទៅលើបុរស ស្ត្រី កុមារ អ្នកជាប់ឃុំឃាំងទណ្ឌិត ប្រជាពលរដ្ឋដែលកាន់សាសនានានា ក្រុមជនជាតិភាគតិចទាំងឡាយដូចជា ជនជាតិភាគតិចចិន និងវៀតណាមអ្នកទីទ័លក្រ និង សមាជិកនៃគណៈបក្សនយោបាយនានា ។

## ៣_ សិទ្ធិ និង ការទទួលខុសត្រូវ

សិទ្ធិមានលំនឹងបាន ក៏ដោយសារតែមានការទទួលខុសត្រូវផងដែរ ។ ឧទាហរណ៍បើសិនជាយើងចង់ឱ្យមានសុវត្ថិ_ភាពដល់ខ្លួនយើង ដូចនេះយើងក៏ត្រូវមានការទទួលខុសត្រូវផងដែរ ដោយមិនឱ្យរំលោភទៅលើសុវត្ថិភាពរូបរាងកាយរបស់អ្នកដទៃឡើយ ។

ជាឧទាហរណ៍ដូចជា ការមិនទទួលខុសត្រូវរបស់មនុស្សម្នាក់ជាចោរលួចទោចក្រយានយន្ត ដែលជាហេតុនាំឱ្យតុលាការឯករាជ្យរកឃើញកំហុសហើយដាក់ទណ្ឌកម្ម ។ ជាឧទាហរណ៍មួយទៀតដូចជា មន្ត្រីពន្ធនាគារម្នាក់បំពានអំណាចរបស់

www.budinst.gov.kh www.elibraryofcambodia.org

ខ្លួនដោយរូបគំនិត ឬ ប្រព្រឹត្តផ្ទាល់ក្នុងការធ្វើទារុណកម្មវាយដំចំពោះអ្នកជាប់ឃុំឃាំង ឬ ទណ្ឌិត ដែលជាហេតុនាំឱ្យតុលាការឯករាជ្យរកឃើញកំហុសហើយដាក់ទណ្ឌកម្ម ។

យោងទៅតាមព្រះធម៌នៃព្រះពុទ្ធសាសនា គុណសម្បត្តិខាងសីលធម៌នៃបុគ្គលជាចោរ និង បុគ្គលជាមន្ត្រីពន្ធនាគារ ទាំងពីរត្រូវរងការរលាប់ឱន ពីព្រោះអំពើអាក្រក់របស់ខ្លួន ។

## ៤_ ការបែងចែកសិទ្ធិមនុស្ស

តាមទម្លាប់សិទ្ធិមនុស្សចែកចេញជាប្រាំមួយផ្នែកដូចតទៅ :

ក_ សិទ្ធិពលរដ្ឋ : ទាក់ទងទៅនឹងការការពារ និង ការរស់នៅរបស់បុគ្គល ។

ខ_ សិទ្ធិនយោបាយ : ទាក់ទងទៅនឹងការរួមចំណែកក្នុងរដ្ឋាភិបាល និង ក្នុងសង្គម ។

គ_ សិទ្ធិសេដ្ឋកិច្ច : ទាក់ទងទៅនឹងទ្រព្យសម្បត្តិ, សន្តិសុខ និង សុខុមាលភាព ។

ឃ_ សិទ្ធិសង្គម : ទាក់ទងទៅនឹងសិទ្ធិនៃការទាក់ទងគ្នា ។

ង_ សិទ្ធិវប្បធម៌ : ការសម្តែងមនោសញ្ចេតនាខាងផ្នែកវប្បធម៌តាមលក្ខណៈទម្រង់ទ្រាយច្រើនយ៉ាងរបស់វា ។ អប់រំផ្សព្វផ្សាយរក្សាសិទ្ធិ ទទួលនិងអាស្រ័យផលវប្បធម៌

ច_ សិទ្ធិនៃពិភពលោក : ទាក់ទងទៅនឹងប្រជាជនពិភពលោកដូចជាសិទ្ធិមានសេរីភាព ការអភិវឌ្ឍន៍ និង បរិស្ថាន ។

ទម្រង់ទ្រាយច្រើនយ៉ាងនៃសិទ្ធិទាំងនោះ គឺជួយដល់ការបែងចែកនៃសិទ្ធិមនុស្ស ហើយនិង ជួយរាយស្គាល់នូវសិទ្ធិដែលអាចត្រូវប្រតិបត្តិដោយផ្ទាល់នៅចំពោះមុខតុលាការ ( ដូចជាចំណុច ក. ខ ) ហើយនិង សិទ្ធិដែលត្រូវការប្រព្រឹត្តកម្មក្នុងរយៈពេលយូរដោយរាជរដ្ឋាភិបាល ( ដូចជាចំណុច គ. ឃ. ង ) ឬ ដោយសហគមអន្តរជាតិ ( ចំណុច ច ) ។ ទោះជាយ៉ាងណាក៏ដោយ សិទ្ធិទាំងនោះមិនអាចផ្តាច់ចេញពីគ្នាទេ គឺមានការពឹងផ្អែកគ្នាទៅវិញទៅមក ។

## ៥_ សេរីភាពខាងជំនឿដែលជាសិទ្ធិពលរដ្ឋ និង សិទ្ធិសង្គមកិច្ច:

ប្រទេសទាំងឡាយ ត្រូវតែធានា និង គោរពសេរីភាពខាងជំនឿឱ្យបានពេញលេញ ។ ប្រជាពលរដ្ឋនីមួយៗមានសេរីភាពក្នុងការប្រកាន់យកសាសនាមួយតាមការជ្រើសរើសរបស់ខ្លួន និង ប្រតិបត្តិតាមសាសនានោះ ។ ការយល់ចិត្ត ហើយនិងការយោគយល់ចំពោះសាសនាផ្សេងៗទៀត គឺជាសារៈសំខាន់ក្នុងការលើកតម្កើងសេរីភាពនៃជំនឿសាសនា (1)។ បើសិនណាជាគ្មានការយោគយល់គ្នាទេ ប្រទេសទាំងឡាយត្រូវមានវិធានការទប់ទល់ដើម្បីបំបាត់ការមិនយោគយល់នោះ ជាកិច្ចការពារប្រជាពលរដ្ឋនៃសាសនានានា និង ប្រឆាំងគ្រប់រូបភាពនៃការរើសអើង ។ សេរីភាពខាងសាសនាអាចជួយធ្វើឱ្យមានសន្តិភាពពិភពលោក យុត្តិធម៌សង្គម និង មិត្តភាពរវាងប្រជាពលរដ្ឋក្នុងពិភពលោកដែលយើងប្រាថ្នា ។

ខាងក្រោមនេះគឺជាច្បាប់ខ្មែរដែលទាក់ទងទៅនឹងសិទ្ធិខាងសាសនា :

* មាត្រាទី ៤៣. កថាខណ្ឌ ១. ២ នៃរដ្ឋធម្មនុញ្ញ

*" ១_ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ ។*

*២_ សេរីភាពខាងជំនឿនិងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់និងសន្តិសុខសាធារណៈ ។ "*

* មាត្រាទី ១៨ កថាខណ្ឌ ១. ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

www.budinst.gov.kh www.elibraryofcambodia.org

*" ១. មនុស្សគ្រប់រូបមានសិទ្ធិពេញទីក្នុងការគោរពសាសនា ការប្រើគំនិតគិតគូរ និងការប្រើសម្បជញ្ញៈផ្សេងៗ ។ នៅក្នុងវគ្គនេះគេត្រូវរាប់បញ្ចូលផងដែរនូវសេរីភាពក្នុងការអនុវត្តន៍សាសនា ឬ សេរីភាពក្នុងជំនឿផ្សេងៗទៅតាមចំណង់ផ្ទាល់ខ្លួន ។ សេរីភាពក្នុងការគោរពធ្វើពិធីបុណ្យសាសនា ប្រារព្ធធ្វើពិធីគោរពបូជាព្រះព្រមទាំងសេរីភាពក្នុងវិស័យការអនុវត្តន៍ផ្សព្វផ្សាយ និង បង្ហាត់បង្រៀនសាសនាផង ។*

*២. គ្មាននរណាម្នាក់ត្រូវគេបង្ខិតបង្ខំឱ្យទទួលយកសាសនាឬជំនឿបែបណាមួយដោយប្រាសចាកការជ្រើសរើសដោយសេរីរបស់ខ្លួនឡើយ ។*

ជំនឿខាងសាសនាត្រូវបានទទួលស្គាល់ផងដែរថា រដ្ឋាភិបាលមិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការទាំងឡាយរបស់សាសនាណាមួយទេ ។ សាសនានានាត្រូវមានសេរីភាពស្របតាមលក្ខខ័ណ្ឌច្បាប់ ។ សេរីភាពទាំងនោះមានដូចតទៅ :

- ការធ្វើពិធីសក្ការៈនានា រួមប្រជុំ និង រក្សាទុកទីកន្លែងដើម្បីគោលបំណងសាសនា ។
- ការរៀបចំបង្កើតស្ថាប័នជួយសង្គ្រោះ និង កិច្ចការមនុស្សធម៌ឱ្យមាននិរន្តរ៍ភាព ។
- ការសរសេរ ការចេញផ្សាយ និង ការចែកចាយឯកសារ ។
- ការបង្រៀនសាសនានៅទីកន្លែងដែលសមរម្យ ។
- ការរៃអង្គាស និង ទទួលវិភាគទានស្ម័គ្រចិត្តខាងហិរញ្ញវត្ថុ និង វិភាគទានផ្សេងៗទៀតពីបុគ្គលម្នាក់ៗ និង ពីស្ថាប័ននានា ។
- ការហ្វឹកហ្វឺន, តែងតាំង, បោះឆ្នោតជ្រើសរើស ឬ ចាត់តាំងអ្នកដឹកនាំសមស្របតាមវិន័យសាសនានោះៗ ។
- ការរៀបចំបង្កើត និង រក្សាទំនាក់ទំនងជាមួយបុគ្គលម្នាក់ៗ និង សហគមន៍នានាអំពីកិច្ចការសាសនា និង ជំនឿក្នុងក្របខ័ណ្ឌជាតិ និង អន្តរជាតិ (2) ។

## ❖ ការត្រិះរិះ

មេរៀននេះបញ្ជាក់ថាសិទ្ធិមនុស្ស គឺសំដៅត្រង់មូលដ្ឋាននៃគំនិតដែលមនុស្សគ្រប់រូបត្រូវបានគេប្រព្រឹត្តមកលើខ្លួនដោយមានការគោរព និង សេចក្តីថ្លៃថ្នូរ ។ សិទ្ធិមនុស្សដែលច្បាប់បានលើកតម្កើង និង ការពារគេហៅថាសិទ្ធិខាងផ្លូវច្បាប់ ដូចមានចែងនៅក្នុងជំពូកទី ៣ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាត្រង់ " អំពី សិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ " ។ ក៏ប៉ុន្តែសិទ្ធិមនុស្សត្រូវតែមានលំនឹងជាមួយការទទួលខុសត្រូវផង បានសេចក្តីថាមនុស្សម្នាក់ៗត្រូវជួយលើកតម្កើង និង ការពារសិទ្ធិពលរដ្ឋ, នយោបាយ, សេដ្ឋកិច្ច, សង្គម និង វប្បធម៌ របស់អ្នកដទៃផង ។ គោលធម៌របស់ ព្រះពុទ្ធ និង ទស្សនៈរបស់ខ្មែរខាងសីលធម៌បានលើកតម្កើង និង ការពារសេចក្តីថ្លៃថ្នូររបស់មនុស្សគ្រប់រូប ដូច្នេះសិទ្ធិមនុស្សទាំងអស់នេះក៏ត្រូវតែលើកតម្កើង និង ការពារផងដែរ ។

---

(1) ស្តេចអាសោកដែលកាន់ព្រះពុទ្ធសាសនាបានចារសិលាចារឹកនៅសតវត្សទី ៣ ក្រោយពុទ្ធសករាជ ( សង្គាយនាទីមួយ ) ថា " *ហាមមិនឱ្យប្រមាថសាសនាដទៃ* " ។

(2) មាត្រា ៦ នៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីអំពីការមិនចេះអត់ឱន និង ការរើសអើងគ្រប់រូបភាពទៅលើសាសនា និង ជំនឿ

www.budinst.gov.kh www.elibraryofcambodia.org

# កម្មវិធីមុខវិជ្ជាសំរាប់គ្រូបង្ហាត់នៃមេរៀនទី ៤

********

## សិទ្ធិមនុស្ស និង ព្រះពុទ្ធសាសនា

### ១. គោលដៅ :

នៅចុងបញ្ចប់នៃមេរៀននេះ សមណសិស្ស និង សិក្ខាកាមអាចយល់ដឹង :

- អំពីអរិយសច្ចៈទាំង៤ ព្រមទាំងអង្គនៃអរិយសច្ចៈនីមួយៗ
- ចេះប្រៀបធៀបមគ្គសច្ចៈទាំង៨ ទៅនឹងសិទ្ធិមនុស្ស ដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ។

### ២. ឯកសារយោង :

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- អរិយសច្ចៈទាំង៤ ជាលាយលក្ខណ៍អក្សរ
- សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស

### ៣. សម្ភារៈសិក្សា

- ក្រដាសផ្ទាំងធំសំរាប់បញ្ចាំងឈើផ្ទាំងក្រណាត់ស
- ក្តារខៀន និង ដីស
- ក្រដាសផ្ទាំងធំ និង ឧបករណ៍សរសេរ
- មេរៀនលាយលក្ខណ៍អក្សរ

### ៤. លំហាត់

- តើអាចថា មគ្គសច្ចៈទាំង៨នេះ ជាផ្លូវកណ្តាល ( មជ្ឈិមប្បដិបទា) បានទេ ?
- តើមគ្គសច្ចៈទាំង៨នេះ អាចយកមកអនុវត្តរកសេចក្តីសុខក្នុងជីវិតបច្ចុប្បន្ន និង អនាគតបានទេ ? ហេតុអ្វី ?
- តើមគ្គសច្ចៈទាំង៨នេះ មានការទាក់ទងជាមួយសិទ្ធិមនុស្សឬទេ ?

www.budinst.gov.kh www.elibraryofcambodia.org

## ៥. មេរៀនទី ៤ : សិទ្ធិមនុស្ស និង ព្រះពុទ្ធសាសនា

---

### ក. សច្ចៈធម៌ប្រសើរនៃព្រះពុទ្ធសាសនាគឺអរិយសច្ចៈទាំង ៤ (៦០នាទី)

- គ្រូបង្ហាត់ត្រូវអានប្រកាសជំរឿដែលបញ្ចាំងនៅលើផ្ទាំងក្រណាត់ស ហើយធ្វើអត្ថាធិប្បាយពន្យល់ផ្សេងៗ ដោយបញ្ជាក់ថា មេរៀននេះ គឺសំដៅយកតែមគ្គសច្ចៈទាំង៨ មកប្រៀបធៀបជាមួយសិទ្ធិមនុស្សតែប៉ុណ្ណោះទេ ។

- គួរចាត់សមណសិស្សមួយអង្គ ឬ សិក្ខាកាមដែលស្ម័គ្រចិត្តម្នាក់អោយឡើងមកធ្វើអត្ថាធិប្បាយពន្យល់តាមផ្លូវធម៌ ( បើអាចធ្វើបាន ) ។

---

សម្រាក ២០នាទី

---

### ខ. មគ្គសច្ចៈ (សច្ចៈទី ៤) (១០០នាទី)

- គ្រូបង្ហាត់ត្រូវចែកសមណសិស្ស និង សិក្ខាកាមជាក្រុម ដើម្បីអោយក្រុមនីមួយៗយកមគ្គសច្ចៈទាំង៨នេះ ម្តងមួយៗទៅប្រៀបធៀបនឹងមាត្រាទាំងឡាយនៃសិទ្ធិមនុស្សដែលមានន័យស្របគ្នា ។ រួចហើយអោយតំណាងក្រុមនីមួយៗ ឡើងមករាយការណ៍ចំពោះមុខវគ្គទាំងមូល ។ នៅទីបញ្ចប់ គ្រូបង្ហាត់ត្រូវជួយសម្របសម្រួលធ្វើយ៉ាងណា ដើម្បីអោយស្របមតិគ្នាក្នុងការប្រៀបធៀបនេះ ដោយមានបញ្ចាំងប្រកាសជំរឿលើផ្ទាំងក្រណាត់ស ។

- គ្រូបង្ហាត់ត្រូវពន្យល់អំពីមគ្គសច្ចៈនេះបន្ថែមទៀតនូវឥទ្ធិពលនៃព្រះធម៌នេះ ដែលមានប្រសិទ្ធិភាពមកទល់សព្វថ្ងៃ និងទៅអនាគត ដើម្បីចិញ្ចឹមជីវិតត្រូវ ដែលនាំមកនូវសេចក្តីថ្លៃថ្នូរ និង ចំរុងចំរើន ។

- គួររកអ្នកឯកទេសមកពន្យល់បន្ថែម ។

---

www.budinst.gov.kh www.elibraryofcambodia.org

# មេរៀនទី ៤

# សិទ្ធិមនុស្ស និង ព្រះពុទ្ធសាសនា

## ក_ សច្ចៈធម៌ដ៏ប្រសើរនៃព្រះពុទ្ធសាសនា

សច្ចៈធម៌ដ៏ប្រសើររបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គទ្រង់ត្រាស់ដឹងពីអរិយសច្ចៈទាំង ៤ ឬ ចតុរារិយសច្ច គឺ:

១_ *ទុក្ខសច្ចៈ* : ( *និយមន័យភាពពិតនៃសេចក្តីទុក្ខ* )

ភាពពិតនៃទុក្ខមាន ១២កង :

១_១_ ជាតិទុក្ខ : ទុក្ខព្រោះកំណើត

១_២_ ជរាទុក្ខ : ទុក្ខព្រោះចំណាស់

១_៣_ ព្យាធិទុក្ខ : ទុក្ខព្រោះជម្ងឺ

១_៤_ មរណទុក្ខ : ទុក្ខព្រោះសេចក្តីស្លាប់

១_៥_ សោកទុក្ខ : ទុក្ខព្រោះក្រៀមក្រំ

១_៦_ បរិទេវទុក្ខ : ទុក្ខព្រោះខ្សឹកខ្សួល

១_៧_ ទោមនស្សទុក្ខ : ទុក្ខព្រោះថ្នាំងថ្នាក់

១_៨_ ឧបាយាសៈទុក្ខ : ទុក្ខព្រោះចង្អៀតចង្អល់

១_៩_ អប្បិយេហិ សម្បយោគៈទុក្ខ : ទុក្ខព្រោះមានជំនួបនឹងរបស់មិនពេញចិត្ត

១_១០_ បិយេហិ វិប្បយោគៈទុក្ខ : ទុក្ខព្រោះបាត់បង់របស់ពេញចិត្ត

១_១១_ យម្បិច្ឆំ ន លភតិ តម្បិទុក្ខំ : ទុក្ខព្រោះមិនបានដូចបំណង

១_១២_ ខន្ធទុក្ខ ៥ :

១_១២_១_ រូបក្ខន្ធ : ប្រជុំរូប ឬ កងរូប

១_១២_២_ វេទនាខន្ធ : ពួក ឬ កងវេទនា

១_១២_៣_ សញ្ញាខន្ធ : ពួក ឬ កងសញ្ញា

១_១២_៤_ សង្ខារខន្ធ : ជំនរ ឬ កងតំនិត

១_១២_៥_ វិញ្ញាណក្ខន្ធ : កងវិញ្ញាណ ឬ ពួកចិត្ត

* ទុក្ខទាំងឡាយដែលមាន ១២កងនេះ មានប្រភពចេញមកពី អនិច្ចំ, ទុក្ខំ, អនត្តា (*)

---

(*) តាមវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ( ព្រៃលក្ខណ៍ ) ។

www.budinst.gov.kh www.elibraryofcambodia.org

២_ <u>សមុទយសច្ចៈ</u> : ( *ហេតុពិតនៃសេចក្តីទុក្ខ* )

២_១_ **កាមតណ្ហា** : យោយកចំណង់ និង បំណងប្រាថ្នានៃវិញ្ញាណទាំង ៥

២_២_ **ភវតណ្ហា** : យោយកភពទាំងឡាយ

២_៣_ **វិភវតណ្ហា** : យោយកការចង់បាន គ្មានភព ឬ វិភព

៣_ <u>និរោធសច្ចៈ</u> : ( *ភាពពិតនៃសេចក្តីរលត់ទុក្ខ* )

៣_១_ ភាពរលត់សូន្យឈឹងនូវកាមតណ្ហា

៣_២_ ភាពរលត់សូន្យឈឹងនូវភវតណ្ហា

៣_៣_ ភាពរលត់សូន្យឈឹងនូវវិភវតណ្ហា

៤_ <u>មគ្គសច្ចៈ</u> : ( *ភាពពិតនៃផ្លូវដើម្បីរលត់ទុក្ខ* )

## <u>អរិយមគ្គ ឬ អដ្ឋង្គិកមគ្គ ឬ មជ្ឈិមបដិបទា</u>

### <u>ក្រុមទី ១ : បញ្ញា</u>

៤_១_ *សម្មាទិដ្ឋិ : ការយល់ឃើញត្រូវ*

៤_១_១_ យល់ឃើញថា ធ្វើបុណ្យបានបុណ្យ

៤_១_២_ យល់ឃើញថា ធ្វើបាបបានបាប

៤_២_ *សម្មាសង្កប្បៈ : ការគិតត្រូវ*

៤_២_១_ គិតមិនព្យាបាទអ្នកដទៃ

៤_២_២_ គិតមិនបៀតបៀនអ្នកដទៃ

៤_២_៣_ គិតមិនយកត្រាំក្នុងកាម

### <u>ក្រុមទី ២ : សីល</u>

៤_៣_ *សម្មាវាចា : សំដីត្រូវ*

៤_៣_១_ **មុសាវាទា** : មិនពោលពាក្យកុហក

៤_៣_២_ **ផរុសវាទា** : មិនជេរប្រមាថ

៤_៣_៣_ **បិសុណាវាទា** : មិនញុះញង់បំបែកបំបាក់

៤_៣_៤_ **សម្ផប្បលាបវាទា** : មិនពោលពាក្យរោយរាយគ្មានសារប្រយោជន៍

www.budinst.gov.kh www.elibraryofcambodia.org

៤_៤_ *សម្មាកម្មន្តៈ : ការងារត្រូវ*

៤_៤_១_ បាណា : ហាមសម្លាប់ជីវិត

៤_៤_២_ អទិន្នា : ហាមលួចទ្រព្យសម្បត្តិគេ

៤_៤_៣_ កាមេ : ហាមប្រព្រឹត្តខុសក្នុងកាម

៤_៥_ *សម្មាអាជីវៈ : ការចិញ្ចឹមជីវិតត្រូវ*

៤_៥_១_ សត្ថវណិជ្ជា : មិនធ្វើជំនួញអាវុធ

៤_៥_២_ សត្តវណិជ្ជា : មិនធ្វើជំនួញមនុស្ស

៤_៥_៣_ មំសវណិជ្ជា : មិនធ្វើជំនួញសត្វ

៤_៥_៤_ មជ្ជវណិជ្ជា : មិនធ្វើជំនួញគ្រឿងញៀន និង គ្រឿងស្រវឹង

៤_៥_៥_ វិសវណិជ្ជា : មិនធ្វើជំនួញថ្នាំពុល

<u>ក្រុមទី ៣ : សមាធិ</u>

៤_៦_ *សម្មាវាយាមៈ : ការព្យាយាមត្រូវ*

៤_៦_១_ ព្យាយាមធ្វើអំពើល្អដែលមិនទាន់បានធ្វើ

៤_៦_២_ ព្យាយាមរក្សាទុកនូវអំពើល្អដែលបានធ្វើហើយ

៤_៦_៣_ ព្យាយាមមិនធ្វើអំពើអាក្រក់ ឬ លះបង់អំពើអាក្រក់ដែលបានធ្វើហើយ

៤_៧_ *សម្មាសតិ : ការរលឹកត្រូវ*

៤_៧_១_ រលឹកដល់ការងារដែលមិនទាន់បានធ្វើ

៤_៧_២_ រលឹកដល់ការងារដែលកំពុងធ្វើ

៤_៧_៣_ រលឹកដល់ការងារដែលធ្វើរួចហើយ

៤_៧_៤_ រលឹកដល់កាយ, វាចា, វេទនា, ចិត្ត, ធម្មៈ ដែលកំពុងប្រព្រឹត្តទៅ

៤_៨_ *សម្មាសមាធិ : ការសំរួមចិត្តត្រូវ*

៤_៨_១_ តម្កល់ក្នុងអារម្មណ៍ល្អ

៤_៨_២_ តម្កល់ក្នុងអំពើល្អ

៤_៨_៣_ តម្កល់ក្នុងមុខការល្អ

៤_៨_៤_ តម្កល់ក្នុងធម្មៈដែលកំពុងសិក្សាហ្វឹកហាត់

ខ_ <u>មគ្គសច្ចៈ ( សច្ចៈទី ៤ )</u>

អរិយសច្ចៈ ៤ គឺជាសច្ចៈធម៌ដ៏ប្រសើរនៃព្រះពុទ្ធទ្រង់ត្រាស់ដឹង ហើយព្រះអង្គផ្សព្វផ្សាយដល់ពុទ្ធបរិស័ទរបស់ព្រះអង្គ ដើម្បីឱ្យយល់ដឹងពីការវិវត្តន៍នៃជីវិតមនុស្ស និង បង្ហាញមាគ៌ាទាំងឡាយដើរទៅរកសេចក្តីសុខ និង និព្វាន ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអង្គបានរកឃើញនូវអរិយសច្ចៈទាំង៤នេះ ព្រមទាំងបានលំអិតនូវអរិយសច្ចៈនីមួយៗថែមទៀតដែលយើងអាចយកមកប្រៀបធៀបទៅនឹងសិទ្ធិមនុស្ស ដែលមាននៅក្នុងសេចក្ដីថ្លែងការណ៍ជាសកលស្ដីពីសិទ្ធិមនុស្សដូចខាងក្រោមនេះ :

ព្រះអង្គបានបង្ហាញផ្លូវត្រូវ៨យ៉ាង ដែលហៅថា អរិយមគ្គទាំង៨ ឬ អដ្ឋង្គិកមគ្គក៏បានដែរ :

**មគ្គទី ១ : សម្មាទិដ្ឋិ** ( ការយល់ឃើញត្រូវ ) : មនុស្សរាល់រូបត្រូវចេះយល់ឃើញនូវការគោរព ការរំលោភសិទ្ធិមនុស្ស ។ តាមព្រះធម៌, មនុស្សដែលគោរពសិទ្ធិមនុស្សគឺជាអ្នកធ្វើល្អបានល្អ ធ្វើបុណ្យបានបុណ្យ ហើយមនុស្សមិនគោរពសិទ្ធិមនុស្សគឺអ្នកធ្វើអាក្រក់បានអាក្រក់ ធ្វើបាបបានបាប ។ ការយល់ឃើញដូចនេះ ត្រូវបានទទួលស្គាល់នៅក្នុងមាត្រា ១ នៃសេចក្ដីប្រកាសជាសកលស្ដីអំពីសិទ្ធិមនុស្ស ។

**មគ្គទី ២ : សម្មាសង្កប្បៈ** ( ការគិតត្រូវ ) : មនុស្សរាល់រូបត្រូវត្រិះរិះត្រូវ ឬ គិតត្រូវដោយមិនព្យាបាទបៀតបៀនអ្នកដទៃ ឬ មិនយកត្រាំក្នុងកាម ដូចជាមាត្រា ១, ១០, ១១ នៃសេចក្ដីថ្លែងការណ៍ជាសកលស្ដីពីសិទ្ធិមនុស្ស ( និយាយអំពីការគិត និង វិធីធ្វើយាត្រូវ ) ។

**មគ្គទី ៣ : សម្មាវាចា** ( សំដីត្រូវ ) : មនុស្សរាល់រូបត្រូវប្រកាន់ការពោលពាក្យត្រូវ មិនកុហក មិនជេរប្រទេច មិនញុះញង់បំបែកបំបាក់ និង ពោលពាក្យគ្មានសារប្រយោជន៍ ដូចមានចែងនៅក្នុងមាត្រាទី ៧, ១២, ១៩ នៃសេចក្ដីថ្លែងការណ៍ជាសកលស្ដីពីសិទ្ធិមនុស្ស ។

**មគ្គទី ៤ : សម្មាកម្មន្តៈ** ( ការងារត្រូវ ) : មនុស្សរាល់រូបត្រូវធ្វើអំពើត្រូវជានិច្ចដោយមិនសម្លាប់ជីវិតគេ, លួចទ្រព្យសម្បត្តិគេ និង ប្រព្រឹត្តខុសក្នុងកាម ដូចមានចែងក្នុងមាត្រា ៣, ៤, ៥, ១៦, ១៧ នៃសេចក្ដីថ្លែងការណ៍ជាសកលស្ដីពីសិទ្ធិមនុស្ស និង មាត្រា ៣៧ នៃអនុសញ្ញាស្ដីអំពីសិទ្ធិកុមារ ។

**មគ្គទី ៥ : សម្មាអាជីវៈ** ( ការចិញ្ចឹមជីវិតត្រូវ ) : មនុស្សរាល់រូបត្រូវបង្ការ ឬ ជៀសវាងកុំឱ្យមានការធ្វើជំនួញអាវុធ, មនុស្ស, សត្វដែលឡាប់ឃាមឃាត់, គ្រឿងញៀន និង ថ្នាំពុល ដូចមានចែងក្នុងមាត្រាទី ៤, ២៣ នៃសេចក្ដីថ្លែងការណ៍ជាសកលស្ដីអំពីសិទ្ធិមនុស្ស ។

**មគ្គទី ៦ : សម្មាវាយាម** ( ការព្យាយាមត្រូវ ) : មនុស្សរាល់រូបត្រូវខំព្យាយាមធ្វើអំពើល្អដែលពុំទាន់បានធ្វើ, ព្យាយាមរក្សាទុកអំពើល្អដែលបានធ្វើរួចហើយ, ព្យាយាមមិនធ្វើអំពើអាក្រក់ ឬ លះបង់អំពើអាក្រក់ដែលធ្លាប់ធ្វើរួចមកហើយ ដូចជាមានចែងក្នុងមាត្រា ១, ២៥, ៣០ នៃសេចក្ដីថ្លែងការណ៍ជាសកលស្ដីពីសិទ្ធិមនុស្ស ។

**មគ្គទី ៧ : សម្មាសតិ** ( ការរលឹកត្រូវ ) : មនុស្សរាល់រូបត្រូវរលឹកដល់ការងារត្រូវដែលមិនទាន់បានធ្វើ, កំពុងធ្វើ, ធ្វើរួចហើយៗរំលឹកដល់កាយ, វាចា, វេទនា, ចិត្ត, កម្មដែលកំពុងប្រព្រឹត្ត ។

ការមានស្មារតីទាំងនេះជាវិធានការដ៏ល្អបំផុតដើម្បីបំបាត់ ឬ កែតម្រង់ការរំលោភសិទ្ធិមនុស្ស ។

**មគ្គទី ៨ : សម្មាសមាធិ** ( ការសង្រួមចិត្តត្រូវ ) : មនុស្សរាល់រូបត្រូវចេះសង្រួមចិត្តត្រូវក្នុងអារម្មណ៍ល្អ, អំពើល្អ, មុខការល្អ និង តម្កល់ចិត្តក្នុងធម៌ដែលកំពុងហ៊ឹកហាត់ ។ ការតម្កល់ចិត្តបានដូចនេះ នឹងនាំមកនូវអំពើអហិង្សា និង សន្តិវិធីក្នុងការដោះស្រាយវិបត្តិនានាដូចជាការប្រើអំណាចដោយរំលោភ ការបំពានច្បាប់ ឬ ការរំលោភសិទ្ធិមនុស្សជាដើម ។ គួរកត់សំគាល់ថាមាត្រា ២៦ កថាខណ្ឌ ២ នៃសេចក្ដីប្រកាសជាសកលស្ដីអំពីសិទ្ធិមនុស្ស បានចែងអំពីការអប់រំដែលអាចជួយអភិវឌ្ឍន៍នូវលក្ខណៈរបស់បុគ្គលឱ្យបានប្រសើរ ដែលមានន័យប្រហាក់ប្រហែលនឹងការសង្រួមចិត្តត្រូវនេះដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

❖ <u>ការត្រិះរិះ</u>

ពុទ្ធសាសនាគិតទុកពីបញ្ហាបុគ្គល និង សង្គម តាមរយៈការពិនិត្យនៃសេចក្តីទុក្ខ ។ ការទំនាក់ទំនងរវាងសិទ្ធិមនុស្ស និង ព្រះពុទ្ធសាសនាមានពន្យល់នៅក្នុងមេរៀននេះ ។ សិទ្ធិមនុស្សទទួលស្គាល់ហេតុនៃសេចក្តីទុក្ខ ហើយ តម្រូវអោយមានការដោះស្រាយនូវសេចក្តីទុក្ខទាំងនោះ ។ ក្នុងនិយោធសច្ចៈ និង មគ្គសច្ចៈមានសម្តែង និង បង្ហាញនូវគោលការណ៍សំខាន់ៗសំរាប់ដោះស្រាយរំលាយទុក្ខ ឬ បំបាត់ការធ្វើបាបកម្មទៅលើមនុស្ស ។

www.budinst.gov.kh www.elibraryofcambodia.org

# កម្មវិធីមុខវិជ្ជាសំរាប់គ្រូបង្ហាត់នៃមេរៀនទី ៥

********

## ច្បាប់ទូទៅ ធម្មាធិបតេយ្យ សិទ្ធិមនុស្ស និង ច្បាប់

### ១. គោលដៅ :

នៅចុងបញ្ចប់នៃមេរៀននេះ សមណសិស្ស និង សិក្ខាកាមអាចយល់ដឹង :

- អំពីនិយមន័យនៃច្បាប់ក្នុងស្រុក និង ច្បាប់អន្តរជាតិ ។
- អំពីនិយមន័យនៃធម្មាធិបតេយ្យ និង សារៈសំខាន់របស់វា ។
- អំពីសិទ្ធិមនុស្ស និង ច្បាប់
- អំពីច្បាប់អន្តរជាតិនៃសិទ្ធិមនុស្សទាំងឡាយដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់ ។

### ២. ឯកសារយោង :

- រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា
- កម្រងឯកសារនៃឧបករណ៍អង្គការសហប្រជាជាតិ
- សៀវភៅ " សកលចិន្តា " របស់ព្រះធម្មបាល ខៀវ ជុំ ( បើមាន )

### ៣. សម្ភារៈសិក្សា

- ក្រដាសជំរក្លីសំរាប់បញ្ចាំងលើផ្ទាំងក្រណាត់ស
- ក្រដាសសផ្ទាំងធំ និង ឧបករណ៍សរសេរ
- ក្តារខៀន និង ដីស
- មេរៀនលោយលក្ខណ៍អក្សរ

### ៤. សំណួរ

- តាមក្នុងមេរៀននេះ តើច្បាប់អាចចែកចេញជាប៉ុន្មានយ៉ាង ? អ្វីខ្លះ ?
- ធម្មាធិបតេយ្យជាមូលដ្ឋានគ្រឹះដើម្បីបង្កើតអ្វី ?
- តើច្បាប់អន្តរជាតិសិទ្ធិមនុស្សមានទទួលស្គាល់ដោយច្បាប់ខ្មែរក្នុងស្រុកទេ ? ច្បាប់នោះឈ្មោះអ្វី ? គ្រប់ជំពូកប៉ុន្មាន ? មាត្រាប៉ុន្មាន ?
- ហេតុដូចម្តេច បានជាព្រះរាជាណាចក្រកម្ពុជាត្រូវតែគោរពច្បាប់អន្តរជាតិ ?

www.budinst.gov.kh www.elibraryofcambodia.org

## ៥_ មេរៀនទី ៥: ច្បាប់ទូទៅ ធម្មាធិបតេយ្យ សិទ្ធិមនុស្ស និង ច្បាប់

---

### ១_ ច្បាប់ ( ៣០នាទី )

- គ្រូបង្ហាត់ត្រូវចាត់អោយសមណសិស្សមួយអង្គ ឬ សិក្ខាកាមម្នាក់អានមេរៀន រួចចោទជាសំណួរដោយលើកយកមួយឃ្លាម្តងៗមកពិភាក្សា ។
- រួចហើយ គ្រូបង្ហាត់ត្រូវពិភាក្សាបំផុសគំនិតដោយអោយសមណសិស្ស និង សិក្ខាកាមលើកជាឧទាហរណ៍នៃច្បាប់ក្នុងស្រុកអោយបានពីរ ឬ បី ហើយនិង ច្បាប់អន្តរជាតិអោយបានមួយ ឬ ពីរ ។

### ២_ ធម្មាធិបតេយ្យ ( ៥០នាទី )

- គ្រូបង្ហាត់ត្រូវចែកសមណសិស្ស និង សិក្ខាកាមជាក្រុមដោយអោយក្រុមនីមួយៗសរសេរលើក្រដាសផ្ទាំងសនូវនិយមន័យ និង សារៈសំខាន់នៃធម្មាធិបតេយ្យ រួចហើយអោយតំណាងក្រុមនីមួយៗឡើងមករាយការណ៍ចំពោះមុខវគ្គទាំងមូល ។
- គ្រូបង្ហាត់ត្រូវធ្វើការសម្របសម្រួលប្រមូលយោបល់ទាំងអស់ យកមកផ្សំធ្វើជានិយមន័យ និង សារៈសំខាន់នៃធម្មាធិបតេយ្យអោយមានដូចនៅក្នុងមេរៀននេះ ។
- គ្រូបង្ហាត់ត្រូវអាននិយមន័យរបស់ព្រះធម្មបាល ខៀវ ជុំ នៅចុងមេរៀនផងដែរ រួចហើយបើកឱ្យសិស្សសួរបញ្ជាក់ ។

---

សម្រាក ២០នាទី

---

### ៣_ សិទ្ធិមនុស្ស និង ច្បាប់សិទ្ធិមនុស្ស ( ១០នាទី )

គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយបកស្រាយមេរៀន រួចហើយបើកអោយសមណសិស្ស និង សិក្ខាកាមសួរបញ្ជាក់ ។

#### ៣_១_ ច្បាប់ក្នុងស្រុក ( ៣០នាទី )

គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយបកស្រាយមេរៀន រួចហើយបើកអោយសមណសិស្ស និង សិក្ខាកាមសួរបញ្ជាក់ ។ កាលណាមានចប់បញ្ជីនៃសិទ្ធិមនុស្សដែលមាននៅក្នុងជំពូក ៣នៃរដ្ឋធម្មនុញ្ញ ។ គ្រូបង្ហាត់ត្រូវពិភាក្សាបំផុសគំនិតដោយអោយសិស្សម្នាក់ៗមានយោបល់ ហើយកត់ត្រាទុកលើក្រដាសផ្ទាំងសធំ ឬ ក្តារខៀន ។

www.budinst.gov.kh www.elibraryofcambodia.org

បើមានការខ្វះខាត គ្រូបង្ហាត់ត្រូវបន្ថែមអោយមានមួចមេរៀនដោយបញ្ចាំងក្រដាសធំរឺក្តារឈើផ្ទាំងក្រណាត់ស នូវបញ្ជីសិទ្ធិទាំងនេះហើយបិទក្រដាសផ្ទាំងសធំទុកនៅក្នុងថ្នាក់រៀន ។

## ៣_២_ ច្បាប់អន្តរជាតិនៃសិទ្ធិមនុស្ស ( ៤០នាទី )

-គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយបកស្រាយមេរៀន រួចហើយបើកអោយសមណសិស្ស និង សិក្ខាកាមសួរបញ្ជាក់ ។ កាលណាអានចប់បញ្ជីច្បាប់អន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលបានយល់ព្រម ហើយចុះហត្ថលេខា គ្រូបង្ហាត់ត្រូវពិភាក្សាបំផុសគំនិតយោយអោយសិស្សម្នាក់ៗមានយោបល់ ហើយកត់លើក្រដាសផ្ទាំងក្រណាត់ស ឬក្តារខៀន ។ បើមានការខ្វះខាត គ្រូបង្ហាត់ត្រូវបន្ថែមដោយមានបញ្ចាំងក្រដាសធំរឺក្តារឈើផ្ទាំងក្រណាត់សអោយសិស្សមើលថែមទៀតផង ។ រួចហើយគ្រូបង្ហាត់ត្រូវបិទក្រដាសផ្ទាំងសនៃបញ្ជីច្បាប់អន្តរជាតិទាំងនេះ ទុកនៅក្នុងថ្នាក់រៀន ។

- សួរអ្នកឯកទេសមកពន្យល់បន្ថែម ។

# <u>មេរៀនទី ៥</u>

## មូលដ្ឋាននៃសិទ្ធិមនុស្ស

## ច្បាប់ទូទៅ ធម្មាធិបតេយ្យ សិទ្ធិមនុស្ស និង ច្បាប់

### ១_ <u>ច្បាប់</u> :

ច្បាប់ គឺជាអង្គសេចក្តីនៃក្បួនវិន័យទាំងឡាយដែលប្រជាជននៃប្រទេសមួយ ឬ រដ្ឋាភិបាលនៃប្រទេសនានាត្រូវ គោរព និង ប្រព្រឹត្តិតាមហើយត្រូវប្រត្តិបត្តិ និង អនុវត្តតាមដោយស្ថាប័នតុលាការនៃប្រទេសទាំងនោះ ។ ច្បាប់ទាំងឡាយត្រូវបានអនុម័តដោយសភា ឬ រដ្ឋសភាជាតិដែលសមាជិកជាតំណាងរាស្ត្រជ្រើសរើសដោយការបោះឆ្នោតសេរី ។ ច្បាប់ទាំងនោះសំរាប់តែអនុវត្តនៅក្នុងរង្វង់ប្រទេសមួយ គេហៅថា "ច្បាប់ក្នុងស្រុកនៃប្រទេសនោះ "។ច្បាប់ដែលអនុម័តដោយអង្គការអន្តរជាតិ ដូចជាមហាសន្និបាតនៃអង្គការសហប្រជាជាតិដែលជាអង្គការមួយមានសមាជិកជាគណៈប្រតិភូតំណាងរដ្ឋាភិបាលនៃប្រទេសនានាក្នុងពិភពលោក រួមទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ ហើយច្បាប់ទាំងនោះគេយកទៅអនុវត្តក្នុងហ្លួងសព្រំដែនប្រទេសទាំងនោះ គេហៅថា " ច្បាប់អន្តរជាតិ " ។

### ២_ <u>ធម្មាធិបតេយ្យ</u> :

ធម្មាធិបតេយ្យជាមូលដ្ឋានគ្រឹះ ដើម្បីបង្កើតឱ្យមានឡើងនូវយុត្តិធម៌សំរាប់មនុស្សគ្រប់រូប ។
តទៅនេះ គឺជានិយមន័យនៃធម្មាធិបតេយ្យ និង សារៈសំខាន់របស់វាសំរាប់គ្រប់ប្រទេសទាំងអស់ :

<u>និយមន័យ:</u>

- សមភាពចំពោះមុខច្បាប់ គ្មានជនណាម្នាក់នៅពីលើច្បាប់បានឡើយ គេរាប់បញ្ចូលទាំងមន្ត្រីរាជការអាជ្ញាធររដ្ឋាភិបាលផង ។
- តុលាការត្រូវមានឯករាជ្យភាពដើម្បីបំពេញករណីយកិច្ចរបស់ខ្លួនហើយតុលាការឯករាជ្យនោះត្រូវតែការពារសិទ្ធិរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេស ។

<u>សារៈសំខាន់:</u>

- ការមានធម្មាធិបតេយ្យ គាំទ្រឱ្យប្រទេសនោះមានស្ថេរភាពក្នុងការអភិវឌ្ឍន៍ខាងសេដ្ឋកិច្ច នយោបាយ និង សង្គមកិច្ចផង ។

(*) សូមអានទំព័រខាងក្រោម ។

### ៣_ <u>សិទ្ធិមនុស្ស និង ច្បាប់</u> :

ច្បាប់ក្នុងស្រុក និង ច្បាប់អន្តរជាតិនៃសិទ្ធិមនុស្ស ត្រូវតែលើកស្ទួយ និង ការពារសិទ្ធិមនុស្ស ។

www.budinst.gov.kh www.elibraryofcambodia.org

## ៣-១- ច្បាប់ក្នុងស្រុក :

ឧទាហរណ៍មួយនៃច្បាប់ក្នុងស្រុក គឺរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលជាច្បាប់កំពូលនៃប្រទេសកម្ពុជា ។ រដ្ឋធម្មនុញ្ញនេះត្រូវបានអនុម័តដោយសភាធម្មនុញ្ញនៅខែ កញ្ញា ឆ្នាំ ១៩៩៣ ។ សភានេះមានសមាជិកជាតំណាងរាស្ត្រដែលជ្រើសរើសឡើងតាមការបោះឆ្នោតសេរី ដោយប្រជាពលរដ្ឋខ្មែរនៅខែឧសភា ឆ្នាំ ១៩៩៣ ។

( យោង និង រំលឹកឡើងវិញនូវមាត្រា ១៣១ នៃរដ្ឋធម្មនុញ្ញ ) មាត្រានេះបានបង្ហាញច្បាស់ថា រដ្ឋធម្មនុញ្ញជាច្បាប់កំពូល ហើយរាល់ច្បាប់ និង សេចក្តីសំរេច ( សកម្មភាព ) របស់ស្ថាប័នរដ្ឋត្រូវតែអនុលោមទៅតាមរដ្ឋធម្មនុញ្ញនោះ ។ ដូច្នេះរាល់ច្បាប់ទាំងអស់ដែលអនុម័តដោយរដ្ឋសភាត្រូវអនុលោមតាមរដ្ឋធម្មនុញ្ញ ហើយសេចក្តីសំរេច ឬ សកម្មភាពរបស់ស្ថាប័ន និង ភ្នាក់ងាររបស់រដ្ឋ ( ក្រសួង, រដ្ឋសភាជាតិ, តុលាការ, នគរបាលជាតិ, កងខេមរភូមិន្ទ, កងរាជអាវុធហត្ថ, អាជ្ញាធរខេត្ត និង ស្រុក ។ល។ ក៏ត្រូវតែអនុលោមតាមរដ្ឋធម្មនុញ្ញនេះដែរ ។

ច្បាប់កំពូលនេះទទួលស្គាល់ធម្មាធិបតេយ្យ ( រំលឹក និង យោងមាត្រា ៣១ វាក្យខ័ណ្ឌទី ២ ) ។ មាត្រានេះ ទទួលស្គាល់សមភាពចំពោះមុខច្បាប់ ដោយមិនប្រកាន់ឋានៈ ឬ ស្ថានភាព ។ ( សូមយោង និង ពិនិត្យមាត្រា ១០៩ ) មាត្រានេះបានទទួលស្គាល់ថា តុលាការនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានឯករាជ្យភាព គឺមានន័យថា " ឥតមានការជ្រៀតជ្រែកខាងផ្លូវនយោបាយ សំណូកសូកប៉ាន់ ឬ បំភិតបំភ័យ / រំខានដល់មន្ត្រីតុលាការ ។ តុលាការមានករណីយកិច្ចពិនិត្យមើលភស្តុតាង និង ជម្រះក្តីរួចហើយអនុវត្តតាមច្បាប់តែប៉ុណ្ណោះ ។

យោងជំពូក ៣ នៃរដ្ឋធម្មនុញ្ញមានចំណងជើង " សិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋ " ។ តំណាងរាស្ត្រនៃសភាធម្មនុញ្ញខ្មែរបានទទួលស្គាល់នូវសារៈសំខាន់នៃសិទ្ធិមនុស្ស ដោយបានបញ្ចូលត្រង់ជំពូក ៣ នៅក្នុងច្បាប់កំពូល ។ តទៅនេះ គឺជាបញ្ជីនៃសិទ្ធិមនុស្សដែលមាននៅក្នុងជំពូក ៣ :

សិទ្ធិមានជីវិតរស់នៅ, សិទ្ធិឱ្យគេចាត់ទុកខ្លួនជាមនុស្ស, សិទ្ធិនារី, សិទ្ធិកុមារ, សេរីភាពក្នុងការធ្វើដំណើរ, សេរីភាពបញ្ចេញមតិ, សេរីភាពមានជំនឿ, សិទ្ធិសេដ្ឋកិច្ចដូចជាសិទ្ធិជ្រើសរើសមុខរបរសមស្រប, សិទ្ធិរៀនសូត្រ, សិទ្ធិទទួលការថែទាំសុខភាព, សិទ្ធិនយោបាយដូចជាសិទ្ធិបោះឆ្នោត, សិទ្ធិឈរឈ្មោះបោះឆ្នោត, និង សិទ្ធិបង្កើតគណៈបក្សនយោបាយ, សិទ្ធិបរិហារ និង ប្តឹងតវ៉ាទៅនឹងស្ថាប័នរាជការ និង អជ្ញាធររបស់រដ្ឋ ។ ឧទាហរណ៍ផ្សេងទៀតនៃច្បាប់ក្នុងស្រុក គឺ ច្បាប់ព្រហ្មទណ្ឌ និង ច្បាប់រដ្ឋប្បវេណី ។

## ៣-២- ច្បាប់អន្តរជាតិនៃសិទ្ធិមនុស្ស :

មហាសន្និបាតនៃអង្គការសហប្រជាជាតិអនុវត្តរាល់ច្បាប់អន្តរជាតិ ។ មានច្បាប់អន្តរជាតិនៃសិទ្ធិមនុស្សជាច្រើន ដែលមហាសន្និបាតនៃអង្គការសហប្រជាជាតិបានអនុម័ត ។ ច្បាប់អន្តរជាតិនៃសិទ្ធិមនុស្ស គេហៅថា កតិកាសញ្ញា ឬ អនុសញ្ញា ។ នៅក្រោយពេលដែលកតិកាសញ្ញា និង អនុសញ្ញានៃសិទ្ធិមនុស្សត្រូវបានអនុម័តដោយមហាសន្និបាត ហើយប្រទេសជាសមាជិកអង្គការសហប្រជាជាតិត្រូវសំរេចថា តើនឹងចុះហត្ថលេខានៅលើកតិកាសញ្ញា និង អនុសញ្ញាសិទ្ធិមនុស្សណាខ្លះ ? ។ កាលណាប្រទេសជាសមាជិកសំរេចចុះហត្ថលេខាលើកតិកាសញ្ញា និង អនុសញ្ញានៃសិទ្ធិមនុស្សណាហើយ ប្រទេសសមាជិកនោះត្រូវតែមានកាតព្វកិច្ចទទួលស្គាល់ និង

www.budinst.gov.kh www.elibraryofcambodia.org

គោរពតាមមាត្រាដែលមានចែងនៅក្នុងច្បាប់ទាំងនោះ ។ ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើកតិកាសញ្ញា ហើយនិង អនុសញ្ញានៃសិទ្ធិមនុស្ស ចំនួន ៩ ។

ព្រះរាជាណាចក្រកម្ពុជាមិនមែនគ្រាន់តែបានចុះហត្ថលេខាលើកតិកាសញ្ញា និង អនុសញ្ញានៃសិទ្ធិមនុស្ស ទាំងនោះទេ ព្រះរាជាណាចក្រកម្ពុជានឹងទទួលស្គាល់ហើយគោរពនូវសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងសេចក្តីប្រកាសជាសកល ព្រមទាំងក្នុងកតិកាសញ្ញានិងអនុសញ្ញាទាំងនោះដែរ ដែលរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មានចែងក្នុងមាត្រា ៣១ ជំពូក ៣ ។ ដូច្នេះបានសេចក្តីថាមានបញ្ចូលកតិកាសញ្ញានិងអនុសញ្ញាទាំងនោះទៅក្នុងច្បាប់ក្នុងស្រុករបស់ខ្លួនដែរ ។ ថ្វីត្បិតតែមានការបញ្ចូលច្បាប់ទាំងនេះក៏ដោយ សេចក្តីសំរេច សកម្មភាពនៃស្ថាប័ន, មន្ត្រី, អង្គាធរបស់រដ្ឋ មិនមែនត្រឹមតែត្រូវអនុលោមទៅតាមរដ្ឋធម្មនុញ្ញតែប៉ុណ្ណោះទេ ។ ប៉ុន្តែត្រូវអនុលោមទៅតាមកតិកាសញ្ញា អនុសញ្ញា និង ច្បាប់នៃសិទ្ធិមនុស្សអន្តរជាតិទាំងនោះផងដែរ ។

តទៅនេះ គឺជាបញ្ជីច្បាប់អន្តរជាតិនៃសិទ្ធិមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាបានយល់ព្រមហើយបានចុះហត្ថលេខា :

១_ កតិកាសញ្ញាស្តីអំពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ។

២_ កតិកាសញ្ញាស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ ។

៣_ អនុសញ្ញាអន្តរជាតិ ស្តីអំពីការបំបាត់ចោលសព្វបែបយ៉ាងនៃការប្រកាន់ពូជសាសន៍ ។

៤_ អនុសញ្ញាស្តីអំពីការបង្ការ និង ផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។

៥_ អនុសញ្ញាស្តីពីសិទ្ធិកុមារ ។

៦_ អនុសញ្ញាស្តីអំពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ។

៧_ អនុសញ្ញាប្រឆាំងទារុណកម្ម និង ការផ្តន្ទាទោស ឬ ការប្រព្រឹត្តទាំងឡាយណាដែល ឃោរឃៅ អមនុស្សធម៌ ឬ ដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស ។

៨_ អនុសញ្ញាស្តីអំពីការបំបាត់ការជួញដូរ មនុស្ស និង ការកេងប្រវ័ញ្ចខាងពេស្យាកម្មលើអ្នកដទៃ ។

៩_ អនុសញ្ញាអន្តរជាតិទាក់ទងទៅនឹងឋានៈផ្លូវច្បាប់នៃជនភៀសខ្លួន ។

---

(*) តាមទស្សនៈរបស់ព្រះធម្មបាល ខៀវ ជុំ ក្នុងសៀវភៅ " សាកលចិន្តា " ព្រះអង្គមានពុទ្ធដីកាថា : " ធម្មាធិបតេយ្យ ប្រកាន់យកធម៌ជាធំ ប្រារព្ធយល់ភាពត្រឹមត្រូវ អនុវត្តគំនិតមានហេតុផល ។ ដែលអាចនិយាយបានម្យ៉ាងទៀតថា ជាធំមិនល្អ ជាធំនិយល្អ ជាធំឃើញល្អ ព្រោះឃើញប្រយោជន៍សង្គមធំជាងប្រយោជន៍ឯកជន ។ ទំរើនេះអ្នកស្រាវជ្រាវមានយោបល់ស្របគ្នាថា ល្អហើយ ត្រឹមត្រូវហើយ ។ ខ្ពស់ជាងនេះ, គឺគេចង់បានអោយធម្មាធិបតេយ្យ បានឋិតនៅជាមូលដ្ឋាន ដើម្បីប្រជាធិបតេយ្យមានលក្ខណៈជាប្រជាធិបតេយ្យពេញទី គឺអោយចាតុម្មឹង សុទ្ធតែជាប្រជាធិបតេយ្យទាំងអស់ ដូចជារដ្ឋាភិបាលរបស់ប្រជាជាតិ, ដើម្បីប្រជាជាតិ, ដោយប្រជាជាតិ គឺអំណាចអធិបតេយ្យម៉្យាងទាំងអស់ ជារបស់ប្រជាពលរដ្ឋពិតៗមែនៗ ។ គឺកើតឡើងដោយអាស្រ័យគំនិត មនុស្សគ្មានឈ្លាភលប់ មានគំនិតព្រហ្មវិហារ ។ល។ អ្នកបង្កើតទ្រឹស្តីលទ្ធិប្រជាធិបតេយ្យមុនគេគឺ ព្រះពុទ្ធបរមគ្រូនៃយើងហ្នឹងតែម្តង ។ ព្រោះអ្វី ? ព្រោះអ្នកស្រាវជ្រាវខាងផ្នែកសាសនា បានឃើញគំនោលធម្មៈរបស់ព្រះអង្គ ជាធាតុផ្តល់សេរី សមភាព ភាតរភាព ។ល។ ដោយមនុស្សគ្រប់វណ្ណៈ ត្រកូល អំបូរ ជាតិសាសន៍ ។ល។

www.budinst.gov.kh www.elibraryofcambodia.org

របស់សត្វតិរច្ឆាន ដើមឈើ ។ល។ នៅក្នុងរបបធម្មាធិបតេយ្យ ពុទ្ធសាសនាបានធ្វើសេចក្តីបំភ្លឺថា នយោបាយគ្រប់គ្រង ទោះជាគ្រប់គ្រងការងារក្តី ទូតក្តី នាវាក្តី យន្តហោះក្តី ប្រទេសក្តី រដ្ឋក្តី ។ល។ គេត្រូវប្រើធម្មៈជាអំណាច កុំប្រើអំណាចជាធម្ម ។ អ្នកប្រើធម្មៈជាអំណាច និង ប្រើអំណាចជាធម្មៈ ។ ចំណុចខុសគ្នានៅត្រង់នេះ គឺអ្នកប្រើធម្មៈជាអំណាច គេអនុវត្តនូវទំនើអ្វីៗទាំងអស់តាមច្បាប់ ឬ តាមធម៌ដែលនៅជាធរមាន។ ចំណែកអ្នកប្រើអំណាចជាធម៌ គេអនុវត្តនូវអ្វីៗទាំងអស់ដោយទាញយកច្បាប់យកធម៌នៅក្នុងក្របខ័ណ្ឌនៃគំនិតបោកប្រាសថា ទំនើរបស់ខ្ញុំនេះធ្វើឡើងដោយត្រឹមត្រូវតាមច្បាប់ តាមធម៌ជាធរមានហើយ តែកុហកសោះ ។

បុគ្គលដែលប្រើធម្មៈជាអំណាច បានដល់ព្រះអរិយបុគ្គលទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម ដូចមានចែងក្នុងគម្ពីរព្រះវិន័យថា :

ថ្ងៃមួយជាថ្ងៃបវារណាកម្ម ព្រះសម្មាសម្ពុទ្ធព្រះអង្គគង់ក្នុងវត្តបុព្វារាម មានព្រះអរហន្តសាវកចំនួនប្រមាណ ៥០០អង្គ គង់នៅជាមួយ ។ ក្នុងពេលនោះព្រះសម្មាសម្ពុទ្ធត្រូវបានបវារណាមុនគេ ព្រះអង្គបានបើកឱកាសអោយសង្ឃចោទប្រកាន់នូវទំនើមិនល្អរបស់ព្រះអង្គ ទោះជាដោយឃើញក្តី លឺក្តី សង្ស័យក្តី ។ ព្រះសារីបុត្តត្រូវបានបវារណាជាបន្ទាប់ លោកបានពោលពាក្យសរសើរព្រះសម្មាសម្ពុទ្ធក្នុងចំណុចដែលព្រះអង្គបានរស់នៅក្រោមបន្ទាត់នៃធម្មៈវិន័យយ៉ាងទៀងទាត់ ហើយលោកបានបវារណាជាលំដាប់ទី ២ ។ នេះបញ្ជាក់អោយឃើញថា ព្រះសម្មាសម្ពុទ្ធព្រះអង្គប្រកាន់យកធម្មៈជាធំ ( ធម្មាធិបតេយ្យ )។ ដោយអាស្រ័យព្រះទំនើនៃព្រះសម្មាសម្ពុទ្ធនេះ ទើបសកលពុទ្ធសាសនិក អនុវត្តទំនើគ្រប់យ៉ាងជាធម្មាធិបតេយ្យ ឬ មានធម្មាធិបតេយ្យជាបន្ទាត់នៃការអនុវត្តន៍ ។ល។ និង ។ល។

កាលណាគេចូលចិត្តគំនោលធម្មាធិបតេយ្យជ្រៅជ្រះហើយ គេនឹងមានការចេះដឹងភ្លាមថា អ្វីៗទាំងអស់ក្នុងពិភពលោកទោះជាធាតុនយោបាយគ្រប់គ្រងក្តី សេដ្ឋកិច្ចក្តី សង្គមកិច្ចរដ្ឋក្តី វប្បធម៌ប្រទេសក្តី ។ល។ ដែលមានយុត្តិធម៌ ដែលត្រឹមត្រូវ ដែលជាកុសល ។ល។ សុទ្ធតែមានកំណើត មានមូលដ្ឋានអំពីធម្មាធិបតេយ្យទាំងអស់ ។ ជាពិសេសគឺ លទ្ធិប្រជាធិបតេយ្យហ្នឹងតែម្តង ។

www.budinst.gov.kh www.elibraryofcambodia.org

# កម្មវិធីមុខវិជ្ជាសំរាប់គ្រូបង្ហាត់នៃមេរៀនទី ៦ និង ៧

********

## ការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌

### ១. គោលដៅ :

នៅចុងបញ្ចប់នៃមេរៀននេះ សមណសិស្ស និង សិក្ខាកាមអាចយល់ដឹង :

- អំពីកត្តានៃប្រជាធិបតេយ្យពហុបក្ស
- អំពីសេរីភាពនានាក្នុងការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌
- អំពីឯករាជ្យភាពនៃតុលាការ, ភាពមិនប្រកាន់ពីសម្តី និង ការបោះឆ្នោតសម្ងាត់
- អំពីភាពស្របច្បាប់នៃរាជរដ្ឋាភិបាល ។

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

### ២. ឯកសារយោង :

- រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ
- សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស

### ៣. សម្ភារៈសិក្សា

- ក្រដាសធំរឺក្តីសំរាប់បញ្ចាំងលើផ្ទាំងក្រណាត់ស
- ក្តារខៀន និង ដីស
- ក្រដាសផ្ទាំងធំ និង ឧបករណ៍សរសេរ
- មេរៀនលោយលក្ខណ៍អក្សរ

### ៤. សំណួរ

- តើមានសេរីភាពអ្វីខ្លះដើម្បីធ្វើអោយមានការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌ ?
- តើយ៉ាងដូចម្តេចទៅដែលហៅថា តុលាការឯករាជ្យ ?
- តើក្រុមប្រឹក្សាធម្មនុញ្ញមានភារកិច្ចធ្វើអ្វីខ្លះ ?
- តើគណៈកម្មការបោះឆ្នោតឯករាជ្យត្រូវមានសមាជិកប្រភេទណាខ្លះ ?
- តើភាពស្របច្បាប់នៃរាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ន និង អនាគតត្រូវផ្អែកទៅលើអ្វីខ្លះ ?
- តើអាចថា ការបោះឆ្នោតគឺជាការស្វែងរកព្រះបាទធម្មិកបានឬទេ ?

www.budinst.gov.kh www.elibraryofcambodia.org

## ៥- <u>មេរៀនទី ៦ និង ៧</u> : ការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌

---

### ប្រជាធិបតេយ្យគង់វង្សអាស្រ័យលើការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌ (៤០នាទី)

គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន និង អានរដ្ឋធម្មនុញ្ញមាត្រា ៥១ តាមក្រដាសជ័រភ្លឺ ដែលមានបញ្ចាំងលើផ្ទាំងក្រណាត់ស ដោយអោយសិស្សសួរបញ្ជាក់ ហើយពន្យល់បន្ថែមនូវពាក្យ «<u>ប្រជាធិបតេយ្យពហុបក្ស</u>» និង «<u>អំណាចបែងចែកដាច់ពីគ្នា</u>»។ បន្ទាប់មកទៀត គ្រូបង្ហាត់អត្ថាធិប្បាយមេរៀន និង អានរដ្ឋធម្មនុញ្ញមាត្រា ៣៤ និង ៥២ តាមក្រដាសជ័រភ្លឺដែលបញ្ចាំងលើផ្ទាំងក្រណាត់ស ដោយអោយសិស្សសួរបញ្ជាក់ ហើយពន្យល់បន្ថែមត្រង់ចំណុចថា «<u>សិទ្ធិបោះឆ្នោត និង សិទ្ធិឈរឈ្មោះអោយគេបោះឆ្នោត</u>» និង ចំណុចថា «<u>សិទ្ធិបង្កើតសមាគម និង គណៈបក្សនយោបាយ</u>»។

- <u>សេរីភាពក្នុងការបញ្ចេញមតិ (៤០នាទី)</u>

គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន និង អានមាត្រា ២៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា ១៩ កថាខ័ណ្ឌ នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និង នយោបាយ តាមក្រដាសជ័រភ្លឺដែលមានបញ្ចាំងលើក្រណាត់ផ្ទាំងស ដោយអោយសិស្សសួរបញ្ជាក់ហើយពន្យល់បន្ថែមត្រង់ចំណុចថា « <u>ពិតជាផ្ទុះចេញមកពីសំណាក់ប្រជាពលរដ្ឋ</u> » ពាក្យថា « <u>ជាតិពន្ធ និង និរាករណ៍</u> » « <u>សិទ្ធិប្រកាន់យកមតិយោបល់ដោយសេរី</u> »។

---

សម្រាក ២០នាទី

---

- <u>សេរីភាពក្នុងការបញ្ចេញយោបល់ និង សេរីភាពខាងព័ត៌មាន (៤០នាទី)</u>

- គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន និង អានមាត្រា ៤១ កថាខ័ណ្ឌ ១ នៃរដ្ឋធម្មនុញ្ញ តាមក្រដាសជ័រភ្លឺដែលមានបញ្ចាំងលើផ្ទាំងក្រណាត់សដោយអោយសិស្សសួរបញ្ជាក់ ហើយពន្យល់បន្ថែមត្រង់ចំណុចថា « <u>គ្មានការភ័យខ្លាច ឬ ការបំភិតបំភ័យ</u> » និង ចំណុចថា « <u>មិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំអោយប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និង ដល់សន្តិសុខជាតិ</u> »។

www.budinst.gov.kh www.elibraryofcambodia.org

- គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន និង អានមាត្រា ១៩ កថាខណ្ឌ ២ នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និង នយោបាយ តាមក្រដាសផ្ទាំងធំដែលមានបញ្ចាំងលើផ្ទាំងក្រណាត់ស ដោយបើកអោយសិស្សសួរបញ្ជាក់ ។

- <u>សេរីភាពក្នុងការប្រជុំ ( ៤០នាទី )</u>

គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន និង អានមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយតាមក្រដាសផ្ទាំងធំ ដែលមានបញ្ចាំងលើផ្ទាំងក្រណាត់ស រួចហើយបើកឱ្យសិស្សសួរបញ្ជាក់ និង ពន្យល់បន្ថែមត្រង់ចំណុចថា « <u>បាតុកម្មសាធារណៈ និង ការជួបជុំនយោបាយគឺជាផ្នែកមួយនៃការផ្សព្វផ្សាយពត៌មាននយោបាយ</u> » និង ពាក្យថា « <u>ដោយសន្តិវិធី</u> » ។

---

<u>ថ្ងៃបន្ទាប់</u>

---

- <u>សេរីភាពក្នុងការបង្កើតសមាគម ( ៣០នាទី )</u>

គ្រូបង្ហាត់ត្រូវអធិប្បាយមេរៀន និង អានមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ, មាត្រា ២២ កថាខណ្ឌ ១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយតាមក្រដាសផ្ទាំងធំ ដែលមានបញ្ចាំងលើផ្ទាំងក្រណាត់ស រួចហើយបើកអោយសិស្សសួរបញ្ជាក់ និង ពន្យល់បន្ថែម ត្រង់ចំណុចថា « <u>ដែលខ្វះមិនបាន</u> » និងចំណុចថា « <u>ចូលរួមគណៈបក្សនយោបាយតាមការជ្រើសរើសរបស់ខ្លួន</u> » ។

- <u>ឯករាជ្យភាពនៃតុលាការ ( ៣០នាទី )</u>

គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន និង អានមាត្រា ៣១ កថាខណ្ឌ ២ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១១៧ កថាខណ្ឌ ២ នៃរដ្ឋធម្មនុញ្ញ តាមក្រដាសផ្ទាំងធំដែលមានបញ្ចាំងលើផ្ទាំងក្រណាត់ស រួចហើយបើកឱ្យសិស្សសួរបញ្ជាក់ និង ពន្យល់បន្ថែមត្រង់ចំណុចថា « <u>ការពារសិទ្ធិសេរីភាពស្មើគ្នាចំពោះមុខច្បាប់ និង ការពារប្រឆាំងនូវការប្រើអំណាចដោយរំលោភ</u> » ពាក្យថា « <u>ក្រុមប្រឹក្សាធម្មនុញ្ញ</u> » និង ពាក្យថា « <u>គណៈកម្មការឯករាជ្យនៃការបោះឆ្នោត</u> » ។ ការគំរាមកំហែង ការល្បួងពានលើរូបកាយ ការបង្ខិតបង្ខំប្រភេទណាក៏ដោយ ធ្វើអោយប៉ះពាល់ដល់ការប្រព្រឹត្តដោយសេរីនៃសិទ្ធិបោះឆ្នោត និង សិទ្ធិឈរឈ្មោះអោយគេបោះឆ្នោត ។

- <u>គោលការណ៍នៃការមិនប្រកាន់រើសអើង ( ២០នាទី )</u>

គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន និង អានមាត្រា ៣១ កថាខណ្ឌ ២ នៃរដ្ឋធម្មនុញ្ញ, មាត្រា ៦១ កថាខណ្ឌ ១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល, មាត្រា ៥៩ និង ២៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល, មាត្រា ២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយតាមក្រដាសផ្ទាំងធំដែលមានបញ្ចាំងលើផ្ទាំងក្រណាត់ស

www.budinst.gov.kh www.elibraryofcambodia.org

រួចហើយបើកអោយសិស្សសួរបញ្ជាក់ និង ពន្យល់បន្ថែមត្រង់ចំណុចថា « ជនជាតិភាគតិចមានដូចជាស្ត្រី អ្នកក្រ និង សមាជិកគណៈបក្សប្រឆាំង » ពាក្យថា« ចាត់ទុកជាមោឃៈ » និងពាក្យថា « ប្រកាន់បីសអើង »។

## សម្រាក ២០នាទី

### - ការបោះឆ្នោតសម្ងាត់ ( ៣០នាទី )

គ្រូបង្ហាត់ត្រូវអធិប្បាយមេរៀន និង អានមាត្រា ២៥ កថាខ័ណ្ឌ ខ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ តាមក្រដាសជ័រភ្លឺដែលមានបញ្ចាំងលើផ្ទាំងក្រណាត់ស រួចហើយបើកអោយសិស្សសួរបញ្ជាក់ និង ពន្យល់បន្ថែមត្រង់ចំណុចថា « ត្រូវមើលតែសាមីខ្លួន » ចំណុចថា « កំបាំងអ្នកដទៃ » និង ចំណុចថា « បង្ខំអោយបោះឆ្នោតយ៉ាងណាៗនោះឡើយ » ។

### - តម្រូវការទូទៅក្នុងការធ្វើអោយមានការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌ ( ៣០នាទី )

- ពិភាក្សាបំផុសគំនិតដើម្បីអោយសិស្សគិតរកសេចក្តីតម្រូវការផ្សេងៗក្នុងការធ្វើអោយមានការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌ ដោយកត់ត្រាលើក្រដាសផ្ទាំងស ។
- គ្រូបង្ហាត់ត្រូវជួយកែសម្រួល រួចហើយបិទក្រដាសផ្ទាំងសនៅក្នុងថ្នាក់ ។

### - ការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌ ( ២០នាទី )

គ្រូបង្ហាត់ត្រូវអធិប្បាយមេរៀន និង អានមាត្រា ២១ កថាខ័ណ្ឌ ៣ នៃសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្សតាមក្រដាសជ័រភ្លឺ ដែលមានបញ្ចាំងលើផ្ទាំងក្រណាត់ស រួចហើយបើកអោយសិស្សសួរបញ្ជាក់ និង ពន្យល់បន្ថែមត្រង់ចំណុចថា « សម្តែងនូវឆន្ទៈនយោបាយរបស់ខ្លួនឱ្យបានពេញលេញ » ចំណុចថា « គឺផ្អែកទាំងស្រុងទៅលើការបោះឆ្នោតដោយសេរី និង យុត្តិធម៌ » និង ចំណុចថា « រដ្ឋាភិបាលរបស់ខ្លួនតំណាងស្របច្បាប់នៃឆន្ទៈនយោបាយរបស់ពលរដ្ឋ ។

- សួរអ្នកឯកទេសមកពន្យល់បន្ថែម ។

www.budinst.gov.kh www.elibraryofcambodia.org

# <u>មេរៀនទី ៦ និង ៧</u>

## ការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌

### ប្រជាធិបតេយ្យគង់វង្សអាស្រ័យលើការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌

រាល់ប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ ត្រូវតែធ្វើឱ្យការបោះឆ្នោតសេរី និង យុត្តិធម៌បានសំរេចពេញលេញ ។ ការបោះឆ្នោតដោយសេរី និង យុត្តិធម៌នេះហើយ ដែលបញ្ជាក់ពិតប្រាកដនូវឆន្ទៈរបស់ប្រជាពលរដ្ឋ ។ លទ្ធិប្រជាធិបតេយ្យសេរីរបស់ព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញត្រង់មាត្រា ៥១ មានចែងថា :

*“ ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។*

*អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។*

*អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ ។ ”*

សិទ្ធិនយោបាយទាំងឡាយក៏បានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញដែរ :
ដូចត្រង់មាត្រា ៣៤ និង ៤២ ខាងក្រោមមានចែងថា :

*“ <u>មាត្រា៣៤</u> : ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោតនិងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។*
*ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។*
*ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោត ។*

*បទបញ្ញត្តិបដិសេធសិទ្ធិបោះឆ្នោតនិងសិទ្ធិឈរឈ្មោះឱ្យគេ បោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត ។*

*<u>មាត្រា៤២</u> : ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគមនិងគណៈបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។*

*ប្រជាពលរដ្ឋខ្មែរទាំងឡាយអាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធិផលជាតិ និងសណ្តាប់ធ្នាប់សង្គម ។ ”*

មានសិទ្ធិមនុស្សមួយចំនួនផ្សេងទៀត ដែលមានសារៈសំខាន់លើសពីពោលខាងលើ ក្នុងការធានាការបោះឆ្នោតដោយសេរី និង យុត្តិធម៌ ។ សិទ្ធិមនុស្សទាំងនោះមានចែងនៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាផង ។ តទៅនេះ គឺជាគោលសំខាន់ៗនៃសិទ្ធិទាំងនោះ ហើយនិង មានយោងទាក់ទងទៅនឹងមាត្រាច្បាប់ព្រះរាជាណាចក្រកម្ពុជា :

www.budinst.gov.kh www.elibraryofcambodia.org

- <u>សេរីភាពក្នុងការបញ្ចេញមតិ</u> :

សេរីភាពក្នុងការបញ្ចេញមតិ ត្រូវមានជាចាំបាច់បំផុតនៅក្នុងបរិបទនៃការបោះឆ្នោតដោយសេរី និង យុត្តិធម៌ ។ បើសិនណាជាសេរីភាពនៃការបញ្ចេញមតិត្រូវគេរឹតត្បិតនោះ គេមិនអាចធ្វើឱ្យប្រាកដថា អ្វីៗដែលអះអាងពិតជាឆន្ទៈចេញមកពីសំណាក់ប្រជាពលរដ្ឋទេ ។

តទៅនេះគឺជាច្បាប់ទាំងឡាយដែលព្រះរាជាណាចក្រកម្ពុជា ជួយលើកតម្កើង និង ការពារសិទ្ធិទាំងនោះ :

* មាត្រា ២៨ នៃច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌរបស់ឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់ មានចែងថា :

<u>បទល្មើសក្នុងការសម្តែងមតិ ឬ ជំនឿ</u> :

*“ ១_ គ្មានជនណាម្នាក់ត្រូវគេយាយីរំខានពីរឿងមតិនយោបាយ ជំនឿសាសនា និងពីការដែលខ្លួនជាប់ពូជសាសន៍ ឬជាតិពន្ធ (១) ណាមួយឡើយ ។*

*២_ ច្បាប់ព្រហ្មទណ្ឌទាំងឡាយ ដែលមានជាធរមានសព្វថ្ងៃនូវទាំងប្រទេសកម្ពុជា មិនអាចយកមកសំអាងលើបទល្មើសក្នុងការសំដែងមតិនយោបាយ ឬបទល្មើសមនោគមវិជ្ជាទៀតឡើយ ហើយត្រូវទុកជានិរាករណ៍ (២) ។ ”*

* មាត្រា ១៩ កថាខណ្ឌ ១ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ មានចែងថា :

*“ ១_ មនុស្សគ្រប់រូបមានសិទ្ធិប្រកាន់យកមតិយោបល់ដោយសេរី ។ ”*

- <u>សេរីភាពក្នុងការបញ្ចេញយោបល់ និង សេរីភាពខាងព័ត៌មាន</u>

សេរីភាពក្នុងការបញ្ចេញយោបល់ និង សេរីភាពខាងព័ត៌មាន ត្រូវតែគាំពារ ដើម្បីឱ្យអ្នកមានគំនិតគាំទ្របក្សរបស់ខ្លួនអាចសម្តែងមតិបានក្នុងការធ្វើឱ្យមានការបោះឆ្នោតដោយសេរី និង យុត្តិធម៌ ។ បើសិនជាប្រជាពលរដ្ឋពុំបានទទួលព័ត៌មានច្បាស់លាស់ ការបោះឆ្នោតមិនអាចនឹងធានាបានប្រាកដថា លទ្ធផលពិតជាឆន្ទៈរបស់ប្រជាពលរដ្ឋឡើយ ។ គឺលុះណាតែប្រជាពលរដ្ឋទាំងអស់មានសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួន ឬផ្សាយព័ត៌មានដោយគ្មានការភ័យខ្លាច ឬ ការបំភិតបំភ័យ ទើបការបោះឆ្នោតនោះអាចចាត់ទុកថាជាការបោះឆ្នោតដោយសេរី និង យុត្តិធម៌ទៅកើត ។ រួមជាមួយនេះដែរ គណបក្សនយោបាយទាំងអស់ត្រូវមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានស្មើភាពគ្នា និងដោយយុត្តិធម៌ ។ តទៅនេះគឺជាច្បាប់ដែលព្រះរាជាណាចក្រកម្ពុជាជួយលើកតម្កើង និង ការពារសិទ្ធិទាំងនោះ :

* មាត្រា ៤១ កថាខណ្ឌ ១ នៃរដ្ឋធម្មនុញ្ញបានចែងថា :

*“ ប្រជាពលរដ្ឋមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។ របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។ ”*

---

(១) ជាតិពន្ធ = ពូជអំបូរ

(២) និរាករណ៍ = ទុកជាមោឃៈ

www.budinst.gov.kh www.elibraryofcambodia.org

* មាត្រា ១៩ កថាខណ្ឌទី ២ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយមានចែងថា :

*“ ២_ មនុស្សគ្រប់រូបមានសិទ្ធិបញ្ចេញមតិដោយសេរី ។ សិទ្ធិនេះត្រូវរាប់បញ្ចូលផងដែរនូវសិទ្ធិក្នុងការសាកសួរព័ត៌មាន ទទួលព័ត៌មាន ឬផ្សព្វផ្សាយព័ត៌មាន និងគំនិតគ្រប់បែបយ៉ាងដោយឥតគិតពីព្រំដែនឡើយ ទោះបីតាមរយៈការនិយាយផ្ទាល់មាត់ ការសរសេរ ការបោះពុម្ព ការផ្សាយតាមទម្រង់សិល្បៈ ឬតាមឯកសារព័ត៌មាន ។ ”*

- <u>*សេរីភាពក្នុងការរួមប្រជុំ*</u> :

សេរីភាពក្នុងការរួមប្រជុំត្រូវតែការពារ ដោយហេតុថា បាតុកម្មសាធារណៈ និង ការរួមប្រជុំនយោបាយ គឺជាផ្នែកមួយរបស់ប្រព័ន្ធនៃការផ្សព្វផ្សាយព័ត៌មាននយោបាយ ។ រដ្ឋគួរតែកុំជ្រៀតជ្រែកតាមតែអំពើចិត្តទៅលើការប្រជុំដែលប្រព្រឹត្តទៅដោយសន្តិវិធី ។

តទៅនេះ គឺជាច្បាប់ដែលព្រះរាជាណាចក្រកម្ពុជាជួយលើកតម្កើង និង ការពារសិទ្ធិទាំងនោះ :

* មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ ( ដែលបានរៀបរាប់មកហើយ )

* មាត្រា ២១ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយមានចែងថា :

*“ មនុស្សមានសិទ្ធិធ្វើការរួមប្រជុំគ្រប់បែបយ៉ាងដោយតែប្រកបដោយសន្តិវិធី ។ មិនត្រូវឱ្យមានការរឹតលក្ខខណ្ឌអ្វីទេចំពោះការរួមប្រជុំបែបនេះ ប្រសិនបើគ្មានការប៉ះទង្គិចទៅនឹងច្បាប់ចាំបាច់របស់សង្គមប្រជាធិបតេយ្យក្នុងវិស័យរក្សាសន្តិសុខជាតិសន្តិភាព និងរបៀបរៀបរយសាធារណៈ និងវិស័យការពារសុខុមាលភាពសាធារណៈ សីលធម៌ ព្រមទាំងគោរពនិងការពារសិទ្ធិ និងសេរីភាពអ្នកដទៃ ។ ”*

- <u>*សេរីភាពក្នុងការបង្កើតសមាគម*</u> :

សេរីភាពក្នុងការបង្កើតសមាគម មានន័យប្រហាក់ប្រហែលទៅនឹងសិទ្ធិនៃសេរីភាពក្នុងការរួមប្រជុំដែរ ។ តែក៏ជាសិទ្ធិសំខាន់ណាស់<u>ដែលមិនអាចខ្វះបាន</u> ពីព្រោះសិទ្ធិនេះអនុញ្ញាតឱ្យប្រជាពលរដ្ឋបង្កើតគណៈបក្សនយោបាយ ឬ ចូលរួមក្នុងគណៈបក្សនយោបាយតាមការជ្រើសរើសរបស់ខ្លួន ដែលជាតម្រូវការចាំបាច់សម្រាប់បុគ្គលចូលរួមធ្វើនយោបាយក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ។

តទៅនេះ គឺជាច្បាប់ដែលព្រះរាជាណាចក្រកម្ពុជាជួយលើកតម្កើង និង ការពារសិទ្ធិទាំងនេះ មានចែងថា :

* មាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ ( ដែលរៀបរាប់មកហើយ )

* មាត្រា ២២ កថាខណ្ឌ ១ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមានចែងថា :

*“ ១_ មនុស្សគ្រប់រូបមានសិទ្ធិរួបរួមប្រជុំជាមួយអ្នកដទៃដោយសេរី ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសិទ្ធិក្នុងការបង្កើត ឬចូលរួមជាមួយសមាជិកពាណិជ្ជកម្ម ដើម្បីការពារអត្ថប្រយោជន៍របស់គេ ។ ”*

www.budinst.gov.kh www.elibraryofcambodia.org

## - ឯករាជ្យភាពនៃតុលាការ :

តុលាការឯករាជ្យ គឺជាស្ថាប័នគ្រឹះមួយរបស់ជាតិដែលមានមុខនាទីការពារសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និង ការពារប្រឆាំងនូវការប្រើអំណាចដោយរំលោភ ។

ស្ថាប័ននេះហើយដែលអនុញ្ញាតិឱ្យប្រជាពលរដ្ឋសម្តែងការមិនយល់ស្រប ហើយនិង ប្តឹងតវ៉ាអំពីដំណើរការមិនត្រឹមត្រូវនៃការបោះឆ្នោត ។ ក្នុងការធ្វើឱ្យបានសំរេចពេញលេញនូវការបោះឆ្នោតដោយសេរី និង យុត្តិធម៌ តុលាការត្រូវតែមានភាពមិនលំអៀងដោយគ្មានស៊ីសំណូក ហើយមិនទទួលការសង្កត់សង្កិន គំរាមកំហែង ឬ បំភិតបំភ័យពីខាងក្រៅ ។ ភាពមិនលំអៀងនេះត្រូវធានាថាសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និងត្រួតពិនិត្យមើលដំណើរការនៃការបោះឆ្នោត ហើយពុំមែនអ្នកនយោបាយណាម្នាក់ គណៈបក្សនយោបាយណាមួយ ឬ ដោយគហបតីណាមួយឡើយដែលត្រួតពិនិត្យការបោះឆ្នោតនោះ ។ តុលាការដែលមានភាពឯករាជ្យ ពិតជាការពារដំណើរការបោះឆ្នោតកុំឱ្យមានភាពលំអៀង ឬ ការបន្លំ ។

ក្នុងការធ្វើឱ្យសម្រេចពេញលេញនូវការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា គណៈកម្មការឯករាជ្យនៃការបោះឆ្នោត និង ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាអ្នកទទួលការតវ៉ាមិនយល់ស្រប និង ការប្តឹងតវ៉ាដែលទាក់ទងទៅនឹងដំណើរការបោះឆ្នោត ។

គណៈកម្មការទាំងពីរនេះត្រូវប្រកាន់ភាពមិនលំអៀង ដូចជាតុលាការឯករាជ្យមួយដែលធានាឱ្យមានការបោះឆ្នោតដោយសេរី និង យុត្តិធម៌ ។ គេកំពុងតែព្រាងច្បាប់បង្កើតគណៈកម្មការឯករាជ្យនៃការបោះឆ្នោត ។

តទៅនេះ គឺជាមាត្រានៃរដ្ឋធម្មនុញ្ញដែលទទួលស្គាល់ភាពស្មើគ្នាចំពោះមុខច្បាប់ ហើយនិង ការបង្កើតសិទ្ធិនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌនៃការបោះឆ្នោតក្លែងបន្លំរបស់ឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ។

* មាត្រា ៦៤ នៃច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌរបស់ឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់ មានចែងថា :

*" ជនណាក៏ដោយ តាមការគំរាមកំហែង ការឃ្លាតពាក់រឺរូបកាយ. ការបង្ខិតបង្ខំប្រភេទណាក៏ដោយ ធ្វើអោយប៉ះពាល់ដល់ការប្រព្រឹត្តដោយសេរីនៃសិទ្ធិបោះឆ្នោត និង សិទ្ធិឈរឈ្មោះអោយគេបោះឆ្នោត ឬប៉ះពាល់ដល់ភាពត្រឹមត្រូវនៃប្រតិបត្តិការបោះឆ្នោតទាំងឡាយ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។ "*

* មាត្រា ៣១ កថាខណ្ឌ ២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាមានចែងថា :

*" ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិ សេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវប៉ះពាល់ដល់សិទ្ធិ សេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិ សេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។ "*

* មាត្រា ១១៧ កថាខណ្ឌ ២ នៃរដ្ឋធម្មនុញ្ញមានចែងថា :

*" ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យនិងសំរេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ។ "*

www.budinst.gov.kh www.elibraryofcambodia.org

## - គោលការណ៍នៃការមិនប្រកាន់រើសអើង

គោលការណ៍នៃការមិនប្រកាន់រើសអើងនេះ គឺដើម្បីធានាថានឹងបើកលទ្ធភាពចំហរក្នុងដំណើរការបោះឆ្នោតឱ្យពលរដ្ឋគ្រប់រូបអាចចូលរួមបាន រួមទាំងជនជាតិភាគតិចដែលមានសិទ្ធិបោះឆ្នោតស្របច្បាប់ផង ។ ជនជាតិភាគតិច គឺជាក្រុមតូចនៃប្រជាពលរដ្ឋ ឬ ក្រុមអ្នកដែលត្រូវគ្រប់គ្រងរស់នៅក្នុងសហគមន៍មួយ ឬជាតិមួយ ដែលមានការខុសប្លែកពីគេដោយជាតិសាសន៍, សាសនា, ពណ៌សម្បុរ, ភេទ, ភាសា, កំណើត, វប្បធម៌, សញ្ជាតិ, ដើមកំណើតជាតិ, និន្នាការនយោបាយ ឬ មតិផ្សេងៗ ឬ ស្ថានភាពឯទៀត ។ ជនជាតិភាគតិចទាំងឡាយនៅក្នុងប្រទេសកម្ពុជាមានរួមដូចជា : ចាមិ, កញ្ជះ, វៀតណាម, ព្រៅ, ចិន, លូន, ចាម, អ្នកកាន់សាសនាយេស៊ូ, ស្ត្រី, អ្នកក្រ សមាជិកនៃគណៈបក្សនយោបាយប្រឆាំង ។ល។ ទុកជាភាពប្រកាន់រើសអើង កាលណាគ្មានការយកចិត្តទុកដាក់គិតគូរ ដោយមានការចែកវណ្ណៈខុសគ្នា, ដោយការទាត់ចោល ឬ ដោយមានកម្រិតប្រឆាំងនឹងបុគ្គលម្នាក់ ឬ ក្រុមនៃប្រជាពលរដ្ឋដូចជាជនជាតិភាគតិចជាដើម ។ ទម្រង់នៃការរើសអើងណាមួយដែលប្រឆាំងនឹងជនជាតិភាគតិចនានា រួមទាំងការរើសអើងលើអ្នកដែលមានសិទ្ធិអាចបោះឆ្នោតស្របច្បាប់ គឺជាឧបសគ្គដែលធ្វើឱ្យការបោះឆ្នោតមិនយុត្តិធម៌ និង សេរី ដោយហេតុនេះប្រទេសនោះមិនអាចប្រកាសអះអាងថាខ្លួនឯងហ្នឹងជាអ្នកកាន់ប្រជាធិបតេយ្យពិតប្រាកដបានទេ ។ បើសិនជាការរើសអើងត្រូវបានអនុញ្ញាតឱ្យកើតមានក្នុងដំណើរការបោះឆ្នោត នុះលទ្ធផលនៃការបោះឆ្នោតនឹងមានភាពទុច្ចរិត ហើយដែលអាចនាំឱ្យគេចាត់ទុកការបោះឆ្នោតនោះជាមោឃៈ និងនាំឱ្យដំណើរការប្រជាធិបតេយ្យទាំងអស់ក្នុងការគ្រប់គ្រងគ្មានលំនឹង ។ មានតែប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាទេដែលអាចបោះឆ្នោតបាន ។ ដោយហេតុនេះ គេត្រូវតែសង្កត់ធ្ងន់ទៅលើការកុំឱ្យមានអំពើរើសអើងលើជនជាតិភាគតិចនៅក្នុងដំណើរការពិនិត្យឱ្យចូលសញ្ជាតិជាខ្មែរ ។ តទៅនេះ គឺជាច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាដែលការពារប្រឆាំងនឹងការរើសអើង :

* មាត្រា ៣១ កថាខ័ណ្ឌ ២ នៃរដ្ឋធម្មនុញ្ញ ( មានរៀបរាប់ខាងដើមរួចមកហើយ )

* មាត្រា ៦១ កថាខ័ណ្ឌ ១ នៃច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌរបស់ឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់ដែលមានចែងថា :

*" ១_ ជនណា តាមមធ្យោបាយណាមួយ ដូចមានចែងក្នុងមាត្រា ៥៩ ដែលបានញុះញង់ឱ្យមានសម្អប់ជាតិ, ពូជសាសន៍ ឬសាសនា ដែលជាការញុះញង់ដោយមានការរើសអើង, អរិភាព (១) ឬ ហិង្សា នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ខែ ទៅ ១ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពី ១.០០០.០០០ ទៅ ១០.០០០.០០០រៀល ឬផ្តន្ទាតែទោសណាមួយនៃទោសទាំងពីរនេះក៏បាន ។ "*

* មាត្រា ៥៩ នៃច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌរបស់ឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់ មានចែង :

*" នឹងត្រូវផ្តន្ទាទោសពីបទសមគំនិត ក្នុងអំពើដែលចាត់ទុកជាបទឧក្រិដ្ឋតាមបទបញ្ញត្តិនេះជនទាំងឡាយណាដែល តាមរយៈសន្ទរកថា, តាមសម្រែក ឬ ការគំរាមកំហែង បន្លឺឡើងក្នុងកន្លែងនានាឬ ក្នុងទីប្រជុំជនសាធារណៈ, តាមការសរសេរ, ការបោះពុម្ព, គំនូរ, ចម្លាក់, វិចិត្រកម្ម, និម្មិតរូប, រូបភាព ឬគ្រប់ការតាំងនៃការសរសេរ, សំដី ឬរូបភាព ដែលដាក់លក់ ឬដាក់តាំងនៅកន្លែងនានា ឬក្នុងទីប្រជុំជនសាធារណៈ, តាម*

---

(១) អរិភាព = ភាពអមិត្រ, ភាពជាសត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំងបដា ឬមធ្យោបាយប្រកាសដែលតាំងនៅសាធារណៈជនឃើញ, តាមគ្រប់មធ្យោបាយទំនាក់ទំនងសោតទស្សនៈ បានចម្លងដោយផ្ទាល់ដោយមនុស្សម្នាក់ ឬច្រើននាក់ ប្រព្រឹត្តអំពើទុច្ចរិតបែបនេះ បើការញុះញង់នោះបានសំរេច ។

លក្ខន្តិកៈនេះអាចអនុវត្តបានដែរ កាលណាការញុះញង់នោះបានជាលទ្ធផលត្រឹមតែការប៉ុនប៉ងប្រព្រឹត្តអំពើឧក្រិដ្ឋប៉ុណ្ណោះ ។ ”

* មាត្រា ២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយចែងថា :

“ ដោយពុំយោងទៅលើចំណុចផ្សេងៗក្នុងមាត្រា២ និងដោយគ្មានការហាមប្រាម ដែលពុំសមហេតុផល ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ និងមានលទ្ធភាពក្នុងការ :

ក_ ចូលរួមក្នុងកិច្ចការដឹកនាំនៃការងារសាធារណៈ ដោយផ្ទាល់ខ្លួនក្តីតាមរយៈតំណាងដែលខ្លួនជ្រើសរើសដោយសេរីក្តី ។

ខ_ បោះឆ្នោតឬឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោតទៅតាមកាលៈទេសៈដែលបានកំណត់ទុកយ៉ាងត្រឹមត្រូវ។ ពិធីបោះឆ្នោតនេះត្រូវមានលក្ខណៈជាសាកល សិទ្ធិស្មើគ្នាក្នុងការបោះឆ្នោត គឺឆ្នោតដែលបោះត្រូវលាក់ការជាសម្ងាត់ ដើម្បីធានាឱ្យមានការសំដែងមតិដោយសេរីអំពីសំណាក់អ្នកបោះឆ្នោត ។

គ_ មានសិទ្ធិស្មើៗគ្នាជាទូទៅក្នុងកិច្ចទាក់ទងជាមួយក្រសួងរដ្ឋបាលដែលបំរើសាធារណជនក្នុងប្រទេសខ្លួន ។ ”

* មាត្រា ២៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយចែងថា :

“ នៅចំពោះមុខច្បាប់ មនុស្សគ្រប់រូបមានសិទ្ធិស្មើៗគ្នា ហើយក៏មានសិទ្ធិទទួលកិច្ចការពារអំពីច្បាប់យ៉ាងស្មើគ្នាដោយឥតប្រកាន់ពូជសាសន៍ ឬពណ៌សំបុរឡើយ ។ ក្នុងករណីនេះច្បាប់ហាមមិនឱ្យមានការប្រកាន់ពូជសាសន៍ ហើយច្បាប់ធានាជូនបុគ្គលគ្រប់រូបនូវបញ្ញត្តិការពារយ៉ាងស័ក្តិសិទ្ធិ កុំឱ្យមានការប្រកាន់ទៅលើពូជសាសន៍ ពណ៌សំបុរ ភេទ សាសនាភាសា ជំហរនយោបាយ មតិនានា កំណើតជាតិ ឬ សង្គម ឋានៈ វណ្ណៈ ឬអ្វីផ្សេងៗទៀតឡើយ ។ ”

- ការបោះឆ្នោតសម្ងាត់

ការបោះឆ្នោតសម្ងាត់ គឺជាតម្រូវការចាំបាច់មួយទៀតដើម្បីការពារដំណើរការបោះឆ្នោតកុំឱ្យមានការបំភិតបំភ័យ ។ ក្នុងការឱ្យមានកិច្ចបោះឆ្នោតដោយសេរីពិតប្រាកដ សម្លេងក្នុងសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតគឺត្រូវដឹងតែសាមីខ្លួនប៉ុណ្ណោះ លើកលែងតែអ្នកបោះឆ្នោតជ្រើសរើសប្រាប់សម្លេងនោះទៅអ្នកដទៃដោយខ្លួនឯង ។ ការបោះឆ្នោតត្រូវប្រព្រឹត្តឡើងដោយកំបាំងពីភ្នែកអ្នកដទៃ ( គ្មានជនណាម្នាក់អាចមើលឃើញថា តើអ្នកបោះឆ្នោតបោះបញ្ចេញយោបល់ដូចម្តេចឡើយ ) ហើយគ្មានអ្នកបោះឆ្នោតណាម្នាក់ត្រូវទទួលការបង្ខិតបង្ខំពីសំណាក់អាជ្ញាធរផ្លូវច្បាប់ ឬ អាជ្ញាធររាជរដ្ឋាភិបាលឱ្យប្រាប់ថាខ្លួនបោះឆ្នោតយ៉ាងណាៗនោះឡើយ ។

តទៅនេះ គឺជាច្បាប់អន្តរជាតិនៃសិទ្ធិមនុស្សដែលទទួលស្គាល់ដោយច្បាប់ព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយលើកស្ទួយ និង ការពារសិទ្ធិនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

* មាត្រា ២៥ កថាខ័ណ្ឌ ខ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ មានចែងថា :

*" ខ_ បោះឆ្នោតឬឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោតទៅតាមកាលៈទេសៈដែលបានកំណត់ទុកយ៉ាងត្រឹមត្រូវ ។ ពិធីបោះឆ្នោតនេះត្រូវមានលក្ខណៈជាសាកល សិទ្ធិស្មើគ្នាក្នុងការបោះឆ្នោត ពីឆ្នោតដែលបោះត្រូវលាក់ការធានាថាការសម្ងាត់ដើម្បីធានាឱ្យមានការសំដែងមតិដោយសេរីអំពីសំណាក់អ្នកបោះឆ្នោត ។ "*

* តម្រូវការទូទៅដើម្បីអោយមានការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌ :

_ បើកសិក្ខាសាលាបង្រៀនអប់រំការបោះឆ្នោតដល់ប្រជាពលរដ្ឋទូទៅ ។

_ ការពារសន្តិសុខផ្លូវឆ្លើបឆ្នោតមុនពេលបោះឆ្នោត កំពុងបោះឆ្នោត ហើយនិង ក្រោយពេលបោះឆ្នោត ។

_ ត្រូវមានបញ្ជីជាផ្លូវការនៃអ្នកបោះឆ្នោត ហើយការពារយ៉ាងណាអោយប្រាកដថា ចំនួនសន្លឹកឆ្នោតបោះត្រូវស្មើនឹងចំនួនអ្នកបោះឆ្នោត ។

_ ក្រុមប្រឹក្សាធម្មនុញ្ញ ឬ គណៈកម្មការបោះឆ្នោត ត្រូវបញ្ជូនបេក្ខជនតំណាងរាស្ត្រណាដែលទិញសន្លឹកឆ្នោត ។

## _ *ការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌*

ការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌ទាំងឡាយជួយសម្រួលអោយមានប្រជាធិបតេយ្យគង់វង្ស និង ឱ្យប្រជាពលរដ្ឋសម្តែងនូវឆន្ទៈនយោបាយរបស់ខ្លួនឱ្យបានពេញលេញ ។ ដោយព្រះរាជាណាចក្រកម្ពុជា ជាប្រទេសប្រកាន់របបលទ្ធិប្រជាធិបតេយ្យសេរី ភាពស្របច្បាប់ពិតប្រាកដមែនទែនរបស់រាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ន និង អនាគត គឺផ្អែកទាំងស្រុងទៅលើការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌មួយៗតាមការកំណត់ និងត្រឹមត្រូវពេលវេលា ។ ប្រសិនណាសិទ្ធិជាគ្រឹះមួយមានបញ្ហាក់ខាងលើត្រូវបានគេលើកស្ទួយ និង គោរពហើយនោះ ព្រះរាជាណាចក្រកម្ពុជាអាចអះអាងថា រាជរដ្ឋាភិបាលរបស់ខ្លួនតំណាងស្របច្បាប់នូវឆន្ទៈនយោបាយរបស់ពលរដ្ឋតាមរយៈការបោះឆ្នោតដោយសេរី និង យុត្តិធម៌មែន ។ ភាពស្របច្បាប់នេះត្រូវបានទទួលស្គាល់ក្នុងមាត្រា ២១ កថាខ័ណ្ឌ ៣ នៃសេចក្តី ប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្សមានចែងថា :

*" ៣_ ឆន្ទៈរបស់ប្រជាពលរដ្ឋត្រូវបានទុកជាមូលដ្ឋាននៃអំណាចរបស់រដ្ឋាភិបាល ។ ឆន្ទៈទាំងនេះត្រូវសំដែងឡើងតាមរយៈនៃការបោះឆ្នោតជាសាកលនិងសម្ងាត់ ឬតាមនីតិក្រមសេរីទាំងឡាយដែលត្រូវរៀបចំតាមកាលវេលានិងយ៉ាងត្រឹមត្រូវផង ។ "*

www.budinst.gov.kh www.elibraryofcambodia.org

# កម្មវិធីមុខវិជ្ជាសំរាប់គ្រូបង្ហាត់នៃមេរៀនទី ៨

********

## តួនាទីរបស់ព្រះសង្ឃនៅក្នុងព្រះរាជាណាចក្រកម្ពុជា

### ១. គោលដៅ :

នៅចុងបញ្ចប់នៃមេរៀននេះ សមណសិស្ស និង សិក្ខាកាមអាចយល់ដឹង :

- អំពីតួនាទីទាំងឡាយរបស់ព្រះសង្ឃ
- អំពីការត្រួតត្រា និង ការថែរក្សាកុមារ
- អំពីការទាក់ទងពុទ្ធបរិស័ទជើងវត្ត
- អំពីកិច្ចការរដ្ឋដែលអាចជួយរដ្ឋបាន

### ២. ឯកសារយោង :

- ប្រកាសលេខ ៥ ចុះថ្ងៃទី ៨ មេសា ១៩៩៩

### ៣. សម្ភារៈសិក្សា

- ក្រដាសធំភ្លឺសំរាប់បញ្ចាំងលើផ្ទាំងក្រណាត់ស
- ក្រដាសផ្ទាំងធំ និង ឧបករណ៍សរសេរ
- ក្តារខៀន និង ដីស
- មេរៀនលាយលក្ខណ៍អក្សរ

### ៤. លំហាត់

- តើក្មេងវត្តមានសារៈសំខាន់ចំពោះសាសនា និង ប្រទេសជាតិដូចម្តេចខ្លះ ?
- តើព្រះសង្ឃ និង ព្រះពុទ្ធបរិស័ទជើងវត្ត ត្រូវមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេចខ្លះ ?
- តើពាក្យវត្តអារាមមានន័យដូចម្តេចខ្លះ ?
- តើព្រះពុទ្ធសាសនាចាត់ទុកជា ផ្នែកនៃរដ្ឋាភិបាល ឬ ក៏ជាអង្គការក្រៅរដ្ឋាភិបាល ?
- ពាក្យថា «ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ » តើមានន័យដូចម្តេចខ្លះ ?

www.budinst.gov.kh www.elibraryofcambodia.org

# ៥_ មេរៀនទី ៨: តួនាទីរបស់ព្រះសង្ឃនៅក្នុងព្រះរាជាណាចក្រកម្ពុជា

## ក_ តួនាទីរបស់ព្រះសង្ឃ (៤០នាទី)

គ្រូបង្ហាត់ត្រូវចែកជាក្រុម ដោយឱ្យក្រុមនីមួយៗបញ្ចេញយោបល់ហើយកត់ទុកលើក្រដាសផ្ទាំងធំ ឬ ក្ដារខៀន រួចហើយឱ្យតំណាងក្រុមនីមួយៗរាយការណ៍ចំពោះវគ្គទាំងមូល ។ កាលណាមានការខ្វះខាត គ្រូបង្ហាត់ត្រូវបន្ថែមឱ្យមានដូចក្នុងក្រដាសធំភ្ជាប់ដែលបញ្ចាំងលើក្រណាត់ផ្ទាំងស ។ គ្រូបង្ហាត់ត្រូវបិទក្រដាសបញ្ជីតួនាទីរបស់ព្រះសង្ឃនេះទុកនៅក្នុងថ្នាក់ ។ គ្រូបង្ហាត់ត្រូវពន្យល់បន្ថែមនូវពាក្យ « នាយកធម៌ និង បាដិមោក្ខ » ដោយអានសេចក្ដីពន្យល់ដែលមាននៅខាងក្រោមមេរៀន ។

## ខ_ តួនាទីរបស់ព្រះសង្ឃខ្លះដែលលើកយកមកធ្វើអត្ថាធិប្បាយក្នុងមេរៀននេះ (៤០នាទី)

### ខ_១_ ការត្រួតត្រា និង ការថែរក្សាកុមារដែលអាស្រ័យនៅក្នុងវត្ត

គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន ហើយបើកឱ្យសិស្សសួរបញ្ហា ដោយឱ្យមានការពិភាក្សារកខុសរកត្រូវផង ។

### ខ_២_ ទំនាក់ទំនងជាមួយអាណាព្យាបាល និង ឪពុកម្ដាយ និង ការណែនាំអប់រំ

គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន ហើយបើកឱ្យសិស្សសួរបញ្ហាដោយឱ្យមានការពិភាក្សារកខុសរកត្រូវផង

---

សម្រាក ២០នាទី

---

## គ_ ការទាក់ទងនឹងពុទ្ធបរិស័ទជើងវត្ត (៤០នាទី)

គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន ហើយបើកឱ្យសិស្សសួរបញ្ហាដោយឱ្យមានការពិភាក្សារកខុសរកត្រូវផង ។

## ឃ_ ការជួយកិច្ចការរដ្ឋដែលអាចជួយរដ្ឋបាន (៤០នាទី)

គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន ហើយបើកឱ្យសិស្សសួរបញ្ហាដោយឱ្យមានការពិភាក្សារកខុសរកត្រូវផង ។ ពេលអានមកដល់ត្រង់ការកម្ពុជាតទៅនេះ គ្រូបង្ហាត់ត្រូវឈប់ហើយពិភាក្សាបំផុសគំនិតដោយឱ្យសមណសិស្ស និង សិក្ខាកាម បញ្ចេញយោបល់លើកិច្ចការនានានៅក្នុងចង្កោមនីមួយៗដែលមាននៅក្នុងមេរៀននេះ ។ បើសិនជាសមណសិស្ស និង សិក្ខាកាមបញ្ចេញយោបល់អំពីកិច្ចការជួយប្រជាពលរដ្ឋមិនទាន់គ្រប់គ្រាន់ទេ គ្រូបង្ហាត់ត្រូវតែលើកជាឧទាហរណ៍បន្ថែមទៀត រួច ហើយពិភាក្សារកខុសរកត្រូវ ។

---

www.budinst.gov.kh www.elibraryofcambodia.org

# មេរៀនទី ៨

# តួនាទីរបស់ព្រះសង្ឃ

# នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## ក_ តួនាទីរបស់ព្រះសង្ឃ

តាមប្រកាសលេខ ៩ ចុះថ្ងៃទី ៨ មេសា ១៩៨៩ ព្រះសង្ឃនៃព្រះពុទ្ធសាសនាទទួលតួនាទីបំពេញភារកិច្ចដូចតទៅនេះ :

១_ ការថែទាំវត្តអារាម

២_ ការថែទាំវត្ថុជាតរុក្ខ

៣_ ការបំពេញនាយកធម៌ (១) ឱ្យមាននៅក្នុងខ្លួន ព្រមទាំងឱ្យចេះបាតិមោក្ខ (២) ជាញឹកញួង

៤_ ការត្រួតត្រា និង ថែរក្សាកុមារដែលអាស្រ័យនៅក្នុងវត្ត

៥_ ការទាក់ទងនឹងពុទ្ធបរិស័ទជើងវត្ត

៦_ ការទាក់ទងនឹងគណសង្ឃ

៧_ ការជួយកិច្ចការដែលអាចជួយបាន ។

## ខ_ តួនាទីរបស់ព្រះសង្ឃខ្លះដែលលើកយកមកធ្វើអត្ថាធិប្បាយក្នុងមេរៀននេះ

### ខ_១_ *ការត្រួតត្រា*(៣) *និង ថែរក្សាកុមារដែលអាស្រ័យនៅក្នុងវត្ត ( ករណីយកិច្ចទី ៤ )*

យោងតាមប្រវត្តិពីអតីតកាល វត្តអារាមខ្មែរជាមជ្ឈមណ្ឌលកុមាររបស់សហគមន៍នីមួយៗ ដែលមានជាអាទិ៍ សាលាវត្តសំរាប់កុមាររៀនអាន និង សរសេរ, មានសាលាបឋមសិក្សាអក្សរផ្ចង់ ( សាលារដ្ឋ ), សាលាអក្សរមូល ( រៀនមើលសាស្ត្រាស្លឹករឹត និង រៀនធម៌ដើម្បីសាងព្រះផ្នួស ឬ បន្តរៀនសាលាបាលីជាន់ខ្ពស់ ), មានសាលាវិជ្ជាជីវៈខ្លះៗទៀត ។ កុមារដែលអាស្រ័យនៅក្នុងវត្តអារាមមានតួនាទីសំខាន់ណាស់ ក្នុងការរៀនសូត្រយកចំណេះខ្លួនឯង ដើម្បីបំរើព្រះពុទ្ធសាសនា និង ជាតិទៅអនាគត ។ ដូចនេះ ការទទួលកុមារទាំងឡាយឱ្យស្នាក់នៅក្នុងវត្តអារាមជាភារកិច្ចចម្បងរបស់ព្រះសង្ឃ ដើម្បីជួយលើកស្ទួយចំណេះដឹងរបស់កុមារ ដែលជាទំពាំងស្នងឫស្សីរបស់ព្រះពុទ្ធសាសនា និង ជាតិ ។

---

(១) នាយកធម៌ ( តាមវចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត ) = ធម៌របស់នាយក គឺធម៌សម្រាប់មេកនាំ ឬ អ្នកត្រួតត្រាអ្នកដទៃ, បុគ្គលក្ដី ជាពុទ្ធជិតក្ដី គ្រហស្ថក្ដី ដែលធ្វើជាប្រធាន ត្រួតត្រាលើអ្នកដទៃ គប្បីមាននាយកធម៌ ៦យ៉ាង ប្រចាំក្នុងសន្ដានជានិច្ច គឺ ១_ ខមា : សេចក្ដីអត់ធន់. ២_ ជាគរិយៈ : សេចក្ដីភ្ញាក់រលឹករឿយៗ. ៣_ ឧដ្ឋាន : សេចក្ដីឧស្សាហ៍ខ្នះខ្នែង. ៤_ សំវិភាគ : ការចែករំលែក. ៥_ ទយា : សេចក្ដីអាណិតអាសូរប្រណីគេ. ៦_ ឥក្ខណា : ការរិះរកមើលខុសត្រូវ ។ រីនាយកធម៌ទាំងប្រាំមួយនេះឯងតែងលើកស្ទួយឱ្យនាយកមានតម្លៃ ។

(២) បាតិមោក្ខ ( តាមសៀវភៅព្រះធម៌ទម្ពីករបស់ឧត្តមញ្ញោភិក្ខុ ហ. មណីចិន្ដា ) ថា : គឺជាច្បាប់ ឬ ធម្មនុញ្ញដែលព្រះភិក្ខុសង្ឃត្រូវសិក្សា និង អនុវត្តតាមជានិច្ច ជាទីប្រជុំនូវសិក្ខាបទទាំង ២២៧ ។ បើប្រៀបធៀបមកខាងអាណាចក្រ គឺរដ្ឋធម្មនុញ្ញដែលជាទីប្រជុំនៃបណ្ដាច្បាប់ទាំងឡាយ ដែលមានសំរាប់ការគ្រប់គ្រងប្រទេស ។

(៣) ត្រួតត្រានៅក្នុងអត្ថបទនេះមានន័យថា ការគ្រប់គ្រង ។

www.budinst.gov.kh www.elibraryofcambodia.org

១_២_ *<u>ទំនាក់ទំនងព្រះសង្ឃជាមួយអាណាព្យាបាល ឬ ឪពុកម្ដាយកុមារ និង ការណែនាំអប់រំ</u>*

ដើម្បីរក្សាសេចក្ដីថ្លៃថ្នូររបស់វត្តអារាម ដែលជាទីតំណាងនូវវប្បធម៌ និង អរិយធម៌ខ្មែរព្រះសង្ឃគប្បី ទទួលយកកុមារទាំងឡាយឱ្យមកស្នាក់អាស្រ័យនៅក្នុងវត្ត ដោយឱ្យមានឪពុកម្ដាយ ឬ អាណាព្យាបាលរបស់កុមារ ទាំងនោះនាំមកប្រគេនផ្ញើឱ្យស្នាក់នៅជាមុនសិនបើអាចធ្វើបាន ។

កាលណាកុមារនោះបានទទួលការអនុញ្ញាតពីព្រះគ្រូចៅអធិការវត្តហើយ ព្រះអង្គមេកុដិគប្បីជួយមើល ខុសត្រូវឱ្យមានវិន័យសមស្របជាកុមារនៃព្រះពុទ្ធសាសនាខ្មែរ ដូចជា ការហាត់រៀនសូត្រធម៌, ការរៀនសូត្រវិជ្ជា ទូទៅ, ការជួយកិច្ចការក្នុងវត្ត, ការជួយបំរើព្រះសង្ឃ និង ការជួយកុមារគ្នាឯងទៅវិញទៅមក ។

## គ_ <u>ការទាក់ទងនឹងពុទ្ធបរិស័ទជើងវត្ត ( ករណីយកិច្ចទី ៥ )</u>

ព្រះសម្មាសម្ពុទ្ធទ្រង់តែងតែផ្ដាំផ្ញើទៅដល់ពុទ្ធបរិស័ទទាំង៤ពួក ដើម្បីឱ្យថែរក្សាសាសនារបស់ព្រះអង្គឱ្យបានគង់វង្ស ទៅអនាគតគឺ :

១_ ព្រះភិក្ខុសង្ឃ
២_ ព្រះភិក្ខុនី
៣_ ឧបាសក
៤_ ឧបាសិកា ។

ដូចនេះ ដើម្បីអាចថែរក្សា និង លើកតម្កើងព្រះពុទ្ធសាសនាឱ្យចំរុងចំរើនបាន លុះត្រាតែពុទ្ធបរិស័ទទាំងបួនពួក នេះមានសមត្ថភាពគ្រប់គ្រាន់ទាំងផ្លូវកាយ ផ្លូវចិត្ត ហើយនិងទ្រព្យសម្បត្តិផង ។ មានន័យថា ព្រះសង្ឃត្រូវជួយលើកតម្កើង ជីវភាពរបស់ពុទ្ធបរិស័ទដែលអាចធ្វើបាន ដូចជា ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច អភិវឌ្ឍន៍សហគមន៍ និងការពារបរិស្ថានជាដើម។ ឯពុទ្ធបរិស័ទវិញ ក៏នឹងជួយផ្គត់ផ្គង់នូវបច្ច័យទាំងបួនទៅតាមសមត្ថភាពរបស់ខ្លួនដល់ព្រះសង្ឃព្រះពុទ្ធសាសនាវិញដែរ ។ កាលណាឧបាសក ឧបាសិកា មានសមត្ថភាពគ្រប់គ្រាន់ខាងផ្លូវកាយ ផ្លូវចិត្ត ផ្លូវបញ្ញា និងទ្រព្យសម្បត្តិសមល្មមហើយ វត្តអារាមមុខតែរីកចំរើនជាពុំខាន ។

ឧទាហរណ៍ :

- ធ្វើឱ្យវត្តអារាមទៅជាមជ្ឈមណ្ឌលផ្ដល់ព័ត៌មាន
- ធ្វើឱ្យវត្តអារាមទៅជាមជ្ឈមណ្ឌលផ្ដល់សេវាកម្មជំនួយ ។ល។

( វិជ្ជាសង្គមកិច្ចខាងលើនេះនឹងលើកយកមកបង្រៀននៅពេលក្រោយក្នុងមេរៀនទី ១០ ) ។

## ឃ_ <u>ការជួយកិច្ចការរដ្ឋដែលអាចជួយបាន ( ករណីយកិច្ចទី ៧ )</u>

តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ហើយបាវចនារបស់រដ្ឋក៏បានបញ្ជាក់ថា " ជាតិ សាសនា ព្រះមហាក្សត្រ " ថែមទៀតដែរ ។ ព្រះសង្ឃព្រះពុទ្ធសាសនាមានតួនាទីសំខាន់ណាស់ ដើម្បីជួយកិច្ចការរដ្ឋដែលអាចជួយបាន ពីព្រោះជាតិ សាសនា ព្រះមហាក្សត្រ ត្រូវការឧបត្ថម្ភ និង ជួយគ្នាទៅវិញទៅមក ដើម្បីសេចក្ដីរីកចំរើនទៅអនាគតទាំងផ្លូវលោក និង ផ្លូវធម៌ ។ កាលណាពុទ្ធបរិស័ទចំរុងចំរើន រដ្ឋក៏ចំរុងចំរើន ហើយព្រះពុទ្ធសាសនាក៏ទៅតាមនោះដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

ការជួយកិច្ចការរដ្ឋព្រះសង្ឃអាចធ្វើបាន មានជាឧទាហរណ៍ដូចជា :

- ខាងផ្នែកអភិវឌ្ឍន៍សហគមន៍ : ជួយដឹកនាំ និង ចូលរួមក្នុងការសាងសង់សាលារៀន, សង់ផ្លូវថ្នល់, សង់ស្ពាន, ជីកស្រះ, ឈើកទំនប់, ជីកប្រឡាយ, សង់មន្ទីរពេទ្យ ............ ។ល។ និង ។ល។ និង ចូលរួមជួយណែនាំឱ្យពរក្នុងកិច្ចអាពាហ៍ពិពាហ៍ និង ណែនាំពុទ្ធបរិស័ទឱ្យប្រព្រឹត្តតែអំពើល្អ ។ល។ ;
- ខាងផ្នែកបរិស្ថាន : បណ្ដុះកូនឈើតាមវត្តអារាមដើម្បីបាំងុះ ក្នុងទីវត្តអារាម និង កន្លែងសាធារណៈ, ការពារសត្វមានជីវិត ហើយនិងធ្វើការអភិវឌ្ឍន៍អ្វីៗត្រូវជួយការពារបរិស្ថានផង ។ តាមធម៌ព្រះពុទ្ធដើម្បីឱ្យមានប្រសិទ្ធិភាព, ត្រូវកសាងវត្តដើម្បីធ្វើជាអារាមឱ្យសមស្របទៅនឹងពាក្យថាវត្តអារាម ។ល។ និង ។ល។
- ខាងផ្នែកអប់រំ : សម្ដែងធម៌ទេសនាអប់រំដល់ពុទ្ធបរិស័ទដើម្បីដឹកនាំឱ្យប្រកបតែការងារត្រឹមត្រូវសម្រាប់ចិញ្ចឹមជីវិតតាមមាគ៌ានៃព្រះពុទ្ធសាសនា, ឱ្យចេះស្រលាញ់រាប់អានគ្នាជាបងប្អូន និង ឱ្យចេះអត់អោនគ្នាកាលណាមានយោបល់ផ្ទុយគ្នាដែលសមស្របទៅតាមការលើកតម្កើងនៃសិទ្ធិមនុស្ស, ឱ្យចេះសង្គ្រោះគ្នាទៅវិញទៅមក ចៀសវាងការប្រើអំពើហិង្សា កាប់សម្លាប់គ្នា ដែលផ្ទុយពីសីលធម៌នៃព្រះពុទ្ធសាសនា ។

www.budinst.gov.kh www.elibraryofcambodia.org

# កម្មវិធីមុខវិជ្ជាសំរាប់គ្រូបង្ហាត់នៃមេរៀនទី ៩

*********

# តួនាទីរបស់រាជការនៅក្នុងរដ្ឋប្រជាធិបតេយ្យ

## ១. គោលដៅ :

នៅចុងបញ្ចប់នៃមេរៀននេះ សមណសិស្ស និង សិក្ខាកាមអាចយល់ដឹង :

- អំពីបុគ្គលិកភាពនៃមន្ត្រីរាជការ ។
- អំពីតួនាទីរបស់មន្ត្រីរាជការ តាមទស្សនៈមនុស្សធម៌ និង ព្រះធម៌ព្រះពុទ្ធសាសនា ។
- អំពីទសពិធរាជធម៌ និង ព្រហ្មវិហារធម៌ ។

## ២. ឯកសារយោង :

- គម្ពីរអភិធម្មព្រះត្រៃបិដក
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

## ៣. សម្ភារៈសិក្សា

- ក្រដាសជ័រភ្លឺសំរាប់បញ្ចាំងលើផ្ទាំងក្រណាត់ស
- ក្តារខៀន និង ដីស
- ក្រដាសផ្ទាំងធំ និង ឧបករណ៍សរសេរ
- មេរៀនដោយលក្ខណ៍អក្សរ

## ៤. លំហាត់

- តើភារកិច្ចរបស់មន្ត្រីរាជការមានអ្វីខ្លះ ?
- តើអ្នកដឹកនាំណាដែលប្រកបដោយទសពិធរាជធម៌អាចចាត់ជាព្រះបាទធម្មិកបានទេ ? ពីព្រោះអ្វី ?
- តើនយោបាយក្នុងការទទួលខុសត្រូវ និង តម្លាភាពមានសារៈសំខាន់យ៉ាងដូចម្តេចខ្លះ ?

www.budinst.gov.kh www.elibraryofcambodia.org

## ៥_ មេរៀនទី ៩ : តួនាទីរបស់មន្ត្រីរាជការនៅក្នុងរដ្ឋប្រជាធិបតេយ្យ

### ក_ និយមន័យនៃពាក្យថា មន្ត្រីរាជការ (៤០នាទី)

- គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន រួចហើយបើកឱ្យសិស្សសួរបញ្ជាក់ ។
- គ្រូបង្ហាត់ត្រូវពន្យល់បន្ថែមនូវពាក្យ « ស្ថាប័ន, វិជ្ជាស្ថាន, អង្គការ » ដោយមានលើកជាឧទាហរណ៍ផង។
- គ្រូបង្ហាត់ត្រូវពន្យល់បន្ថែមត្រង់ចំណុចថា « ជាអ្នកអនុវត្ត និង ជាអ្នកយកច្បាប់ទៅឱ្យគេអនុវត្ត » ដោយមានលើកជាឧទាហរណ៍ផង ។

### ខ_ តើតួនាទីរបស់មន្ត្រីរាជការស៊ីវិលមានអ្វីខ្លះនៅក្នុងរដ្ឋប្រជាធិបតេយ្យ ? (៤០នាទី)

- គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន ហើយបើកឱ្យសិស្សសួរបញ្ជាក់ ។
- គ្រូបង្ហាត់ត្រូវពន្យល់បន្ថែមនូវចំណុចថា « បំរើផលប្រយោជន៍, សេចក្តីប៉ងប្រាថ្នា និង សេចក្តីត្រូវការនៃជីវិត » ចំណុចថា « ជាអ្នកការពារច្បាប់នៃកម្មសិទ្ធិជន » ។

---

សម្រាក ២០នាទី

---

### គ_ គោលការណ៍តាមផ្លូវសាសនាស្តីពីលក្ខណៈនៃបុគ្គលបំរើសង្គម (៤០នាទី)

គ_១_ ខាងក្រោមនេះ គឺជាទសពិធរាជធម៌

- គ្រូបង្រៀនត្រូវអត្ថាធិប្បាយមេរៀន ហើយបើកឱ្យសិស្សសួរបញ្ជាក់ ។
- កាលណានាំមកដល់ទសពិធរាជធម៌ គ្រូបង្ហាត់ត្រូវដាក់ក្រដាសជ័រភ្លឺបញ្ចាំងលើក្រណាត់ស ឬ សរសេរលើក្តារខៀននូវព្រះធម៌ទាំងនោះ ហើយពន្យល់បន្ថែមត្រង់ចំណុចថា « គឺសំដៅដល់អ្នកចាត់ចែងកិច្ចការទូទៅគ្រប់ជាន់ថ្នាក់ទាំងអស់ » ។ គ្រូបង្ហាត់ត្រូវពន្យល់បន្ថែមអំពីព្រះធម៌ « តបះ » និង ត្រង់ចំណុចថា « ព្រះបាទធម្មិក » ។

គ_២_ ព្រហ្មវិហារធម៌

- គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀនលើក្រដាសជ័រភ្លឺ ដែលបញ្ចាំងលើផ្ទាំងក្រណាត់ស ឬ លើក្តារខៀន រួចហើយបើកឱ្យសិស្សសួរបញ្ជាក់ ។
- គ្រូបង្ហាត់ត្រូវពន្យល់បន្ថែម ត្រង់ចំណុចថា « ដើម្បីរក្សាតម្លៃ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស» ។

www.budinst.gov.kh www.elibraryofcambodia.org

## ឃ_ ការទទួលខុសត្រូវ និង តម្លាភាព (១០នាទី)

- គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន រួចហើយបើកឱ្យសិស្សសួរបញ្ជាក់ ។
- គ្រូបង្ហាត់ត្រូវពន្យល់បន្ថែមត្រង់ចំណុច « ពីត្រូវមានការទទួលខុសត្រូវ », ពាក្យថា « តម្លាភាព » បង្កើនគុណភាពការងារ(វិជ្ជាជីវៈពិតប្រាកដ), ដើម្បីឱ្យមានពត៌មានជាសាធារណៈ, ឱ្យមើងថារដ្ឋធ្វើអ្វីខ្លះ ?។

## ង_ ហេតុអ្វីបានជាមន្ត្រីរាជការត្រូវអនុវត្ត និង គោរពច្បាប់ក្នុងស្រុក និង ច្បាប់សិទ្ធិមនុស្សអន្តរជាតិ (៣០នាទី)

- គ្រូបង្ហាត់ត្រូវចែកសមណសិស្ស ឬសិក្ខាកាមជាក្រុម ហើយឱ្យក្រុមនីមួយៗបញ្ចេញយោបល់លើក្រដាសផ្ទាំងធំ រួចហើយឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ចំពោះមុខវគ្គទាំងមូល ។ គ្រូបង្ហាត់គួរបើកការពិភាក្សារកខុសរកត្រូវ ហើយបន្ថែមបន្ថយនូវចំណុចណាដែលខ្វះខាតដើម្បីរាយមានមួយក្នុងមេរៀននេះ ។ គ្រូបង្ហាត់ត្រូវកត់ត្រាទុកនូវយោបល់ណាដែលសមស្រប ដើម្បីយកមកបន្ថែមនៅក្នុងមេរៀនដើម្បីលំអរថែមទៀត ។
- គ្រូបង្ហាត់ត្រូវបិទក្រដាសផ្ទាំងធំនៃចម្លើយទាំងនោះនៅក្នុងថ្នាក់ ។

---

www.budinst.gov.kh www.elibraryofcambodia.org

# មេរៀនទី ៩

# តួនាទីរបស់មន្ត្រីរាជការនៅក្នុងរដ្ឋប្រជាធិបតេយ្យ

## ក_ អ្នកណាខ្លះជាមន្ត្រីរាជការ ?

មន្ត្រីរាជការ គឺជាពលរដ្ឋដែលធ្វើការនៅក្នុងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ក្រសួង ឬ វិទ្យាស្ថាននានា។ នេះរាប់បញ្ចូលទាំងមន្ត្រីនយោបាយនានាចាប់តាំងពីថ្នាក់ខ្ពស់រហូតដល់ថ្នាក់ទាប, អ្នកដឹកនាំតាមនាយកដ្ឋាននានា, វេជ្ជបណ្ឌិត, បុគ្គលិកគ្រូពេទ្យនៅក្នុងមន្ទីរពេទ្យរដ្ឋ និង មណ្ឌលសុខភាពនានា, បុគ្គលិកសង្គមកិច្ច, គ្រូបង្រៀន ប៉ូលីស ហើយនិង បុគ្គលិកនៅក្នុងការិយាល័យនានារបស់រាជរដ្ឋាភិបាលថែមទៀត ។ សមាជិកដូចជាកងកម្លាំងប្រដាប់អាវុធ (កងរាជអាវុធហត្ថ) តុលាការ ហើយនិង អយ្យការរបស់រដ្ឋ មិនបានរាប់បញ្ចូលជាមន្ត្រីរាជការស៊ីវិលទេ ។ តែទោះបីជាយ៉ាងណាក៏ដោយនេះមិនមានន័យថា បុគ្គលិកទាំងនោះមិនអាចត្រូវគេរាប់បញ្ចូលទៅជាអ្នកបំរើសង្គមបានទេ ។ ផ្ទុយទៅវិញ បុគ្គលិកទាំងនោះត្រូវគេរំពឹងថា ខ្លួននឹងបំពេញករណីយកិច្ចទាំងឡាយក្នុងនាមជាអ្នកអនុវត្តន៍ដើម្បីការពារ និង គាំពាររដ្ឋធម្មនុញ្ញ ហើយនិងអនុវត្តច្បាប់ខ្មែរនីមួយៗ ។

## ខ_ តើតួនាទីរបស់មន្ត្រីរាជការស៊ីវិលមានអ្វីខ្លះនៅក្នុងសង្គមប្រជាធិបតេយ្យ ?

មន្ត្រីរាជការស៊ីវិលត្រូវបំរើផលប្រយោជន៍, សេចក្តីប៉ងប្រាថ្នា និង សេចក្តីត្រូវការនៃជីវិតរបស់ប្រជាពលរដ្ឋទាំងនេះជាភារកិច្ចដែលមន្ត្រីរាជការត្រូវតែបំរើដោយខានពុំបាន ។

តាមការពិតមន្ត្រីទាំងនោះគឺជាបុគ្គលដែលត្រូវទទួលស្គាល់ និង គោរពតាមគោលការណ៍នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ច្បាប់ក្នុងស្រុកនានា និង ច្បាប់អន្តរជាតិនៃសិទ្ធិមនុស្ស ។ បើសិនណាជាមន្ត្រីទាំងនេះគោរពច្បាប់ បទបញ្ញត្តិនានា និង ការពារកុំឱ្យមានការប្រើអំណាចដោយរំលោភដែលធ្វើឱ្យខូចប្រយោជន៍របស់ប្រជាពលរដ្ឋ នោះប្រជាពលរដ្ឋនឹងគោរព ហើយ មានការទុកចិត្តលើមន្ត្រីទាំងនោះជាពុំខាន ។

## គ_ គោលការណ៍តាមផ្លូវសាសនាស្តីពីលក្ខណៈនៃបុគ្គលិកបំរើសង្គម

ព្រះពុទ្ធសាសនាបានកំណត់បទដ្ឋានសំរាប់បុគ្គលិកបំរើសង្គម ដូចជាអ្នកដឹកនាំរដ្ឋ ខេត្ត ស្រុក រួមទាំងអ្នកទាំងឡាយណាដែលជ្រើសតាំងឱ្យធ្វើជាអ្នកដឹកនាំផង ។ គេរំពឹងថាមន្ត្រីទាំងនោះមានគុណសម្បត្តិខ្ពស់ ហើយមានការធ្វើពលិកម្ម មានចរិយាសម្បត្តិល្អ ហើយនិងមានភក្តីភាពចំពោះប្រជាពលរដ្ឋ និង ប្រទេសរបស់ខ្លួន ។

គ_១_ ខាងក្រោមនេះ គឺជាទសពិធរាជធម៌ដែលព្រះពុទ្ធអង្គបានប្រដៅទុកមកសម្រាប់មេដឹកនាំទាំងឡាយដើម្បីប្រតិបត្តិតាម :

១_ <u>ទានៈ</u>ចេះធ្វើអំណោយ ( គឺចេះជួយសង្គ្រោះគ្នា )

២_ <u>សីលៈ</u> ចេះធ្វើកាយ វាចា ចិត្ត ឱ្យសុចរិត ទៀងទាត់ យុត្តិធម៌ និង វៀរបង់អំពើអាក្រក់គ្រប់យ៉ាង ( មិនធ្វើអាក្រក់ )

www.budinst.gov.kh www.elibraryofcambodia.org

៣_ **បរិច្ចាគៈ** ចេះលះបង់សេចក្ដីកំណាញ់ ហើយបរិច្ចាគទ្រព្យសម្បត្តិ កសាងប្រយោជន៍សង្គម ប្រយោជន៍សាធារណៈ ( គឺមិនអាត្មានិយម )

៤_ **អាជ្ជវៈ** មានចិត្តត្រង់ ប្រកាន់សច្ចធម៌ ( គឺនិយាយបែបណា ធ្វើបែបនោះ )

៥_ **មទ្ទវៈ** ចេះបន្ទន់ឥរិយាបថ និង ចិត្តគំនិត ( គឺប្រើសំដីពីរោះ ផ្អែមល្ហែម )

៦_ **តបៈ**[1] ចេះព្យាយាមកំចាត់ចោលនូវសេចក្ដីអាក្រក់ចេញពីខ្លួន ( ទាំងកាយ វាចា ចិត្ត ) ហើយតាំងខ្លួនឱ្យនៅក្នុងអំពើល្អជានិច្ច ( គឺរាំងស្កាត់សេចក្ដីអាក្រក់ )

៧_ **អក្កោធៈ** មិនសំដែងអាការៈច្រងេងច្រងាង ទទឹងទាស់ (គឺមិនកំហៅក្រហាយអ្នកដទៃ )

៨_ **អវិហឹសា** មិនបៀតបៀនអ្នកដទៃ ( គឺមិនធ្វើឱ្យគេមានទុក្ខលំបាក ) ។

៩_ **ខន្តី** ចេះអត់ធ្មត់ ( អត់ធន់ )

១០_ **អវិរោធនៈ** មិនធ្វើអ្វីឱ្យខុសឆ្គងពីគន្លងច្បាប់ ( គឺគោរពប្រតិបត្តិតាមច្បាប់ជានិច្ច )

តាមទស្សនៈនៃព្រះពុទ្ធសាសនា ទសពិធរាជធម៌នេះពុំមែនសំដៅតែទៅលើព្រះមហាក្សត្រសោយរាជ្យនោះទេ គឺសំដៅដល់អ្នកចាត់ចែងសំរេចកិច្ចការទូទៅគ្រប់ជាន់ថ្នាក់ទាំងអស់ ។ ដោយហេតុនេះហើយបានជាខ្មែរតែងតែមានជំនឿថា កាលណាមានព្រះរាជាធម្មិកដឹកនាំប្រទេសណា ប្រទេសនោះឯងតែងមានសេចក្ដីរុងរឿងរីកចំរើន និង មានសន្តិភាព ។ ព្រះរាជាធម្មិកបានន័យថា អ្នកដឹកនាំណា ( មន្ត្រីរាជការ ) ដែលប្រកបដោយធម៌ដូចមានចែងក្នុងទសពិធរាជធម៌ខាងលើនេះ ។

គ_២_ អ្នកដឹកនាំ ដើម្បីឱ្យក្លាយទៅជាបុគ្គលបំរើសង្គមល្អប្រពៃ ព្រះពុទ្ធសាសនាប្រដៅថាត្រូវមានព្រហ្មវិហារធម៌ថែមទៀត ដែលមានដូចខាងក្រោមនេះ :

១_ មេត្តា : ផ្សាយសេចក្ដីរាប់អានទៅរកសព្វសត្វ ។
( អាណិតស្រឡាញ់ចង់ឱ្យគេបានសុខ ឱ្យដូចជាសេចក្ដីសុខដែលខ្លួនចង់បាន )

២_ ករុណា : ផ្សាយសេចក្ដីអាណិតទៅរកសព្វសត្វ ។
( ជួយសង្គ្រោះឱ្យគេរួចផុតពីសេចក្ដីទុក្ខដែលកើតពីវិបត្តិផ្សេងៗ )

៣_ មុទិតា : ផ្សាយអំណរទៅរកសព្វសត្វ ដែលបានសេចក្ដីសុខចំរើន ។
( មានចិត្តត្រេកអរនៅពេលដែលគេបានសុខហើយ )

៤_ ឧបេក្ខា : ផ្សាយសេចក្ដីស្មោះស្មើ ប្រាសចាកអគតិធម៌ទាំងបួនគឺ :
( តាំងចិត្តទៀងត្រង់ជាកណ្ដាល ប្រាសចាកអគតិធម៌ទាំងបួន )

៤_១_ ឆន្ទាគតិ : លំអៀងដោយស្រឡាញ់ ព្រោះលាភ ព្រោះនិយម ។

៤_២_ ទោសាគតិ : លំអៀងដោយស្អប់គំនួន ។

៤_៣_ ភយាគតិ : លំអៀងដោយភ័យខ្លាចអំណាចគេ ឬដើម្បីអំណាច ។

៤_៤_ មោហាគតិ : លំអៀងដោយល្ងិតល្ងង់មិនចេះច្បាប់ ឬមិនអនុវត្តច្បាប់ ។

---

(1) តបៈ តាមន័យសម្ដេចសង្ឃជួន ណាត ប្រែថា កាន់ឧបោសថសីល

www.budinst.gov.kh www.elibraryofcambodia.org

យោងតាមទស្សនៈព្រះពុទ្ធសាសនា មន្ត្រីរាជការ និង ប្រជាពលរដ្ឋទាំងអស់ត្រូវប្រកាន់ខ្ជាប់ជានិច្ចនូវព្រហ្មវិហារធម៌ទាំង ៤ ខាងលើដើម្បីរក្សាគុណសម្បត្តិល្អនៃសីលធម៌ ។ កាលណាសមាជិកនៃសង្គមបានបដិបត្តិធម៌ទាំងនេះខ្ជាប់ខ្ជួនហើយ សង្គមនោះមុខតែប្រកបដោយសេចក្តីចំរើនរុងរឿង និង សន្តិភាពជាមិនខាន ព្រមទាំងសិទ្ធិមនុស្ស និង ធម្មាធិបតេយ្យពិតជាត្រូវបានលើកតំកើងនិងការពារផងដែរ ។

## ឃ_ ការទទួលខុសត្រូវ និង តម្លាភាព(១)

ភារកិច្ចដែលសំខាន់ជាងគេបង្អស់របស់បុគ្គលិកបំរើសង្គមដូចជា មន្ត្រីរាជការដោយតែងតាំង ឬ ដោយបោះឆ្នោតជ្រើសរើសធ្វើការនៅក្នុងស្ថាប័នរបស់រដ្ឋ គឺត្រូវមានការទទួលខុសត្រូវនៅចំពោះមុខសាធារណៈជន និង ការឱ្យមានតម្លាភាព។

នេះមានន័យថា រាជរដ្ឋាភិបាលត្រូវបង្កើតប្រព័ន្ធមួយដែលបើកចំហឱ្យសាធារណជនទទួលព័ត៌មាន អំពីអ្វីៗដែលរាជរដ្ឋាភិបាលធ្វើ និង អ្វីៗដែលប៉ះពាល់ដល់សង្គម ។ ពីព្រោះប្រជាពលរដ្ឋមានសិទ្ធិដឹងនូវអ្វីដែលរាជរដ្ឋាភិបាលធ្វើ ។ មិនត្រឹមតែឱ្យដឹងប៉ុណ្ណោះទេ បុគ្គលិកបំរើសង្គមទាំងអស់ត្រូវធ្វើសេចក្តីរាយការណ៍ និង បង្កលក្ខណៈងាយស្រួលអោយដល់ប្រជាពលរដ្ឋ និង ប្រព័ន្ធសារព័ត៌មានឯករាជ្យ ក្នុងការចង់មើលសំណុំរឿង និង ចង់បានព័ត៌មានផ្សេងៗថែមទៀតផង ។

## ង_ ហេតុអ្វីបានជាមន្ត្រីរាជការត្រូវអនុវត្ត និង គោរពច្បាប់ក្នុងស្រុក និង ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ?

ទី ១_ ពីព្រោះថា មន្ត្រីរាជការទាំងអស់នោះជាសមាជិកនៃរដ្ឋាភិបាល ។

ទី ២_ ពីព្រោះថា ច្បាប់ក្នុងស្រុកអនុម័តដោយរដ្ឋសភា និង ច្បាប់សិទ្ធិមនុស្សអន្តរជាតិនានា ត្រូវបានដាក់បញ្ចូលនៅក្នុងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា ៣១ ។

ទី ៣_ ពីព្រោះថា គ្មានអ្នកណាម្នាក់ ឬ ស្ថាប័នណាមួយអាចនៅពីលើច្បាប់បានឡើយ ( ធម្មាធិបតេយ្យ ) ។

ទី ៤_ ពីព្រោះថា ច្បាប់នីមួយៗមានចែងអោយមន្ត្រីរាជការទទួលស្គាល់ និង គោរពតាម រួមទាំងតុលាការឯករាជ្យផងដែរ ។

ទី ៥_ ពីព្រោះថា មន្ត្រីរាជការជាអ្នកបំរើប្រជាពលរដ្ឋ ដូច្នេះត្រូវដឹងពីច្បាប់ ហើយត្រូវគោរពច្បាប់មុនគេ ។

ទី ៦_ ពីព្រោះថា បើមន្ត្រីមិនគោរពច្បាប់ នោះនឹងនាំឱ្យមានភាពមិនបរិសុទ្ធ អយុត្តិធម៌ និងអាណាធិបតេយ្យក្នុងប្រទេស ។ នេះបានសេចក្តីថា មន្ត្រីទាំងនោះមិនបានបំពេញភារកិច្ចរបស់ខ្លួនដោយត្រឹមត្រូវ និង មិនទទួលខុសត្រូវនូវអំពើរបស់ខ្លួន ។ ដូច្នេះការអភិវឌ្ឍន៍ខាងសេដ្ឋកិច្ច នយោបាយ និង សង្គមកិច្ចនៅក្នុងប្រទេសក៏ទទួលបានលទ្ធផលមិនពេញលេញដែរ ។

(១) - តម្លាភាព ន័យនៅក្នុងមេរៀននេះគឺថា ភាពឥតលាក់លៀម, ភាពថ្លាមួយកញ្ចក់

- តាមន័យរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ថា ភាពនៃចិត្តថ្លា និង ដោយកុសល ។

www.budinst.gov.kh www.elibraryofcambodia.org

# កម្មវិធីមុខវិជ្ជាសំរាប់គ្រូបង្ហាត់នៃមេរៀនទី ១០

********

## គោលនៃវិជ្ជាសង្គមកិច្ច

១. **គោលដៅ** :

នៅចុងបញ្ចប់នៃមេរៀននេះ សមណសិស្ស និង សិក្ខាកាមអាចយល់ដឹង :

- អំពីការផ្សព្វផ្សាយពត៌មាន និង សេវាកម្ម
- អំពីរបៀបផ្តល់ជំនួយ និង គោលដៅរបស់វា
- អំពីការដោះស្រាយបញ្ហាផ្សេងៗ

២. **ឯកសារយោង** :

- គម្ពីរអភិធម្មនៃព្រះត្រៃបិដក

៣. **សម្ភារៈសិក្សា**

- ក្រដាសជំរុំភ្លឺសំរាប់បញ្ចាំងលើផ្ទាំងក្រណាត់ស
- ក្រដាសសផ្ទាំងធំ និង ឧបករណ៍សរសេរ
- ក្តារខៀន និង ដីស
- មេរៀនលាយលក្ខណ៍អក្សរ

៤. **សំណួរ**

- តើការបង្កើតមជ្ឈមណ្ឌលពត៌មាននៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់យើងមានសារៈសំខាន់ឬទេ ? ពីព្រោះអ្វី ?
- តើចាំបាច់ត្រូវជួយផ្តល់សេវាកម្មជំនួយដល់ប្រជាពលរដ្ឋឬទេ ? ពីព្រោះអ្វី ?
- ហេតុដូចម្តេចបានជាពត៌មានផ្ទាល់ខ្លួនម្នាក់ៗ គេត្រូវរក្សាសម្ងាត់ ? ។
- តើសង្គមកិច្ចមានគោលដៅចុងបញ្ចប់យ៉ាងណា ?
- ការដោះស្រាយបញ្ហានីមួយៗដោយយកផ្លូវកណ្តាល តាមទស្សនៈព្រះពុទ្ធ តើមានប្រសិទ្ធិភាពឬទេ ? ពីព្រោះអ្វី ?

www.budinst.gov.kh www.elibraryofcambodia.org

## ៥_ មេរៀនទី ១០ : គោលនៃវិជ្ជាសង្គមកិច្ច

### ក_ មជ្ឈមណ្ឌលពត៌មាន

#### ១_ និយមន័យ និង គោលដៅ ( ២០នាទី )

- គ្រូបង្ហាត់ត្រូវពិភាក្សាបំផុសគំនិតលើនិយមន័យ និង គោលដៅ ហើយកត់ត្រាទុកលើក្រដាសផ្ទាំងស ឬ ក្ដារខៀន រួចហើយពិភាក្សារកខុសរកត្រូវដើម្បីធ្វើជានិយមន័យមួយ និង គោលដៅមួយដែលស្របទៅនឹង មេរៀន ។
- គ្រូបង្ហាត់ត្រូវបិទក្រដាសផ្ទាំងសទាំងនោះនៅក្នុងថ្នាក់ ។

#### ២_ វិធានការណ៍, សកម្មភាព, ការផ្សាយ, ទីតាំង, ការកត់ត្រាទុក ( ២០នាទី )

- គ្រូបង្ហាត់អត្ថាធិប្បាយមេរៀន ហើយបើកឱ្យសិស្សសួរបញ្ជាក់ ។
- គ្រូបង្ហាត់ត្រូវពន្យល់បន្ថែមលើពាក្យ « សេវាកម្ម, ប្រភពពត៌មាន, ប្រព័ន្ធនៃការផ្សាយ » ។

### ខ_ សេវាកម្មជំនួយ

#### ១_ និយមន័យ និង គោលដៅ ( ២០នាទី )

- គ្រូបង្ហាត់ត្រូវពិភាក្សាបំផុសគំនិតលើនិយមន័យ និង គោលដៅ ហើយកត់ត្រាទុកលើក្រដាសស ឬ ក្ដារខៀន រួចហើយពិភាក្សារកខុសរកត្រូវដើម្បីធ្វើនិយមន័យមួយ និង គោលដៅមួយដែលស្របទៅនឹងមេរៀន ។
- គ្រូបង្ហាត់ត្រូវបិទក្រដាសផ្ទាំងសទាំងនោះនៅក្នុងថ្នាក់រៀន ។

#### ២_ វិធានការណ៍, សកម្មភាព, ទីតាំង និង ការផ្សាយ ( ២០នាទី )

- គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន និង បើកឱ្យសិស្សសួរបញ្ជាក់ ។
- គ្រូបង្ហាត់ត្រូវពន្យល់បន្ថែម ត្រង់ចំណុចថា « ភ្ជាប់ទៅនឹងប្រភពណាដែលអាចជួយបាន » ពាក្យថា « ស្វែងយល់ » « ស្រង់មតិ » និង « បិទសំណុំរឿង » ។

---

សម្រាក ២០នាទី

---

#### ៣_ បទបញ្ញត្តិនៃសេវាជំនួយ ( ២០នាទី )

- គ្រូបង្ហាត់ត្រូវអត្ថាធិប្បាយមេរៀន និង បើកឱ្យសិស្សសួរបញ្ជាក់ ។

www.budinst.gov.kh www.elibraryofcambodia.org

- គ្រូបង្គាត់គួរពន្យល់បន្ថែមត្រង់ចំណុចថា «ព័ត៌មានទាំងឡាយត្រូវរក្សាជាការសម្ងាត់, ការផ្សព្វផ្សាយបានលុះណាមានការអនុញ្ញាតពីសាមីខ្លួនជាមុនសិន » ។

## គ_ ទ្រឹស្ដីព្រះពុទ្ធសាសនាដែលទាក់ទងទៅនឹងសង្គមកិច្ច ( ៦០នាទី )

### គ១_ គោលដៅនៃសេវាកម្មជំនួយ

- គ្រូបង្គាត់ត្រូវអធិប្បាយមេរៀន និង បើកឱ្យសិស្សពិភាក្សាសួរកនុសរកត្រូវ ។ រួចហើយគ្រូបង្គាត់គួរធ្វើការពិចារណាលើករឿងមួយ ឬ ពីរជាឧទាហរណ៍ ។

ឧទាហរណ៍បញ្ហារបស់ជនម្នាក់ដែលត្រូវការសេវាជំនួយ :

« មានជនម្នាក់ឈ្មោះ .................................. បានមកជួបសមណសិស្ស សុំឱ្យជួយដោះស្រាយជីវភាពរបស់គាត់ ពីព្រោះត្រូវទឹកជំនន់លេចផ្ទះ និង ស្រែចំការអស់ ” តើសមណសិស្សត្រូវជួយតាមវិធីណាខ្លះ ?

ទី ១_ ធ្វើការស្វែងយល់ពីស្ថានភាព

ទី ២_ កត់ពត៌មានទុក

ទី ៣_ បើមានលទ្ធភាព :

* ពេលភ្លាមៗ :

- ផ្ដល់ជំរក និង ម្ហូបអាហារបណ្ដោះអាសន្ន

* ពេលយូរអង្វែង :

- ប្រាប់ឱ្យទៅរកអង្គការនានា ឬ មន្ទីរដែលពាក់ព័ន្ធ ដើម្បីសុំជំនួយសង្គ្រោះ ជាពិសេសពូជស្រូវ ឬ ពូជដំណាំ ។

### គ២_ ការដោះស្រាយបញ្ហានានា

- គ្រូបង្គាត់ត្រូវអធិប្បាយមេរៀន និង បើកឱ្យសិស្សពិភាក្សាសួរកនុសរកត្រូវ ។

- គ្រូបង្គាត់ត្រូវពន្យល់ពីអរិយសច្ចៈទាំង ៤ នេះបន្ថែមទៀត ។

- គ្រូបង្គាត់គួរធ្វើការពិចារណាលើកបញ្ហាមួយ ឬ ពីរ ធ្វើជាឧទាហរណ៍បន្ថែមលើឧទាហរណ៍ដែលមាននៅក្នុងមេរៀន ដោយឱ្យសមណសិស្ស ឬ សិក្ខាកាមពិភាក្សាបំពុសគំនិតតាមលំដាប់លំដោយនៃសច្ចៈនីមួយៗដូចមានក្នុងអរិយសច្ចៈទាំង ៤ ដើម្បីរៀនដោះស្រាយបញ្ហាទាំងនោះដោយខ្លួនឯង ។

www.budinst.gov.kh www.elibraryofcambodia.org

# មេរៀនទី ១០
# មូលដ្ឋាននៃវិជ្ជាសង្គមកិច្ច

## ក_ មជ្ឈមណ្ឌលព័ត៌មាន

### ១_ និយមន័យ :

មជ្ឈមណ្ឌលផ្តល់ព័ត៌មាន គឺជាកន្លែងមួយសម្រាប់ជូនព័ត៌មានផ្សេងៗដល់ប្រជាពលរដ្ឋអំពីមុខរបរ ការងារប្រាក់បំណាច់ សេវាកម្មសង្គមកិច្ច សេវាកម្មទាក់ទងនឹងច្បាប់ ព័ត៌មានអំពីច្បាប់ព្រះរាជាណាចក្រកម្ពុជា រួមទាំងច្បាប់សិទ្ធិមនុស្ស ឯកសារសិទ្ធិមនុស្ស និង ព័ត៌មានផ្សេងៗទៀត ។

### ២_ *គោលដៅ* :

គោលដៅនៃមជ្ឈមណ្ឌលផ្តល់ព័ត៌មាននេះ គឺដើម្បីធ្វើឱ្យសិទ្ធិរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ដោយភ្ជាប់សេចក្តីត្រូវការទៅនឹងប្រភពជំនួយទាំងឡាយ ។

### ៣_ *វិធានការណ៍ និង សកម្មភាព* :

ព័ត៌មានទាំងឡាយត្រូវផ្តល់ជូនដល់ប្រជាពលរដ្ឋ តាមសេចក្តីស្នើរបស់សាមីជន ឬ ចែកផ្សាយព័ត៌មានជាទូទៅដល់សាធារណៈជន ។ ការផ្តល់ព័ត៌មាននេះ អាចធ្វើនៅតាមវត្ត ឬ នៅពេលចុះទៅសួរសុខទុក្ខតាមផ្ទះតាមភូមិ ឬ ក្នុងពិធីបុណ្យសាសនានានា ។

សកម្មភាពនៃការផ្តល់ព័ត៌មានទាំងនោះមានដូចតទៅ :

- ត្រូវសាកសួរប្រជាពលរដ្ឋឱ្យដឹងច្បាស់លាស់អំពីប្រភេទនៃព័ត៌មានដែលប្រជាពលរដ្ឋចង់បាន ។
- ត្រូវផ្តល់ព័ត៌មានអំពីសេវាកម្ម និង ប្រភពធនធានឱ្យបានជាក់លាក់ និង ត្រឹមត្រូវ ។
- ត្រូវយល់ឱ្យច្បាស់លាស់ ហើយអធិប្បាយពន្យល់នូវប្រភេទព័ត៌មានដែលមាន ។ ត្រូវដឹងថា តើធ្វើយ៉ាងដូចម្តេចដើម្បីឱ្យបានទទួលព័ត៌មាននេះ ឬ ត្រូវទាក់ទងប្រភពធនធានណាខ្លះ ? ហើយតើព័ត៌មាននោះមាននៅទីកន្លែងណាខ្លះ ?

### ៤_ *ការផ្សាយ* :

ប្រព័ន្ធនៃការផ្តល់ព័ត៌មាននេះ ត្រូវផ្សាយអោយបានទៅដល់គ្រប់ប្រជាពលរដ្ឋ និង ឧបាសក ឧបាសិកា នៅក្នុងពិធីបុណ្យសាសនា ឬ តាមមធ្យោបាយផ្សេងៗទៀត ។

### ៥_ *ការកត់ត្រា* :

ត្រូវធ្វើបញ្ជីប្រជាពលរដ្ឋដែលបានទទួលព័ត៌មាន សេវាកម្ម ឬ ជំនួយផ្សេងៗ ហើយរក្សាទុកជាសម្ងាត់ដោយអោយមានកត់ឈ្មោះ និង អាសយដ្ឋានផងដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

## ខ_ សេវាកម្មជំនួយ

### ១_ និយមន័យ :

សេវាកម្មជំនួយ គឺជាការជួយប្រជាពលរដ្ឋឱ្យបានទទួលនូវសេវាកម្ម និងធនធាន ដែលត្រូវការទាំងឡាយ ហើយនិង ជួយឱ្យបានសំរេចនូវអ្វីៗដែលប្រជាពលរដ្ឋត្រូវការជាចាំបាច់ ។

### ២_ គោលដៅនៃសេវាកម្មជំនួយ :

គោលដៅនៃសេវាកម្មជំនួយ គឺជួយប្រជាពលរដ្ឋដែលគ្មានទីពឹងលើក្រុមគ្រួសារ ឬ ពុំអាចទទួលជំនួយចាំបាច់ ឬ គ្មានទទួលជំនួយតែម្តង ។

### ៣_ វិធានការណ៍ និង សកម្មភាព :

សេវាកម្មជំនួយនេះគឺជាប្រព័ន្ធដែលរៀបចំឡើងដោយព្រះសង្ឃព្រះពុទ្ធសាសនា ដើម្បីជួយប្រជាពលរដ្ឋដែលត្រូវការសេវាកម្ម និងជំនួយទាំងឡាយ ដោយជួយភ្ជាប់ប្រជាពលរដ្ឋទាំងនោះទៅនឹងប្រភពណាដែលអាចជួយបាន។ ការផ្តល់សេវាកម្មជំនួយនេះមាន ការជួយផ្តល់ពត៌មាន ការប្រាប់ឱ្យទៅរកប្រភពធនធាន និងការជួយណែនាំអប់រំ។

ការផ្តល់សេវាកម្មជំនួយដល់ប្រជាពលរដ្ឋ ត្រូវមានសកម្មភាពដូចតទៅនេះ :

- ធ្វើការស្វែងយល់អំពីសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។
- រៀបចំបង្កើតសំណុំរឿងរបស់សាមីជនម្នាក់ៗ ហើយរក្សាទុកជាសម្ងាត់ដោយមនេធ្វើថែនការសេវាកម្មផង ។
- រៀបចំឱ្យមានការស្រង់ស្ថិតិរបស់ប្រជាពលរដ្ឋដែលបានទទួលជំនួយ ។
- ជួយអប់រំណែនាំក្នុងវិស័យសុភាវធម៌ ចរិយាធម៌ ធម្មាធិបតេយ្យ និង សីលធម៌តាមបែបសាសនា ។
- បង្ហាត់ហ្វឹកហ្វឺនសិទ្ធមនុស្ស ដែលមាននៅក្នុងរដ្ឋធម្មនុញ្ញ សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស និង ច្បាប់អន្តរជាតិស្តីអំពីសិទ្ធិមនុស្ស ។
- ផ្តល់ការឧបត្ថម្ភជំនួយ ហើយនឹង អប់រំដល់អ្នកជាប់ឃុំឃាំង និង ទណ្ឌិត ។
- បង្ហាត់ហ្វឹកហ្វឺនអំពីការទំនាក់ទំនងរវាងព្រះពុទ្ធសាសនា និង សិទ្ធិមនុស្ស ។
- ផ្តល់ជំនួយឧបត្ថម្ភ និង ការអប់រំដល់អ្នករងគ្រោះដោយការបង្ខំឱ្យធ្វើពេស្យាចារ និង អ្នករងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ ។
- ផ្តល់ជំនួយឧបត្ថម្ភ ដើម្បីជួយលើកតំកើង និង ការពារបរិស្ថាន ។
- ផ្តល់ការទ្រទ្រង់ ផ្តល់ជំនួយផ្សេងៗ និង ជួយណែនាំពន្យល់នូវជនដែលមានជំងឺអេដស៍ ។
- ជួយប្រាប់ឱ្យទៅរកប្រភពធនធានចាំបាច់ ។
- ជួយណែនាំឱ្យបានទទួលសេវាកម្មចាំបាច់ ។
- ជួយតាមពិនិត្យឱ្យដឹងថា តើការប្រាប់ឱ្យទៅរកសេវាកម្មនោះបានសម្រេចហើយឬនៅ ហើយសាមីខ្លួនពេញចិត្តឬទេ ?
- បិទសំណុំរឿងវិញ កាលណាសេចក្តីត្រូវការរបស់សាមីជនបានសម្រេច និង អស់ចិត្តហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

- ធ្វើការតាមដានយ៉ាងតិចណាស់ឱ្យបានម្ដងក្នុងមួយខែ ឬ លើសពីនេះក៏បាន ក្នុងចំណោមសំណុំរឿងដែលបានបិទហើយនោះ ។

## ៤_ ទីតាំងសេវាកម្មជំនួយ :

ទីតាំងនៃសេវាកម្មជំនួយនេះអាចបង្កើតនៅក្នុងវត្តអារាម ឬ កន្លែងសមស្របណាមួយផ្សេងទៀតក៏បាន ។

## ៥_ ការផ្សាយ :

សេវាកម្មជំនួយត្រូវផ្សាយឱ្យប្រជាជន និង ឧបាសក ឧបាសិកាទាំងអស់ផ្ទាល់ដឹង ។

## ៦_ បទបញ្ញត្តិនៃសេវាជំនួយ :

អាចធ្វើទៅបានចំពោះការប្រាប់ឱ្យដឹងអំពីពត៌មានរបស់ប្រជាពលរដ្ឋម្នាក់ៗទៅបុគ្គលសង្គមកិច្ច ឬ អង្គការនានា ក្នុងការធ្វើអភិវឌ្ឍន៍សហគមន៍ ជួយផ្ដល់សេវាកម្មនានា និង សេវាកម្មដែលទាក់ទងខាងផ្លូវច្បាប់ ឬ ខាងសិទ្ធិមនុស្ស ក្នុងគោលបំណងដើម្បីសម្រួលធ្វើកិច្ចការទាំងនេះ ។ ក៏ប៉ុន្តែ អ្នកទាំងនោះត្រូវទុកពត៌មានទាំងឡាយដែលខ្លួនទទួលជាការសម្ងាត់ ។ ការផ្សាយពត៌មានទៅភ្នាក់ងារសង្គមកិច្ច ឬ អង្គការដែលទាក់ទងផងដែរ ត្រូវមានការអនុញ្ញាតពីសាមីខ្លួនជាមុនសិន ។

## ៧_ ការកត់ត្រា :

ការកត់ត្រាទុកពត៌មានសំខាន់របស់ប្រជាពលរដ្ឋ ត្រូវរក្សាទុកជាប់នៅជាមួយព្រះសង្ឃដែលដើរតួជាភ្នាក់ងារជួយសហគមន៍ មានដូចតទៅនេះ :

- ឈ្មោះ និង អាសយដ្ឋាន ។
- ឈ្មោះ អាសយដ្ឋាន និង លេខទូរស័ព្ទរបស់ជនរងគ្រោះ បើមាន ។
- ឈ្មោះ អាសយដ្ឋាន និង លេខទូរស័ព្ទ របស់មនុស្សណាដែលត្រូវទាក់ទង កាលណាមានភាពអាសន្ន ។
- ចំណេះវិជ្ជា និង ការពិសោធន៍ ។
- មុខរបរ ។
- ពត៌មានផ្ទាល់ខ្លួន ។
- ផែនការណ៍នៃសេវាកម្ម ។
- ការសរសេរកត់ត្រាទុកនូវសេវាកម្មទាំងឡាយដែលបានផ្ដល់ឱ្យ ។
- សេចក្ដីរាយការណ៍សរុបអំពីការបិទករណី ។

www.budinst.gov.kh www.elibraryofcambodia.org

## គ_ ទ្រឹស្តីព្រះពុទ្ធសាសនាដែលទាក់ទងទៅនឹងវិជ្ជាសង្គមកិច្ច

### គ១_ គោលដៅនៃសេវាកម្មជំនួយ : ( *អត្តាហិ អត្តនោ នាថោ : ខ្លួនទីពឹងខ្លួន* )

តាមន័យអត្តរូប ពុទ្ធភាសិតនេះហាក់ដូចជាបង្កើតភាពឯកោ ដែលផ្ទុយពីសង្គមសាស្ត្រ តែតាមការពិតគឺសំដៅតែទៅលើការប្រតិបត្តិធម៌ ការរៀនធម៌ ឬរៀនចំណេះវិជ្ជាផ្សេងៗតែប៉ុណ្ណោះទេ ដែលមនុស្សរាល់រូបមិនអាចពឹងនរណាក្រៅពីខ្លួនឯងបានឡើយ ។

បើសិនជាយើងប្រែឱ្យចំន័យត្រឹមត្រូវនៃភាសាបាលីនោះ ទ្រឹស្តីព្រះពុទ្ធនេះមានន័យថា " រឹងខ្លួនហ្នឹងឯងជាទីពឹងរបស់ខ្លួន " ដែលមានន័យសំដៅទៅលើការបង្កើតឱ្យមានភាពឯករាជ្យទៅវិញទេ ។ បើគោលទៅលើវិជ្ជាសង្គមកិច្ចសម័យបច្ចុប្បន្ន ភាពឯករាជ្យនេះ គឺជាគោលដៅនៃការជួយប្រជាពលរដ្ឋដែលអង្គការនានាធ្វើនៅក្នុងព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃ ។

ឧទាហរណ៍ : ការជួយជនពិការ

តាមធម្មតាជនពិការម្នាក់ៗ តែងពុំមានជំនឿលើខ្លួនឯងទេ ដូចនេះហើយបានជាអង្គការនានាគេជួយតម្លៃតជើងសិប្បនិម្មិត បង្រៀនវិជ្ជាជីវៈ ដើម្បីបង្កើតជំនឿ រួចហើយគេជួយរកការងារឱ្យធ្វើ ឬ ផ្តល់ដើមទុនឱ្យប្រកបមុខរបរដើម្បីធ្វើអំពើជួយខ្លួនឯង ។

ដូចនេះ ការផ្តល់ជំនួយ ការសុំជំនួយ ឬ អ្នកទទួលជំនួយ ត្រូវគិតយ៉ាងណា ដើម្បីយកជំនួយនោះ មកធ្វើឱ្យមានភាពឯករាជ្យ គឺម្ចាស់លើខ្លួនឯង ដែលអាចរស់នៅដោយខ្លួនឯង ។

### គ២_ ការដោះស្រាយបញ្ហានានា :

តាមទ្រឹស្តីរបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គបានប្រដៅទុកមក ដើម្បីដោះស្រាយបញ្ហានានាក្នុងសង្គមមានដូចនៅក្នុងអរិយសច្ចៈទាំង ៤ ។ អរិយសច្ចៈទាំង ៤ ប្រាប់នូវលំដាប់នៃការរិះគិត ដោះស្រាយ និង អត្ថន័យនៃសច្ចៈនីមួយៗ ។ ព្រះអង្គបានលើកយក :

សច្ចៈទី១ គឺ **ទុក្ខសច្ចៈ** : ដើម្បីស្វែងយល់អំពីកត្តា និងធាតុរួមផ្សំដែលបង្កើតជាសេចក្តីទុក្ខ ។

សច្ចៈទី២ គឺ **សមុទយសច្ចៈ** : ហេតុដែលនាំឱ្យកើតសេចក្តីទុក្ខ ។

សច្ចៈទី៣ គឺ **និរោធសច្ចៈ** : ភាពរលត់ទុក្ខ ។

សច្ចៈទី៤ គឺ **មគ្គសច្ចៈ** : ផ្លូវដែលជាវិធានការដើម្បីរំលត់ទុក្ខ ។

ដូចនេះ ដើម្បីដោះស្រាយនូវបញ្ហាសព្វសារពើដែលកើតមានឡើងនៅជុំវិញខ្លួនយើង គប្បីត្រូវប្រតិបត្តិរកដំណោះស្រាយតាមផ្លូវកណ្តាលដែលព្រះសម្មាសម្ពុទ្ធបានកំណត់មកហើយដូចខាងលើ ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ : បញ្ហាភាពក្រីក្រ ( ទុក្ខ )

ទី ១ : កត្តា និង ធាតុរួមផ្សំដែលបង្កើតភាពក្រីក្រ ( អត់ដើមទុន, អត់ទ្រព្យសម្បត្តិ។ល។ និង ។ល។ )

ទី ២ : ហេតុនៃសេចក្តីក្រីក្រ ( អវិជ្ជា, គ្មានសុខភាព, គ្មានជំនាញ, ពិការ, មានជំលោះផ្ទៃក្នុង, ឥតការងារធ្វើ, ។ល។ និង ។ល។ )

ទី ៣ : ការបំបាត់ភាពក្រីក្រ ( ធ្វើឱ្យមានដើមទុន, មានដីធ្លី, មានការសិក្សាគ្រប់គ្រាន់, មានការថែរក្សាសុខុមាលភាព, មានលំនៅដ្ឋានគ្រប់គ្រាន់, មានគ្រូបង្រៀនវិជ្ជាជីវៈ, មានការងារធ្វើគ្រប់គ្រាន់...... ។ល។ )

ទី ៤ : ផ្លូវជាវិធានការនៃការបំបាត់ភាពក្រីក្រ ( បញ្ចប់ជំលោះផ្ទៃក្នុង, សង់សាលារៀនឱ្យបានគ្រប់គ្រាន់, សង់មន្ទីរពេទ្យឱ្យបានគ្រប់គ្រាន់, បង្កើតឱ្យមានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់គ្រាន់, ជួយរកការងារធ្វើ, ផ្តល់ដើមទុន, បង្រៀនវិជ្ជាមេគ្រួសារ, បង្រៀនមុខជំនាញកសិកម្ម និង ពាណិជ្ជកម្ម, បង្កើនសីលធម៌នៃជាតិសាសន៍, ។ល។ )

www.budinst.gov.kh www.elibraryofcambodia.org

ឧបត្ថម្ភដោយ

**អង្គការអ៊ីក្សប្រូធេសហ្វឡង់**

**និង**

**មជ្ឈមណ្ឌលសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិនៅកម្ពុជា**

រៀបចំដោយ

**ពុទ្ធិកសមាគមខ្មែរនៅកម្ពុជា**



ទីស្នាក់ការ

ផ្ទះលេខ ១១៨អឺ ផ្លូវលេខ ១៥០ សង្កាត់ផ្សារដេប៉ូ ខណ្ឌទួលគោក

ទីក្រុងភ្នំពេញ

www.budinst.gov.kh www.elibraryofcambodia.org